ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី៤ ឆ្នាំ២០២០

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក ស វ




ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

www.ecosocc.gov.kh

info@ecosocc.kh

(855) 012 915 577 (855) 012 912 009

# គតិបណ្ឌិតរដ្ឋបុរសជាតិ

« យកវិស័យអប់រំ  វិនិយោគឲ្យអប់រំ »

« យើងអភិវឌ្ឍប្រទេស  តាមបែបជំហានគីង្គក់ »

« ប្រូតស្រូវក្នុងទឹក  ប្រសើរជាងគ្មានស្រូវប្រូត »

« ខ្មែរមានកិត្តិយសរបស់ខ្មែរ  ខ្មែរត្រូវការជំនួយអភិវឌ្ឍ
តែក៏ត្រូវការកិត្តិយសខ្មែរដែរ »

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង

- យឹម ណុលសន

និពន្ធនាយក

- អ៊ីវ ថុង

ការិយាល័យនិពន្ធ

- នរ៉ាណាឫទ្ធិ

អាននន្ទដាយ៉ាត

- លី គឹមសុខ

- ឆយ អូន

- ទីប្រឹក្សាបច្ចេកទេស

- សមាជិក-សមាជិកា

នៃក្រុមប្រឹក្សា

សេដ្ឋកិច្ច សង្គមកិច្ច

និងវប្បធម៌

អ្នកចាត់ចែងផលិត

- ប៉ិច សុខា

- អ៊ិន គុលា

អ្នកចែកផ្សាយ

- អៀង រដ្ឋា

- សេក វុទ្ធី

ការីកុំព្យូទ័រ

- អេង រត្នមុនី

- សយ វាស្នា

- យឹម ច័ន្ទតារា

# មាតិកា

**ទំព័រ**


I- បទអត្ថាធិប្បាយ " សន្តិភាព និង ការអភិវឌ្ឍ ជាវត្ថុភ្លោះ ! " ១

II- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តៈ

១- ការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ២-៣

២- សេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ ៤-៥

III- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ ៦-១៣

IV- បទវិភាគៈ

១- លក្ខខណ្ឌទ្រទ្រង់សេដ្ឋកិច្ចជប៉ុន ១៤-១៩

២- អំណាចជាអ្វី? ២០

៣- ការស្រឡាញ់ជាតិ ២១-២២

V- សកម្មភាពផ្សេងៗរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ២៣-២៦

VI- នាទីវប្បធម៌

- បច្ចេកសព្ទ ២៧-២៨

- ស្រាវជ្រាវ : យល់ដឹងអំពីពាក្យ " ប្រពៃណីបុណ្យអុំទូក អកអំបុក សំពះព្រះខែ " ២៩-៣២

VII- នាទីកំណាព្យ

- គង់តែ! (បទពាក្យ៤ - មួយវគ្គមាន៨ឃ្លា) ៣៣

- វស្សាដើមឆ្នាំ (បទពាក្យ៧) ៣៣

VIII- នាទីកំសាន្ត

- រឿងបុរសយកលាទៅលក់ ៣៤

- រឿងល្បើកថ្មើរជើងម្នាក់ ៣៤

IX- ការវិវត្តនៃប្រព័ន្ធទឹកសាប និងប្រវត្តិនៃវិស័យជលផលទឹកសាបកម្ពុជា (ត) ៣៥-៤៣

# សន្តិភាព និង ការអភិវឌ្ឍ ជាវត្ថុភ្លោះ !

ប្រជាពលរដ្ឋខ្មែរ ទើបនឹងបានទទួលមនុញ្ញផលសន្តិភាពពេញលេញ តាមរយៈមាគ៌ានយោបាយឈ្នះ ឈ្នះរបស់សម្តេចតេជោ **ហ៊ុន សែន** មានរយៈពេលជាង២០ឆ្នាំប៉ុណ្ណោះ។សន្តិភាព នាំមកនូវការបង្រួបបង្រួមជាតិដែលមានតម្លៃស្មើជីវិតមិនត្រឹមតែសម្រាប់ពេលបច្ចុប្បន្នកាលនេះទេប៉ុន្តែវាក៏សម្រាប់អនាគតកាលរបស់កម្ពុជាទៀតផង។ពាក្យថា **សន្តិភាព** បើពោលវាងាយណាស់តែបើបង្កើតឱ្យមានភាពសុខសាន្តត្រាណក្នុងផែនឯកភាពជាតិ វាពិបាកជាងទៅសុំភ្លើងយក្សទៅទៀត។ ចំណែកពាក្យថា **អភិវឌ្ឍន៍** សំដៅការកសាង ជាតិឱ្យរីកចម្រើនសំបូរសប្បាយ ហើយការអភិវឌ្ឍអាចប្រព្រឹត្តទៅបានតែនៅក្នុងកាលានុវត្តភាពពិសេសតែ មួយគត់ គឺ សន្តិភាព។ ហេតុដូច្នេះហើយ បានជាគេសង្កេតឃើញថា ទីណាមានសន្តិភាព បានសេចក្តីថា ទីនោះមានសន្តិសុខ សុវត្ថិភាព និងស្ថិរភាពនយោបាយសង្គម ប្រាកដណាស់ជាមានការអភិវឌ្ឍយ៉ាងគគ្រឹកគ្រេងលើគ្រប់វិស័យ ទើបបានមានពាក្យថា **សន្តិភាព និង អភិវឌ្ឍន៍ ជាវត្ថុភ្លោះ** ដែលចង់បញ្ជាក់យ៉ាងច្បាស់ថា មានមួយឥតមួយមិនបានជាដាច់ខាត។គេមិនដែលជួបប្រទះទាល់តែសោះនូវស្ថានភាពសង្គ្រាមនិងអភិវឌ្ឍន៍ឡើយនៅលើលោកយើងនេះ។ គឺមានតែសង្គ្រាម និងវិនាសកម្ម ដែលកម្ពុជាយើងក៏ធ្លាប់បានជួបប្រទះក្នុងអតីតកាលផងដែរ។

ការកសាងឯករាជ្យនៃកម្ពុជា បាននាំឱ្យប្រទេសនេះមានសន្តិភាព ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោ **ហ៊ុន សែន** វីរបុរសជាតិខ្មែរ ដែលបានយកជីវិតធ្វើជាដើមទុនរំដោះជាតិពីរបបស្រេកឈាមប្រល័យពូជសាសន៍ប៉ុលពតហើយបាននឹងកំពុងអភិវឌ្ឍសមិទ្ធិសង្គមកម្ពុជាដ៏ស្ដឹមស្ដៃ និងទំនើបទាន់សម័យ មិនចាញ់អារ្យប្រទេសប៉ុន្មានទេ ហើយដែលសង្គមខ្មែរយើងពីមុនមកមិនដែលមាន។ ទាំងជនជាតិខ្មែររស់នៅបរទេស ទាំងទេសចរណ៍បរទេសបានជញ្ជក់មាត់ស្ងើចសរសើរមិនដាច់ពីមាត់នូវវឌ្ឍនភាពកម្ពុជា ដែលមិននឹកស្មានដល់ថាលឿនដូចនេះ។

ប៉ុន្តែក៏នៅមានពួកកាកសំណល់ខ្មែរបម្រើបរទេសមួយចំនួនតូច មិនសប្បាយចិត្តនឹងស្ថានភាពកម្ពុជាសព្វថ្ងៃនេះទេ ពួកគេជឿស្លុងផ្កាប់មុខ ដាក់ខ្លួនជាអាមាត្យមហាយក្សប្រជាធិបតេយ្យ ដើម្បីតែផលប្រយោជន៍ក្រុមខ្លួនមួយក្តាប់តូចប៉ុណ្ណោះ។

សន្តិភាពឯកភាពជាតិឯករាជ្យភាពពិតជាកើតមានបានដោយសារសេចក្តីក្លាហាននិងបដិភាណរបស់កូនខ្មែរក្នុងទិសស្លោក " **ខ្មែរធ្វើបាន** " ហើយជាតិខ្មែរនៅត្រូវការវីរបុរសជាតិ ដឹកនាំប្រទេសយូរអង្វែងទៀត នោះគឺ សម្តេចតេជោ **ហ៊ុន សែន** បិតាស្ថាបនិកសន្តិភាពកម្ពុជា៕

**ដោយបណ្ឌិតសាស្ត្រាចារ្យ - អ៊ីវ ចុង**

## ១- ការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត គោលបំណង/គោលដៅ

ដើម្បីឱ្យការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតមានការឯកភាព រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរលេខ០៣ សរ. ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៣ ស្តីពីគោលការណ៍ណែនាំអំពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតណែនាំឱ្យក្រសួងស្ថាប័នផ្សព្វផ្សាយអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួននូវគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលបានទទួលការឯកភាពពីគណៈ រដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣។

តាមគោលការណ៍ណែនាំខាងលើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាពិសេសសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលត្រូវដាក់ឆ្លងប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យពិភាក្សាផ្តល់ការឯកភាពផ្ញើជូនប្រធានរដ្ឋសភា ឬថ្វាយព្រះមហាក្សត្រឡាយព្រះហស្ថលេខា ឬជូននាយករដ្ឋមន្ត្រីសូមហត្ថលេខាលិខិតបទដ្ឋានគតិយុត្តទាំងអស់នេះត្រូវតាក់តែង និងឆ្លងកាត់ការពិនិត្យពិភាក្សាច្រើនដំណាក់កាលទាំងក្នុងក្រសួងសាមីទាំងជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ការពិភាក្សាដែលចំណាយពេលវេលាមិនតិចប៉ុន្មានដែរនោះ គឺនៅត្រង់ចំណុចស្តីពីគោលបំណង និងគោលដៅ។

អ្នកចូលរួមទាំងអស់នៅក្នុងការពិនិត្យពិភាក្សាសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតសុទ្ធតែបានយល់ច្បាស់ថា ដើម្បីសម្រេចគោលបំណងបាន គឺត្រូវមានគោលដៅ។

សៀវភៅគោលការណ៍ណែនាំឆ្នាំ២០១៣ ទំព័រ៦/១៣០ រៀបរាប់ថា "គោលបំណង គោលដៅ ...ត្រូវចែងជាបន្តបន្ទាប់នៅក្នុងមាត្រា១ មាត្រា២..." បានសេចក្តីថា រាល់សេចក្តីព្រាងច្បាប់ទាក់ទងនឹងទម្រង់ចំណុចបទប្បញ្ញត្តិទូទៅ គឺត្រូវមានគោលបំណង ដែលត្រូវចែងក្នុងមាត្រា១ និងគោលដៅ ដែលត្រូវចែងក្នុងមាត្រា២ បន្ទាប់។

ក្នុងការអនុវត្តជាក់ស្តែងយើងសង្កេតឃើញមានការច្រឡំគ្នារវាងគោលបំណងនិងគោលដៅ។នៅក្នុងអង្គពិភាក្សាអ្នកចូលរួមយល់ថាអ្វីដែលសរសេរនៅក្នុងគោលបំណងមានខ្លះជាគោលដៅហើយនៅក្នុងគោលដៅក៏មានអ្វីជាគោលបំណងខ្លះដែរ ដែលធ្វើឱ្យការពិភាក្សាម្តងៗស៊ីពេលវេលាយូរ ពិបាករកការឯកភាពគ្នា។

ចំពោះការសរសេរមុនក្រោយក៏ចោទជាបញ្ហាដែរ ហើយមានសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តខ្លះបញ្ចូលខ្លឹមសារនៃគោលបំណងនិងគោលដៅជាមួយគ្នាក៏មាន។

ជាការដោះស្រាយចំពោះបញ្ហាទាំងឡាយដែលកើតមានឡើងទាក់ទងដល់ការតាក់តែងគោលបំណងនិងគោលដៅ គណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ បន្ទាប់ពីបានពិនិត្យនិងកែសម្រួលខ្លឹមសារនៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន នៅក្នុងបញ្ហាផ្សេងៗ ចំណុច២.៧ បានសម្រេចថា៖

"ចំពោះការរៀបចំសេចក្តីព្រាងច្បាប់ថ្មីៗនាពេលខាងមុខត្រូវរៀបចំជាទម្រង់ ដែលមានមាត្រាចែងពីគោលបំណងបានហើយ ដោយមិនចាំបាច់មានមាត្រាចែងអំពីគោលដៅទេ" (សជណ លេខ៤៣៣ អកទ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០)។

សេចក្តីជូនដំណឹងបានលើកឡើងអំពីការតាក់តែងសេចក្តីព្រាងច្បាប់តែការណែនាំនេះក៏អនុវត្តចំពោះសេចក្តីព្រាងព្រះរាជក្រឹត្យនិងសេចក្តីព្រាងអនុក្រឹត្យដែរព្រោះនៅក្នុងសៀវភៅគោលការណ៍ណែនាំឆ្នាំ២០១៣មានការចង្អុលបង្ហាញថាការតាក់តែងសេចក្តីព្រាងព្រះរាជក្រឹត្យនិងសេចក្តីព្រាងអនុក្រឹត្យដែលមានលក្ខណៈ

ជាបទបញ្ញាទូទៅត្រូវអនុវត្តដូចសេចក្ដីព្រាងច្បាប់ដែរ។ ដូច្នេះ បើមានការណែនាំចំពោះសេចក្ដីព្រាងច្បាប់ឱ្យមានមាត្រាចែងអំពីគោលបំណង មិនចាំបាច់មានចែងអំពីគោលដៅនោះចំពោះសេចក្ដីព្រាងព្រះរាជក្រឹត្យ និងសេចក្ដីព្រាងអនុក្រឹត្យដែលមានលក្ខណៈជាបទបញ្ញាទូទៅក៏ដូច្នេះដែរ។

តើការរៀបចំឱ្យមានមាត្រាតែមួយចែងអំពីគោលបំណងនេះយ៉ាងដូចម្ដេច?

យើងសាកល្បងពិនិត្យមើលមាត្រា៩នៃច្បាប់ស្ដីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ៥៤២០/០១៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ ៖

មាត្រា១.- គោលបំណង

ច្បាប់នេះកំណត់អំពីបែបបទនីតិវិធីនិងលក្ខខណ្ឌនៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ននៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រមទាំងការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្នុងគោលបំណងដើម្បីការពារសន្ដិសុខជាតិនិងសណ្ដាប់ធ្នាប់សាធារណៈ ការពារអាយុជីវិតនិងសុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងការពារទ្រព្យសម្បត្តិនិងបរិស្ថាន។

យើងអាចចោទសួរថា តើអ្វីជាគោលបំណងនៃច្បាប់នេះ? តើការកំណត់អំពីបែបបទ...ឬការការពារសន្ដិសុខជាតិ...?

"ច្បាប់នេះកំណត់អំពីបែបបទនីតិវិធី... នៃការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន... ព្រមទាំងការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន..."។ បែបបទនីតិវិធី និងលក្ខខណ្ឌនៃការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នមានចែងលម្អិតនៅក្នុងជំពូកទី២នៃច្បាប់រីឯវិធានការក្នុងការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពមានអាសន្ន គឺមានចែងនៅក្នុងជំពូកទី៣បន្ទាប់។

ដូច្នេះការសរសេរថា "ច្បាប់នេះកំណត់" ឬ "មានគោលដៅកំណត់" ដូចដែលធ្លាប់ប្រើកន្លងមកនោះមានន័យថា "គោលដៅ" គឺចង្អុលបង្ហាញអំពីចំណុច (ឬគោលដៅ) សំខាន់ៗសម្រាប់អនុវត្តឈានទៅរកការសម្រេចនូវ"គោលបំណង"ដ៏ទូលំទូលាយមួយដែលនៅក្នុងច្បាប់ខាងលើនេះគឺ"ការពារសន្ដិសុខជាតិ និងសណ្ដាប់ធ្នាប់សាធារណៈការពារអាយុជីវិតនិងសុខភាពប្រជាពលរដ្ឋព្រមទាំងការពារទ្រព្យសម្បត្តិនិងបរិស្ថាន"។ "គោលដៅ" គឺគោលចំណុចដែលយើង "ដៅ" ដែលយើង "កំណត់" ដែលយើងដាក់ចេញប្រកបដោយលក្ខណៈច្បាស់លាស់ ជាក់លាក់ ប្រាកដប្រជា ដើម្បីលទ្ធផលរំពឹងទុកមួយ គឺការការពារសន្ដិសុខជាតិ និងសណ្ដាប់ធ្នាប់សាធារណៈ...។

ការណែនាំតម្រូវឱ្យមានការរៀបចំជាមាត្រាតែមួយ ចែងអំពីគោលបំណងក៏ពិតមែន តែការសរសេរគាត់តែងត្រូវមានភាពទន់ភ្លន់ត្រូវចេះសរសេរព្រោះមាត្រា១នៃច្បាប់នេះប្រៀបបាននឹងសេចក្ដីផ្ដើមនៃការតែងសេចក្ដីមួយដូច្នោះដែរ ដែលបង្ហាញឱ្យឃើញនូវអ្វីដែលត្រូវរៀបចំជាបន្តនៅក្នុងតួសេចក្ដីនិងក្នុងសន្និដ្ឋាន។ ទន់ភ្លន់ត្រង់ថា មិនចែងតែអំពីគោលបំណងទេ តែមានរំលេចអំពីគោលដៅទៀត ហើយត្រូវចេះសរសេរ គឺចង់និយាយថា មិនចាំបាច់សរសេរគោលដៅមុនគោលបំណងដូចច្បាប់ខាងលើនោះទេ ដាក់គោលបំណងមុនក៏បាន អាស្រ័យទៅនឹងរចនាសម្ព័ន្ធនៃល្បះដែលយើងសរសេរ ធ្វើយ៉ាងណាឱ្យស្ដាប់បាន ត្រឹមត្រូវតាមក្បួនវេយ្យាករណ៍។ ការសរសេរតែពីគោលបំណងសុទ្ធតែមួយមុខ ក៏មិនមែនជាប្រការហាមឃាត់ដែរ ប៉ុន្តែយកល្អគប្បីចេះច្របាច់បញ្ចូលគ្នានូវគោលដៅនិងគោលបំណងនេះព្រោះថាគោលបំណងគឺជាលទ្ធផលរំពឹងទុកដែលលេចចេញពីគោលដៅបើនិយាយតែពីគោលបំណងមិនរំលេចនូវគោលដៅដែលយើងកំណត់បានច្បាស់លាស់ហើយនោះ នោះគំនិតរបស់យើងហាក់ដូចជាខ្វះភាពឡូស៊ីក មិនប្រទាក់ក្រឡាគ្នា៕

*ដោយ សួង លាងហៃ - (ក.ស.វ. - ក្រុម ១)*

## ២- សេចក្តីព្រាងច្បាប់ស្តីពី

# មូលបត្ររដ្ឋ

មូលបត្ររដ្ឋ គឺជាឧបករណ៍ដ៏សំខាន់១នៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាលអាចប្រើក្នុងការកៀរគរសាច់ប្រាក់ពីក្នុងស្រុកនិងក្រៅប្រទេសដើម្បីធ្វើហិរញ្ញប្បទានចំណាយរបស់ខ្លួនក្នុងការការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

នាពេលកន្លងមក ដោយគ្មានការបោះផ្សាយមូលបត្ររដ្ឋ រាជរដ្ឋាភិបាលមានការពឹងផ្អែកខ្លាំងលើកម្ចីពីខាងក្រៅ ដែលកាលនោះ ប្រភពហិរញ្ញវត្ថុខាងក្រៅនៅមានភាពទូលំទូលាយនិងអំណោយផល ជាអាទិ៍ លក្ខខណ្ឌអនុគ្រោះខ្ពស់ លក្ខណៈសម្បទាន និងអត្រាការប្រាក់ទាប។ ប៉ុន្តែក្នុងបរិការណ៍បច្ចុប្បន្ន មានបញ្ហាប្រឈមពីកត្តាខាងក្រៅ និងកត្តាខាងក្នុងមួយចំនួនដែលអាចបង្កឥទ្ធិពលជាយថាហេតុលើស្ថានភាពបំណុលសាធារណៈ បូករួមនឹងគោលបំណងនៃការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុ ជាពិសេសការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងដើម្បីជួយអភិវឌ្ឍទីផ្សារមូលបត្រនិងហិរញ្ញវត្ថុកម្ពុជា ធ្វើឱ្យការបោះផ្សាយមូលបត្ររដ្ឋ ដើម្បីកៀរគរទុនពីទីផ្សារមូលបត្រទាំងក្នុងនិងក្រៅប្រទេស បានក្លាយជាកាលានុវត្តភាព និងអាទិភាពថ្មីសម្រាប់កម្ពុជា។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំសេចក្តីព្រាងច្បាប់នេះដោយឈរលើមូលដ្ឋានបង្អែកនៃច្បាប់ស្តីពីមូលបត្ររដ្ឋ (ចាស់) ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ២០០៨ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ និងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩–២០២៣។

ដោយហេតុថាច្បាប់ថ្មីតម្រូវឱ្យមានការកែប្រែច្បាប់ចាស់ស្ទើរគ្រប់មាត្រា (ប្រហែល៩៥%) និងត្រូវលុបជំពូកមួយចំនួន និងថែមជំពូកថ្មី ដូច្នេះក្រសួងសាមីបានសម្រេចរៀបចំសេចក្តីព្រាងច្បាប់ថ្មីតែម្តង ដើម្បីនិរាករណ៍ច្បាប់ស្តីពីមូលបត្ររដ្ឋឆ្នាំ២០០៧ ដែលជាច្បាប់បម្រុងមិនទាន់បានអនុវត្ត។

ច្បាប់ស្តីពីមូលបត្ររដ្ឋ មានគោលបំណងកំណត់ក្របខណ្ឌរួមសម្រាប់គ្រប់គ្រងការបោះផ្សាយការជួញដូរ និងការគ្រប់គ្រងមូលបត្ររដ្ឋ ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ព្រមទាំងធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈសំដៅរួមចំណែកពង្រឹងការគ្រប់គ្រងតម្រូវការសាច់ប្រាក់របស់រាជរដ្ឋាភិបាលឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម អភិវឌ្ឍទីផ្សារមូលបត្រ និងទីផ្សារហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងគាំទ្រគម្រោងអាទិភាព និងចាំបាច់ផ្សេងទៀត។

សេចក្តីព្រាងច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះការបោះផ្សាយ ការជួញដូរ និងការគ្រប់គ្រងមូលបត្ររដ្ឋដែលបោះផ្សាយទាំងក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា។ការបោះផ្សាយមូលបត្ររដ្ឋជាសិទ្ធិអំណាចផ្តាច់មុខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨។

អត្ថប្រយោជន៍នៃច្បាប់ស្តីពីមូលបត្ររដ្ឋ គឺពិពិធកម្មប្រភពហិរញ្ញប្បទានគម្រោងអាទិភាពនានា ការកៀរគរទុនពីប្រភពក្នុងស្រុកនិងក្រៅប្រទេសមកបំពេញសេចក្តីត្រូវការ ជួយអភិវឌ្ឍទីផ្សារមូលបត្រ សម្របទៅតាមភាពរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា។លើសពីនេះមូលបត្ររដ្ឋនឹងដើរតួជាឧបករណ៍នៃគោលនយោបាយ

សារពើពន្ធផងនិងគោលនយោបាយរូបិយវត្ថុផងដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងធនាគារជាតិនៃកម្ពុជាអាចប្រើក្នុងការគ្រប់គ្រងស្ថានការណ៍ម៉ាក្រូសេដ្ឋកិច្ចរយៈពេលខ្លី។សេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ (ថ្មី) មាន៥ជំពូក និង ១៦មាត្រា៖

| | |
|---|---|
| – ជំពូកទី១ បទបញ្ញត្តិទូទៅ | មាន ០៣ មាត្រា |
| – ជំពូកទី២ ការបោះផ្សាយ និងការដាក់លក់មូលបត្ររដ្ឋ | មាន ០៩ មាត្រា |
| – ជំពូកទី៣ ទីផ្សារបន្ទាប់នៃមូលបត្ររដ្ឋ | មាន ០១ មាត្រា |
| – ជំពូកទី៤ ទោសប្បញ្ញត្តិ | មាន ០២ មាត្រា |
| – ជំពូកទី៥ អវសានប្បញ្ញត្តិ | មាន ០១ មាត្រា |

សេចក្តីព្រាងច្បាប់មូលបត្ររដ្ឋ គឺជាយន្តការនៃពិពិធកម្មប្រភពហិរញ្ញប្បទានដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិដោះស្រាយបញ្ហាប្រឈមពីកត្តាខាងក្រៅនិងកត្តាខាងក្នុងមួយចំនួននិងឆន្ទៈប្រែក្លាយកម្ពុជាពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នាពេលខាងមុខ៕

*ដោយ ម៉ម សារិទ្ធ - (ក.ស.វ. - ក្រុម ២)*

**គំនិតគួរចងចាំ**

« បានត្រូវមកពីស្គាល់ខុស បើមិនដូច្នោះទេ រកត្រូវពុំឃើញឡើយ។»

សម្តេចព្រះមហាសង្ឃរាជា ជួន ណាត ជោតញ្ញាណោ

## III- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ *



របាយការណ៍វិភាគនេះ ជាលទ្ធផលនៃកិច្ចប្រជុំចង្អៀតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ.) លើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃព្រហស្បតិ៍ ៥រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី **ឃឹម ឈុលឡា** ប្រធានក.ស.វ. ដែលសមាសភាពចូលរួម មានគណៈប្រតិបត្តិក.ស.វ. និងក្រុមការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយការរៀបចំរបាយការណ៍នេះដោយពឹងផ្អែកលើមូលដ្ឋានព័ត៌មាន ទិន្នន័យពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ដែលជាធាតុចូលផ្សេងៗទៀតពីថ្នាក់ដឹកនាំ ទីប្រឹក្សាបច្ចេកទេស សមាជិក សមាជិកានៃក.ស.វ. ក្រសួងស្ថាប័នពាក់ព័ន្ធ និងមន្ត្រីអគ្គលេខាធិការដ្ឋាននៃក.ស.វ. តាមប្រព័ន្ធតេលេក្រាម។

### ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➡ នាត្រីមាសទី៣ ឆ្នាំ២០២០ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៩% ធៀបនឹងត្រីមាសមុន និងកើនឡើង២,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
| ម្ហូបអាហារ | +៤,៥% | សាច់ជ្រូក | +១២,៧% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៤,៣% | ត្រីស្រស់ | +៧,២% |
| ភោជនីយដ្ឋាន | +៣,៦% | សាច់គោស្រស់ | +៣,៩% |
| ការសិក្សា | +៣,៥% | អង្ករ | +២,៦% |
| សំលៀកបំពាក់ និងស្បែកជើង | +២,៩% | ផ្លែឈើ | +២,៤% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | +១,៦% | សាច់មាន់ស្រស់ | +១,៧% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត | +១,២% | បន្លែ | +១,៥% |
| ការកម្សាន្ត និងវប្បធម៌ | +០,៥% | | |
| គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | +០,៤% | | |
| សុខាភិបាល | +០,២% | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.២. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមត្រីមាស ២០១៨–២០២០




តារាង១.៣. អត្រាប្តូរប្រាក់

| បរិយាយ | ត្រីមាសទី៣ ២០២០ | ត្រីមាសទី២ ២០២០ | ត្រីមាសទី៣ ២០១៩ | បរិយាយ | ត្រីមាសទី៣ ២០២០ | ត្រីមាសទី២ ២០២០ | ត្រីមាសទី៣ ២០១៩ |
|---|---|---|---|---|---|---|---|
| រ/ដុល្លារ | ៤ ១០០រ/$ | ៤ ០៩៣រ/$ | ៤ ០៩៥រ/$ | បាត/ដុល្លារ | ៣១,៦បាត/$ | ៣០,៩បាត/$ | ៣០,៦បាត/$ |
| រ/បាត | ១៣០រ/បាត | ១៣៣រ/បាត | ១៣៤រ/បាត | ដុង/ដុល្លារ | ២៣១៦៣ដុង/$ | ២៣ ១៧៥ដុង/$ | ២៣ ២០០ដុង/$ |
| រ/ដុង | ០,១៧៧រ/ដុង | ០,១៧៧រ/ដុង | ០,១៧៧រ/ដុង | យ៉ន់/ដុល្លារ | ៦,៨យ៉ន់/$ | ៧,១យ៉ន់/$ | ៧,១យ៉ន់/$ |

## ២. ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងត្រីមាសទី៣ ឆ្នាំ២០២០ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៨ ២០១៩ និង ២០២០ (ប៊ីលានរៀល)



**២.១. ចំណូលថវិកាជាតិ** ៖ អនុវត្តបាន ៥ ២២៥,០ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១ ៣០៦,២ លានដុល្លារ (*មធ្យមប្រចាំខែ ៨៥,៩%នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន ៤ ១៥០,១ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ១ ០៣៧,៥ លានដុល្លារ (*មធ្យមប្រចាំខែ ៦៩,៥% នៃផែនការ*) និងចំណូលមូលធនចំនួន ១០៧៤,៨ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ២៦៨,៧ លានដុល្លារ (*មធ្យមប្រចាំខែ ៩៦៩,៧% នៃផែនការ*) (តាមតួលេខ រតនាគារជាតិ)។

➢បើធៀបនឹងត្រីមាសមុនចំណូលថវិកាជាតិថយចុះ៨,៣%និងថយចុះ១៩,៣%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០១៩។

➢នៅក្នុងចំណូលចរន្ត៖

✓ចំណូលសារពើពន្ធមានចំនួន ៤ ៤២៣,១ ប៊ីលានរៀល ថយចុះ ២២,៥% ធៀបនឹងត្រីមាសមុននិងថយចុះ ២៧,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន (តាមតួលេខអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ)។ ចំណែកតាមតួលេខរតនាគារជាតិ ចំណូលសារពើពន្ធមានចំនួន ៣ ៨៨៦,៨ ប៊ីលានរៀលថយចុះ ២៥,៨% ធៀបនឹងត្រីមាសមុននិងថយចុះ ២៨,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន ២៦៣,៤ ប៊ីលានរៀលថយចុះ ១២,៧% ធៀបនឹងត្រីមាសមុន និង ថយចុះ ៧០,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តាមតួលេខរតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងរង្វង់ក្រចក ជាបម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងរង្វង់ក្រចក ជាបម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: :+០,៩% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (-៣៧,២%) | ➢អាជ្ញាបណ្ណក្នុងស្រុក : +១,៣% | (-៤០,៤%) |
| | | ➢ នេសាទ: -៦១,០% | (+១៥,២%) |
| ➢ ចំណូលពន្ធដារ: -៣៧,៨% (អគ្គនាយកដ្ឋានពន្ធដារ) | (-១២,៦%) | ➢សម្បទានរ៉ែ: -៣៥,០% | (-១០,៦%) |
| | | ➢អាកាសចរណ៍ស៊ីវិល: -៤៤,៩% | (-៨៨,៦%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: +១៤១,១% | (-៩៧,៧%) |

**២.២. ចំណាយថវិកាជាតិ** ៖ អនុវត្តបាន ៥ ០៦៤,៨ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១ ២៦៦,២ លានដុល្លារ(*មធ្យមប្រចាំខែ ៦៥% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៣ ៧១៩,២ ប៊ីលានរៀល (*មធ្យមប្រចាំខែ ៨២% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១ ៣៤៥,៦ ប៊ីលានរៀល (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៨ ២០១៩ និង២០២០

(ប៊ីលានរៀល)



➢ចំណាយថវិកាជាតិថយចុះ៣,៦% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៤,២%ធៀបនឹងត្រីមាសទី៣ឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ ៨,២% ធៀបនឹងត្រីមាសមុន និងថយចុះ ៧,៦% ធៀបនឹងត្រីមាសទី៣ឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាត្រីមាសទី៣នេះ មានអតិរេកចំនួន ១៦០,២ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៤០,០ លានដុល្លារ (តួលេខ រតនាគារជាតិ)។

## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងត្រីមាសទី៣ ឆ្នាំ២០២០មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន ១៣២ ៦១៣,៦ ប៊ីលានរៀលមានការកើនឡើង៦,៨%ធៀបនឹងខែមុននិងកើនឡើង ១៣,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង$M_2$** ក្នុងខែនេះ ជារួមបណ្តាលមកពី ការកើនឡើងនៃរូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ៤,៣% ប្រាក់បញ្ញើចរន្ត៦,៩% និងប្រាក់បញ្ញើផ្សេងទៀត៧,២%។




➢ក្នុងខែនេះ ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើមានចំនួន១៦,២% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,៨% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០២០

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅស្ថាប័នទទួលប្រាក់បញ្ញើ | ១៥,៦% | ១៥,៧% | ១៦,៤% | ១៦,៥% | ១៦,៤% | ១៦,២% | ១៦,២% | ១៦,២% | ១៦,២% | | | |
| រូបិយបណ្ណបរទេសនៅក្នុងធនាគារ | ៨៤,៤% | ៨៤,៣% | ៨៣,៦% | ៨៣,៥% | ៨៣,៦% | ៨៣,៨% | ៨៣,៨% | ៨៣,៨% | ៨៣,៤% | | | |

ក្រាហ្វ៣.២.បម្រែបម្រួលរូបិយវត្ថុក្នុងត្រីមាសទី៣ ឆ្នាំ២០២០ (ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)



តារាង៣.៣.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | ត្រីមាសទី៣ ២០២០ | ត្រីមាសទី២ ២០២០ | ត្រីមាសទី៣ ២០១៩ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ១១៩ ៥៣២,២ | ១១៤ ០៧៩,៥ | ១០១ ៤៤៥,៨ |
| ក្នុងនោះ ជារៀល | | ១២ ៩៣៥,៥ | ៧ ៧៥០,៦ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ២៩ ២២៥,៦ | ២៧ ៩៨៧,១ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៤,៧% | ៥,០% | ៤,៧% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៣,២% | ៣,៣% | ៣,៣% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១០,៩% | ៩,៧% | ៩,៩% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,០% | ៨,០% | ៨,១% |
| កម្ចីជារៀលនៅហត្ថកសិករ | ១៨,០% | ១៧,៨% | ១៨,០% |
| កម្ចីជារៀលនៅអម្រឹត | ១៧,៨% | ១៧,៨% | ១៨,០% |
| កម្ចីជារៀលនៅប្រាសាក់ | ១៦,០% | ១៥,០% | ១៦,០% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងវប្បធម៌

➡ក្នុងត្រីមាសទី៣ ឆ្នាំ២០២០ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន ២៧៩,៧ ពាន់តោនកើនឡើង៤៥,៨% ធៀបនឹងត្រីមាសមុននិង កើនឡើង៨,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣ ០០៦,១ GWh មានការថយចុះ៥,០% ធៀបនឹងត្រីមាសមុននិង ថយចុះ០,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះៈ

- អគ្គីសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ១ ៦៦៨,៣ GWh មានការកើនឡើង២២៤,៧% ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ១៧,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន ៧១៧,២ GWh មានការថយចុះ៤៤,២% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៣៣,៨%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDCមានចំនួន ៥២៨,៨ GWh មានការថយចុះ៥១,៣% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង៣៩,៩%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ៩១,៨ GWh មានការថយចុះ៦៦,៩% ធៀបនឹងត្រីមាសមុនប៉ុន្តែ កើនឡើង៩,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ផលិតកម្មស៊ីម៉ង់ត៍(មិនទាន់ទទួលបានតួលេខ)។

➢**ឧស្សាហកម្ម**:

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –ត្រីមាសទី៣ ២០២០ | ចំនួន–ត្រីមាសទី២ ២០២០ | ចំនួន–ត្រីមាសទី៣ ២០១៩ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៣៩ | ៧២ | ៧៦ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៨៥១ | ១ ៨៦១ | ១ ៦៨៦ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បើកថ្មី) | | | ៥ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | | ១៣ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៤ ៣១៤,៣ ពាន់ម២ មានការកើនឡើង៥០,៥% ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ២៨,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ២ ០២៥,៣ លានដុល្លារមានការកើនឡើង៥៩,៧% ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ៣៤,៧% បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំ មុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *ប្រភេទ* | *ពាន់ម២ — ត្រីមាសទី៣ ២០២០* | *ពាន់ម២ —ត្រីមាសទី២ ២០២០* | *ពាន់ម២ —ត្រីមាសទី៣ ២០១៩* |
|---|---|---|---|
| ▪ លំនៅឋាន | ១ ៦៦៩,៤ | ៩២៧,៤ | ២ ០៩៥,៦ |
| ▪ ឧស្សាហកម្ម | ៦៥៦,៥ | ៦២០,០ | ១ ១៧២,២ |
| ▪ពាណិជ្ជកម្ម | ១ ៦៤៣,៧ | ៨៥៧,៨ | ២ ១៨៧,៨ |
| ▪ ទេសចរណ៍ | ១២៨,១ | ១១៦,០ | ៤៧៣,៧ |
| ▪ផ្សេងៗ | ០,០ | ០,០ | ៦,៦ |
| អនុញ្ញាតសរុប | ៤ ៣១៤,៣ | ២ ៨៦៧,១ | ៥ ៩៩២,៧ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាត្រីមាសនេះគឺលំនៅដ្ឋាន៣៨,៧% និងពាណិជ្ជកម្ម៣៨,១% នៃផ្ទៃក្រឡាសរុប។

➢**សេវាកម្ម**

តារាង**៤.៣.**ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| *ប្រភេទ* | *ចំនួន —ត្រីមាសទី៣ ២០២០* | *ចំនួន—ត្រីមាសទី២ ២០២០* | *ចំនួន—ត្រីមាសទី៣ ២០១៩* |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១០៩៤ | ១ ២៥៦ | ២ ៦៨១ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១២៤ | ១០៣ | ២៧ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ១ ៨២១ | ១ ៥៨៨ | ៣ ២០៧ |

➢**ការងារ**

តារាង៤.៤. ការស្វែងរកការងារនិងទទួលបានការងារ

| *ប្រភេទ* | *នាក់—ត្រីមាសទី៣ ២០២០* | *នាក់—ត្រីមាសទី២ ២០២០* | *នាក់—ត្រីមាសទី៣ ២០១៩* |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ៦ ៤៨១ | ៤ ៩៧៨ | ៥ ៤១០ |
| អ្នកទទួលបានការងារធ្វើតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងទីភ្នាក់ងារជ្រើសរើសឯកជន | ៥៦ ៧៥៣ | ៥១ ៣៨៤ | ៥៥ ៣៧៩ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៥៦ ៧០៨ | ៤៩ ៨៧៥ | ៣៥ ៣៥៩ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៤៥ | ១ ៥០៩ | ២០ ០២០ |

## ➢វិនិយោគ

តារាង៤.៥.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ត្រីមាសទី៣ ២០២០ | ត្រីមាសទី២ ២០២០ | ត្រីមាសទី៣ ២០១៩ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៣ ៧៨៨,២ | ១ ៦២២,៧ | ១ ៤០៣,៤ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៣៤,២ | ៨១,៣ | ១៩,៩ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ១៩៩,០ (៣៣,០) | ៦១៨,៨ (៤០,៦) | ៤៥៤,៣ (២០៨,១) |
| វិស័យទេសចរណ៍ | ៣៥១៥,១ | ២០២,៤ | ៨០៥,៧ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៣៩,៩ | ៧២០,២ | ១២៣,៥ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៣៨ | ៨៨ | ៩១ |
| បង្កើតការងារ (ពាន់នាក់) | ២៦,៩ | ៤៩,២ | ៩១,៩ |

## ➢ទំនិញឆ្លងកាត់កំពង់ផែ(សរុប២កំពង់ផែ) មិនទាន់ទទួលបានតួលេខៈ

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)

| | |
|---|---|
| ▪ កំពង់ផែភ្នំពេញ:-១៤,៩% (-១៣,៤%) | ▪ កំពង់ផែកំពង់សោម:+១៥,៥% (+១,២%) |

## ➢ការចុះបញ្ជី និងចរាចរណ៍

តារាង៤.៧.ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ចំនួន – ត្រីមាសទី៣ ២០២០ | ចំនួន–ត្រីមាសទី២ ២០២០ | ចំនួន–ត្រីមាសទី៣ ២០១៩ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ៧០,៣ | ៧៩,៣ | ១១៨,៨ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ១៩,៩ | ២០,៣ | ២៨,៥ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍ (លើក) | ៨១១ | ៧០៣ | ៩៨៦ |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ២៤,១ | -១៨,៥% | -៦៤,២% |
| ក្នុងនោះទទួល | ៧,១ | -២០,៣% | -១៥,៦% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៥០,១ | +៥៦,៣% | -៧៩,១% |
| ក្នុងនោះទទួល | ៣៨,៦ | +២០,៣% | -៧៤,២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២ ៨២៥,៨ | -៧,៩% | -២៩,០% |
| ក្នុងនោះហៅចូល | ១ ១៨៨,៦ | -៦,៤% | -១៩,៤% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៨ ៨៤៨,៣ | +៣,៨% | -៣៩,៥% |
| ក្នុងនោះហៅចូល | ៨ ៦៥០,៦ | +៣,១% | -៤០,០% |

➢ **ការធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍**

តារាង៤.៨.អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| *ប្រភេទ* | *ចំនួន(ពាន់នាក់)* | *%Δ ធៀបនឹង ត្រីមាសមុន* | *%Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១,៤ | +៣៩១,៥% | -៩៥,៥% |
| ភ្ញៀវទេសចរបរទេសទិញប័ណ្ណទស្សនាអង្គរ | ៨,៤ | +១០១,១% | -៩៨,០% |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ៥៧,០ | +២៣០,៨% | +១៩៥,៤% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២,៧ | +១០៩,៦% | -៩៩,១% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ១០០,៧ | +៦០,៩% | -៩៦,០% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៦,៣ | +១២៤,៩% | -៩៨,៨% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៦៤,៩ | +១៣៥,០% | -៩៥,៦% |
| ✓ តាមផ្លូវអាកាស | ៣៦,៣ | +៨៩,១% | -៩៦,៥% |
| ✓ តាមផ្លូវគោក និងទឹក | ២៨,៥ | +២៤០,១% | -៩៣,៥% |

## ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ **ការនាំចូល**នាត្រីមាសទី៣ ឆ្នាំ២០២០ មានចំនួន ១៧ ៩២៧,៦ ប៊ីលានរៀល (ស្មើនឹង ៤ ៤៨១,៩ លានដុល្លារ ស.រ.អា.) កើនឡើង៣,៧% ធៀបនឹងត្រីមាសមុនប៉ុន្តែ ថយចុះ១៤,១%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +២,៥% | +៦,១% | រថយន្តសរុប (ប៊ី.ល.រ) | -០,៥% | -៤៩,២% |
| ប្រេងម៉ាស៊ូត | +១,៦% | +៨,៤% | រថយន្តសរុប (គ្រឿង) | +៦,១% | -៥៣,៩% |
| ឧស្ម័ន | +១៥,២% | -១៦,៦% | ត្រាក់ទ័រនិងគោយន្ត | -៣៣,៤% | -៣៤,២% |
| អគ្គិសនីនាំចូលដោយ EDC | -៥១,៣% | +៣៩,៩% | ម៉ូតូ (គ្រឿង) | | |
| ដែកសំណង់ | +១២៩,៥% | +៣៤,១% | អង្ករ | +២១២៤% | -២១,៣% |
| ស៊ីម៉ង់ត៍ | -៤៥,៦% | -៧៣,៣% | ផ្លែឈើនិងបន្លែ | +៧៧,៤% | +៨៦,៩% |
| គ្រឿងអេឡិចត្រូនិក | | | ថ្នាំកសិកម្ម | +៣១៧,៨% | +៥៥២,៥% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់ | +១៨,៤% | -៦,៥% |

➡**ការនាំចេញ** ត្រីមាសទី៣ឆ្នាំ២០២០ មានចំនួន **២២ ៩៤៩,៦**ប៊ីលានរៀល ស្មើនឹង **៥ ៧៣៧,៤**លានដុល្លារ ស.រ.អា. (**១២៨,០%** នៃការនាំចូល)កើនឡើង៣៤,៦% ធៀបនឹងត្រីមាសមុននិង កើនឡើង២៤,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| *ទំនិញ* | *%Δធៀបនឹងត្រីមាសមុន* | *%Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%Δធៀបនឹងត្រីមាសមុន* | *%Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១៥៨,៤% | +១១៤,១% | ផលិតផលនេសាទ | +៦,៧% | +២៧,៨% |
| វាយនភណ្ឌនិងស្បែកជើង | +៤៧,១% | -១០,៧% | កៅស៊ូ | +៩១,២% | +៥៤,៤% |
| អង្ករ | -៤៦,៤% | -២៥,០% | | | |

## ១- លក្ខខណ្ឌទ្រទ្រង់សេដ្ឋកិច្ចជប៉ុន

ឆ្នាំ១៨៦៨...! គឺជាឆ្នាំដែលព្រះចៅអធិរាជ មូជីហ៊ីតូ(Mutquihito) បានដណ្តើមយកអំណាចពីពួកសូងុន (Chogoun)ជាឆ្នាំដែលព្រះអង្គប្រកាសលុបរបបសក្តិភូមិហើយជាឆ្នាំដែលប្រទេសជប៉ុនត្រូវបានបើកចំហទ្វារយ៉ាងធំ ទទួលឥទ្ធិពលពីអឺរ៉ុប។ នេះជាទំព័រប្រវត្តិសាស្ត្រថ្មី ជាបដិវត្តន៍មួយសម្រាប់ជនជាតិមួយនៅទ្វីបអាស៊ី។

គួរជ្រាបថា មុនសម័យបដិវត្តនេះ ប្រទេសជប៉ុនឋិតនៅនៅក្រោមអំណាចរបស់មីខាដូ(Mikado) គឺព្រះចៅអធិរាជដែលជនជាតិជប៉ុនចាត់ទុកជាតំណាងអាទិភាពនៅលើផែនដីនេះ។ក៏ប៉ុន្តែជំនាន់ក្រោយមកទៀតអភិជនជប៉ុនម្នាក់បានទទួលលប់ចោលឋានន្តរសក្តិជាសូងុនគឺមេទ័ពហើយបានដណ្តើមយកអំណាចទាំងអស់ពីព្រះចៅអធិរាជមកកាន់កាប់បន្ទាប់ពីសូងុន មានពួកដៃមីយ៉ូ(Daimios) ជាស្តេចក្រាញ់ ដែលមានអំណាចត្រួតត្រាលើតំបន់នានាក្នុងប្រទេសជប៉ុន ដោយប្រើពួកសាមូរ៉ៃ(Samourais) ជាអ្នកការពារ។

រហូតមកដល់សព្វថ្ងៃនេះ ប្រទេសជប៉ុនក្លាយទៅជាមហាអំណាចសេដ្ឋកិច្ចលេខ៣ ក្រោយសហរដ្ឋ-អាមេរិកនិងចិន មានលក្ខខណ្ឌលប់ចោលជាច្រើនជាភស្តុតាងបញ្ជាក់នូវសន្ទុះដ៏ខ្លាំងក្លាក្នុងវិស័យសេដ្ឋកិច្ចនៃប្រទេសជប៉ុននេះ។

### ១-លក្ខខណ្ឌប្រវត្តិសាស្ត្រ

ក្នុងដំណើរដំបូងនៃការបដិវត្តន៍ ប្រទេសជប៉ុនបានបញ្ចូលលទ្ធិប្រជាធិបតេយ្យ បង្កើតច្បាប់រដ្ឋធម្មនុញ្ញតាមបែបប្រទេសព្រូស(Prusse) ប្រកាសសមភាពដល់ប្រជាពលរដ្ឋ បញ្ចូលកាតព្វកិច្ចសិក្សាក្នុងបឋមភូមិ រៀបចំកងទ័ពជើងទឹក ជើងគោក រៀបចំតុលាការ រៀបចំសេដ្ឋកិច្ច មានឧស្សាហកម្មជាដើម...។ល។ ក្នុងរយៈពេលដ៏ខ្លី ប្រទេសនេះក៏ក្លាយទៅជាមហាអំណាចមានការរីកចម្រើនលុតលាស់ទាន់ប្រទេសទាំងឡាយនៅទ្វីបអឺរ៉ុប។

### ១-១-កត្តាខាងប្រជាជននិងសេដ្ឋកិច្ច

កត្តាដែលនាំឱ្យសម័យមីអ៊ីយិ ទទួលនូវជោគជ័យនោះ គឺចំនួនប្រជាជនដែលបានកើតឡើងយ៉ាងឆាប់រហ័ស គឺពី៣៤លាន(១៨៧០) ទៅដល់៤៦លាន(១៩០៤)។ ក្រៅពីនេះ ក្នុងការស្តាបនាសេដ្ឋកិច្ចឱ្យមានសន្ទុះដ៏ខ្លាំងក្លា អាស្រ័យដោយរដ្ឋផ្ទេរគ្រឹះស្ថានឧស្សាហកម្មនានា ចាប់តាំងពីឆ្នាំ១៨៨០ឱ្យទៅគ្រួសារក្រុមហ៊ុនសំខាន់ៗក្នុងប្រទេសដូចតទៅ៖

-សហគ្រាស មិតជីអ៊ុ(Mitseui) ដែលនៅដើមសម័យមីអ៊ីយិជាធនាគារសម្រាប់អធិរាជជប៉ុន សម្រាប់ប្តូរក្រដាសប្រាក់ជំនាន់ដើម មកជាក្រដាសប្រាក់ថ្មី។ នៅពេលដែលរដ្ឋាភិបាលបានប្រគល់សហគ្រាសខ្លះមកឱ្យដឹកនាំក្រុមហ៊ុន មីតជីអ៊ី ក៏បានយករោងចក្រធ្វើសូត្រ ធ្វើអំបោះ ប្រដាប់ធ្វើអគ្គិសនី និងធ្វើក្រដាស។

-សហគ្រាសមីតជីប៊ីស៊ី ដែលបានកាន់កាប់ខាងនាវាចរណ៍ក្នុងឆ្នាំ១៨៧៥ និងខាងធនាគារដែរក្នុងឆ្នាំ១៨៩០។ ក្រុមហ៊ុននេះបានទទួលពីរដ្ឋនូវសហគ្រាសជាច្រើន ដូចជា អណ្តូងរ៉ែ សំណង់នាវា និងការធានារ៉ាប់រង។ ក្នុងឆ្នាំ១៨៨៩ គេបានទិញដីមួយកន្លែងជាបឹងបួរទំហំ៤០០.០០០ម² ចំពីមុខវាំងអធិរាជជប៉ុន ដែលគេមិនត្រូវការសោះនោះ។ ដីនេះសព្វថ្ងៃក្លាយទៅជាមជ្ឈមណ្ឌលនៃទីក្រុងតូក្យូ។

-សហគ្រាស ស៊ូមីតូម៉ូ Sumitomo ដែលពីដើមគ្រាន់តែជាអ្នកប្រកបអាជីវកម្មខាងសិប្បកម្មប៉ុណ្ណោះ។ ឆ្នាំ១៨៨៥ គេបានបង្កើតធនាគារមួយនៅអូសាកា Osaka ហើយបានទទួលកាន់កាប់ផ្នែកឧស្សាហកម្មខ្លះដែរ។

សហគ្រាសឯកជនទាំងនេះ រួមបញ្ចូលមកឱ្យឈ្មោះហៅថា សៃបាត់ជុ (Zaibatsus) មាននាទីសំខាន់ណាស់ក្នុងការត្រួតត្រាដំណើរនៃសេដ្ឋកិច្ចរបស់ប្រទេស។ក្នុងឆ្នាំ១៩៤០សហគ្រាសឯកជនទាំងនេះបានត្រួត

គ្រាសេដ្ឋកិច្ចជប៉ុនចំនួន ៦០% ដែលនាំប្រទេសទៅរកសង្គ្រាមវាតទីទឹកដីនេះឯង។

**១-២-នយោបាយអាណានិគម**

លុះបានចម្រើនខ្លាំងក្លាហើយជប៉ុនក៏បានអនុវត្តនយោបាយវាតទីទឹកដីដូចជាមហាអំណាចអាណានិគមនៅទ្វីបអឺរ៉ុបដែរ។

-នៅឆ្នាំ១៨៩៤-៩៥ជប៉ុនបានច្បាំងនឹងចិន ដើម្បីដណ្តើមយកប្រទេសកូរ៉េ។ ជ័យជំនះក្នុងសង្គ្រាមនេះបានអនុញ្ញាតជប៉ុនឱ្យដណ្តើមយកកោះតៃវ៉ាន់(Formose) កោះប៉េស្កាដ័រពីប្រទេសចិនថែមទៀត។

-នៅឆ្នាំ១៩០៤-០៥ ជប៉ុនបានធ្វើសង្គ្រាមជាមួយនឹងប្រទេសរុស្ស៊ីប្រកបដោយជោគជ័យទៀត។ តាមសន្ធិសញ្ញាមួយនៅ ផតស្មៅ Port Smouth ប្រទេសរុស្ស៊ីត្រូវថយចេញពីម៉ាន់ជូរី Mandchourie ហើយជប៉ុនត្រូវបានតំបន់លាវទុង Liao Tong ដោយមានកំពង់ផែអាធួ Arthur ផង ព្រមទាំងបានតំបន់សាខាលីន Sakha line ភាគខាងត្បូងថែមទៀត។

-នៅឆ្នាំ១៩១០ និងសម័យក្រោយសង្គ្រាមលោកលើកទី១ ជប៉ុនបានភ្ជាប់យកប្រទេសកូរ៉េនិងដែនដីសម្បទាន អាល្លឺម៉ង់ នៅចុងបូព៌ាជាច្រើន ដូចជា គាវចូវ កម្រងកោះម៉ារីយ៉ាន ការូលីន និងម៉ាកសាល។

-នៅឆ្នាំ១៩៣២ ប្រទេសជប៉ុនបានតាំងអាណាព្យាបាលរបស់ខ្លួនលើអាណាខេត្តម៉ាន់ជូរីដែលគេឱ្យឈ្មោះថា ម៉ានជូកូ ហើយដែលជាតំបន់មួយសំបូរទៅដោយដីមានជីជាតិនិងអណ្តូងរ៉ែផ្សេងៗជាច្រើន។ ក្នុងសង្គ្រាមពិភពលោកលើកទី២ គឺនៅថ្ងៃទី៧ ធ្នូ ១៩៤១ កងទ័ពជប៉ុនវាយលុកកំពង់ផែ Pear Habour ហើយមួយឆ្នាំក្រោយមកបានទន្ទ្រានរហូតដល់ឆ្នេរសមុទ្រចិន មហាសមុទ្រប៉ាស៊ីហ្វិក មហាសមុទ្រឥណ្ឌាទៀតផង... ប៉ុន្តែនៅថ្ងៃទី២កញ្ញា១៩៤៥ប្រទេសនេះបានខាតបង់ដែនដីទាំងនេះវិញហើយព្រមចុះចាញ់ក្នុងសង្គ្រាមដោយគ្មានលក្ខខណ្ឌផង។

**១-៣-កាកសាងឡើងវិញក្រោយសង្គ្រាម**

ក្រោយសង្គ្រាមរលត់នៅប្រទេសជប៉ុនបានបាត់បង់នូវដែនដីខាងក្រៅទាំងអស់ដែលជាប្រភពនៃធនធានអាហារនិងវត្ថុធាតុដើម មករួមនៅត្រឹមតែកោះបួន គឺកោះហុងដូ(Hondo) កោះហុកកៃដូ(Hokkaido) កោះគ្យូស៊ូ(Kuzshu) និងកោះស៊ីកុក(Sikok) កោះអូគីណាវ៉ា (Okinava) នៅជារបស់ជប៉ុនដដែល តែត្រូវអាមេរិកាំងយកទៅធ្វើជាមូលដ្ឋានសឹក តាមគោលការណ៍រហូតដល់ឆ្នាំ១៩៧២។ ក្រៅពីនេះសង្គ្រាមបានធ្វើឱ្យទាហានស្លាប់ ១,៥លាននាក់ និងស៊ីវិលស្លាប់ ៦៩០.០០០នាក់ ឧស្សាហកម្មនិងរោងចក្រថាមពល ៣០% រោងចក្រចម្រាញ់ប្រេង ៥៨% និងកប៉ាល់ម៉ារីន ៨០% បានត្រូវខូចខ្ទេចខ្ទី រីឯទីក្រុងចំនួន៤០%ក៏ត្រូវបំផ្លាញដោយសារទម្លាក់គ្រាប់បែកដែរ ពិសេសគឺក្រុងហ៊ីរ៉ូស៊ីម៉ា(Hiroshima) និងក្រុងណាហ្គាសាគី(NagasaKi) ដោយគ្រាប់បែកបរមាណូចំនួនពីរគ្រាប់។

ចាប់តាំងពីខែសីហា១៩៤៥ រហូតដល់ឆ្នាំ១៩៥០ ប្រទេសជប៉ុនត្រូវស្ថិតនៅក្រោមកិច្ចត្រួតត្រារបស់កងទ័ពអាមេរិកាំង។រដ្ឋធម្មនុញ្ញថ្មីមួយបែបអាមេរិកាំងត្រូវប្រកាសឡើងនៅថ្ងៃនៅថ្ងៃទី០៣កញ្ញា១៩៤៦ដែលធ្វើប្រទេសជប៉ុនឱ្យទៅជារដ្ឋប្រជាធិបតេយ្យសភា ឯព្រះចៅអធិរាជគ្រាន់តែនិមិត្តរូបនៃរដ្ឋ និងឯករាជ្យជាតិប៉ុណ្ណោះ។ សហគ្រាសធំសៃបាត់ជុ ត្រូវបានបញ្ឈប់សកម្មភាព។ មានបង្កើតគោលការណ៍កែទម្រង់ក្នុងវិស័យកសិកម្មដែរ។ ពួកធនាគារអាមេរិកាំងនៅស៊ីកាហ្គោ(Chicago) បានចេញមកជួយរៀបចំឱ្យប្រសើរឡើងវិញក្នុងបញ្ហាវិបត្តិហិរញ្ញវត្ថុ និងវិបត្តិបោះពុម្ពក្រដាសប្រាក់ច្រើនហួសហេតុ(Inflation)។

ក្រោយថ្ងៃទី៨ សីហា ១៩៥១ ប្រទេសជប៉ុនបានទទួលឯករាជ្យពេញលេញ។ ចាប់ពីពេលនោះមកសកម្មភាពខាងសេដ្ឋកិច្ចក៏ចាប់មានសន្ទុះឡើងវិញប្រកបដោយលទ្ធផលជាក់ស្តែង។គេបានអនុវត្តនយោបាយថ្មីចំពោះប្រទេសចិនដីគោក។ សហរដ្ឋអាមេរិកបានបញ្ឈប់ឱ្យសងការជួសជុល បន្ធូរច្បាប់ប្រឆាំងនឹងត្រឹស(Trust) ព្រមទាំងឱ្យជប៉ុនខ្ចីប្រាក់សម្រាប់ជួសជុលកសាងឡើងវិញផង។

សង្គ្រាមនៅកូរ៉េឆ្នាំ១៩៥៣ ពិសេសថ្មីៗនេះសង្គ្រាមនៅឥណ្ឌូចិនពីឆ្នាំ១៩៥៥ បានជំរុញឱ្យអាមេរិកាំងយកជប៉ុនជាមូលដ្ឋានជួរមុខគេដោយបានឧបត្ថម្ភឱ្យកសាងឧស្សាហកម្មសម្រាប់ជួសជុលសម្ភារៈខូចខាតក្នុងសង្គ្រាម។ ដូចនេះឧស្សាហកម្មក៏ចាប់ផ្តើមងើបឡើងវិញហើយសហគ្រាសសៃបាត់ជុក៏ចាប់មានសកម្មភាពឡើងវិញដែរ ដោយសហរដ្ឋអាមេរិកបានទាំងទទួលផ្តល់ប្រាក់ចំនួន ១០០លានដុល្លារក្នុងមួយឆ្នាំៗផង។

ដូចនេះដំណើរដ៏ប្រសើរបានរកឃើញហើយ ប៉ុន្តែប្រទេសជប៉ុនបានជួបប្រទះនឹងលក្ខខណ្ឌធម្មជាតិដ៏លំបាកមិនសូវសមស្រប( Défavorable ) ឡើយ។

**២-លក្ខខណ្ឌធម្មជាតិ**

ប្រទេសជប៉ុនជាប្រទេសតូច( ៣៨០.០០០គម២ ) ធំជាងប្រទេសខ្មែរពីរដង ប្រកបដោយភ្នំ និងភ្នំភ្លើងជាច្រើន ហើយមានប្រជាជនរស់នៅចំនួន១០៣លាននាក់ច្រើនជាងប្រទេសខ្មែរ១២ដង។ផ្ទៃដីមានទំហំតូចនៅចំពោះចំនួនប្រជាជនដ៏ច្រើនយ៉ាងនេះ ជាហេតុធ្វើឱ្យបញ្ហាចិញ្ចឹមជីវិតកាន់តែចោទខ្លាំងឡើងៗ។

**២-១-បញ្ហាកសិកម្ម**

-បញ្ហានេះស្ថិតនៅលើផ្ទៃដីដែលដាំដំណាំបានចំនួនតិចគឺ ១៤,៨% នៃផ្ទៃដីទាំងអស់ ក្រៅពីនេះមានព្រៃឈើចំនួន៦៧,៥%វាលស្មៅសម្រាប់ចិញ្ចឹមសត្វចំនួន៣,៦%រីឯផ្ទៃដីដែលមិនអាចដាំដំណាំបាននោះមានចំនួន ១៣,៨%នៃផ្ទៃដីទាំងអស់។

ដោយចំនួនផ្ទៃក្រឡាដីដាំដំណាំមានចំនួនតិចបែបនេះហើយបានជាកម្មសិទ្ធិដីនៃគ្រួសារជប៉ុនបែងចែកគ្នាជាផ្នែកតូចៗដ៏ច្រើនលើសលប់។ កម្មសិទ្ធិដែលមានតិចជាង ០,៥ហិកតា មានចំនួនទៅដល់ ៣៦,៣% ពី០,៥ទៅ១ហិកតាមានចំនួន ៣០,៣% និងពី១ហិកតាទៅ២ហិកតាមានចំនួន ២៥,៤%។ ដើម្បីបង្កើនចំនួនដីដាំដំណាំជនជាតិជប៉ុនបានសាកល្បងទន្ទ្រានដីទៅក្នុងទឹកដូចជានៅច្រកសមុទ្រតូចៗឬទៅលើភ្នំទាបៗបង្កើតជាថ្នាក់ៗ( ៣០០.០០០ហិកតាក្នុងឆ្នាំ១៩៦៦ )។ការបាចទឹកបញ្ចូលស្រែបានអនុវត្តតាំងពីមជ្ឈឹមសម័យហើយសព្វថ្ងៃនេះផ្ទៃដីចំនួន ៥០% នៃផ្ទៃដីដាំដំណាំសុទ្ធតែត្រូវប្រើដោយវិធីបាចទឹកនេះ។ ដើម្បីថែរក្សាដី ដូចជាការថែទាំសួនច្បារដូច្នោះដែរនោះ កសិករជប៉ុនប្រើម៉ាស៊ីនដាំដំណាំ( Monocuteurs ) តូចៗជាច្រើន ( ៣លានគ្រឿង ) ហើយប្រើប្រាស់គីមីច្រើនបំផុត គឺលេខ២ក្នុងពិភពលោក ក្រោយប្រទេសប៉េអ៊ីបា Pays Bas ( ១៩៦៧ )។ ដូចនេះហើយបានជាអ្នកស្រែជប៉ុនអាចយកផលស្រូវបាន ២ដងក្នុងមួយឆ្នាំគឺ ពី៤ឬ៥តោនក្នុង១ហិកតា។

ប៉ុន្តែការប្រកបកសិកម្មបែបខាងលើនេះ អាចធ្វើឱ្យដីខ្សោយច្រើនកន្លែងយ៉ាងឆាប់រហ័ស។ ម្យ៉ាងទៀតមានកត្តាមួយចំនួនទៀតដែលជាចំណោទចំពោះជនបទជប៉ុននោះការលូតលាស់យ៉ាងខ្លាំងក្លាខាងឧស្សាហកម្មជាហេតុធ្វើឱ្យប្រជាជនសកម្មខាងកសិកម្មថយចុះពីចំនួន ៥៧% ក្នុងឆ្នាំ១៩៣៨ ទៅ១៩,៣%ក្នុងឆ្នាំ១៩៦៨។ រីឯប្រជាជនជនបទក៏មានចំនួនតិចដែរគឺមានចំនួន ២៩% នៃប្រជាជនទាំងអស់( ១៩៦៨ )។

លទ្ធផលឃើញថា ផលិតផលកសិកម្មមានស្រូវ( ១៨,៨លានតោនក្នុងឆ្នាំ១៩៦៨ លេខ៤ ) ស្រូវសាឡីតែ( លេខ៤ ) ស្ករ ថ្នាំជក់ សូត្រ និងផលិតផលនេសាទ( ៧,២លានតោន លេខ២ ) សុទ្ធតែត្រូវចាត់ថ្នាក់ដ៏ប្រសើរក្នុងពិភពលោក ប៉ុន្តែផលិតផលនេះ មិនអាចមានចំនួនគ្រប់គ្រាន់នឹងសេចក្តីត្រូវការនៃជនជាតិជប៉ុនឡើយដូចនេះហើយបានជាប្រទេសជប៉ុនត្រូវនាំចូលមកក្នុងប្រទេសនូវផលិតផលប្រភេទនេះជាច្រើន។

**២-២-បញ្ហាធនធានក្រោមដី**

-ប្រទេសជប៉ុនមិនសូវសំបូរធនធានធម្មជាតិក្រោមដីទេ។ ជប៉ុនមានត្បូងថ្មដែរ( ៤៦,៤លានតោន ក្នុងឆ្នាំ១៩៦៩ ) ប៉ុន្តែពិបាកជីកយក ហើយគុណភាពពុំសូវល្អប៉ុន្មាន រីឯត្បូងថ្មកុក( Charbon à Coke ) សម្រាប់ប្រើក្នុងការស្លដែកនោះ ត្រូវប្រទេសជប៉ុនទិញយកពីសហរដ្ឋអាមេរិកចំនួន៣៥លានតោន។ ប្រេងកាតក៏ខ្វះច្រើនណាស់ដែរ( ៨០០.០០០តោន )ត្រូវទិញមកពីប្រទេសក្រៅចំនួន១៤១,៥លានតោន។ ធនធានដែករិតតែមានចំនួនតិចណាស់ទៅទៀតដែលត្រូវឱ្យជប៉ុនទិញរ៉ែដែក កម្ទេចដែកពីបរទេសចំនួន៩០%នៃសេចក្តីត្រូវការទាំង

អស់។ ម៉ង់កាណែ(Monganèse) ត្រូវនាំចូលពីប្រទេសឥណ្ឌានិងសហភាពសូវៀតចំនួន៣៦១.០០០តោន។ ក្រៅពីនេះមានស្ពាន់ធរ(១,៩លានតោនក្នុងឆ្នាំ១៩៦៧) និងអគ្គិសនី(២៦៥.០០០លានKmh លេខ៣ ក្នុងនោះមានចំនួន៦៩,៧% បានមកពីវារីអគ្គិសនី) ដែលអាចផ្គត់ផ្គង់សម្រាប់សេចក្ដីត្រូវការក្នុងស្រុកបាន។

**២-២-បញ្ហាប្រជាគណាន៍(Problème démographique)**

-បញ្ហាប្រជាគណាន៍ចោទខ្លាំងបំផុតនៅប្រទេសជប៉ុន ព្រោះប្រជាជនកើនចំនួនច្រើនរហ័សពេក ចាប់ពីចុងសតវត្សទី១៩មក។ ប៉ុន្តែសព្វថ្ងៃមានច្បាប់មួយ ថ្ងៃទី១៣ កក្កដា ១៩៤៨ បានកម្រិតចំនួនកំណើនកូនក្មេងធ្វើឱ្យអត្រាកំណើនប្រជាជនថយចុះមកនៅត្រឹមចំនួន១២ឬ១៣ភាគពាន់។

ក្នុងបណ្ដាប្រជាជនទាំងមូល ប្រជាជនក្រុងកើនឡើងច្រើនជាងគេ(ប្រជាជនក្រុងមានចំនួន៧០%នៃប្រជាជនទាំងអស់ក្នុងឆ្នាំ១៩៦៩)។ ក្នុងចំណោមមនុស្ស១០៣លាននាក់ មានពាក់កណ្ដាលរស់នៅលើផ្ទៃដីតែ១,៣%នៃផ្ទៃដីទាំងអស់ពិសេសនៅតំបន់ឆ្នេរសមុទ្រពីតូក្យូទៅអូសាកាចម្ងាយតែ៦០០គ.មប៉ុណ្ណោះ។ទីក្រុងធំៗនៅក្នុងតំបន់នោះមានចំនួនមនុស្សលើសពី១លាននាក់ ដូចជាទីក្រុងតូក្យូ(១១លាន) យូកូហាម៉ា(១,៩លាន) ណាហ្គូយ៉ា(១,៩៥លាន) ក្យូតូ(១,៤លាន) កូបេ(១,២លាន) និងអូសាកា(២,២លាន)។

ក្នុងឆ្នាំ១៩៦៨ប្រជាជនសកម្មនៃប្រទេសជប៉ុនមានចំនួន១៩,៥%ក្នុងមណ្ឌលទី១(កសិកម្ម-នេសាទ) ៣៣,៦% ក្នុងមណ្ឌលទី២(រ៉ែ-ឧស្សាហកម្ម) និង៤៦% ក្នុងមណ្ឌលទី៣(ពាណិជ្ជកម្មនិងអ្នករដ្ឋការ)។

រួមសេចក្ដីមក លក្ខខណ្ឌធម្មជាតិមិនសូវប្រកប(défavorable) ក្នុងការទ្រទ្រង់សេដ្ឋកិច្ចជាតិទេ។ តែទោះជាយ៉ាងណាក៏ដោយបច្ចុប្បន្ននេះប្រទេសជប៉ុនក្លាយទៅជាមហាអំណាចពិភពលោកលេខ៣ទៅហើយ។ ប្រការនេះកើតឡើងអាស្រ័យលក្ខខណ្ឌផ្សេងៗទៀតពោលគឺក្រុមហ៊ុនឯកជនដ៏ខ្លាំងពូកែលក្ខណៈមនុស្សជប៉ុនស្វាហាប់ និងបច្ចេកវិទ្យាដ៏ខ្ពង់ខ្ពស់នោះឯង។

**៣-លក្ខខណ្ឌជោគជ័យនៃសេដ្ឋកិច្ចជប៉ុន**

សម្ទុះនៃសេដ្ឋកិច្ចជប៉ុនស្ថិតនៅលើគំនិតខួរក្បាលនៃជនជាតិជប៉ុននេះតែម្ដងដោយបានដឹកនាំនយោបាយសេដ្ឋកិច្ចមួយដ៏ច្បាស់លាស់ប្រកបដោយបច្ចេកវិទ្យាខ្ពស់បំផុត។

**៣-១-ក្រុមហ៊ុនឯកជនដ៏ខ្លាំងពូកែ**

-ក្នុងការដឹកនាំសេដ្ឋកិច្ច រដ្ឋបានចូលធ្វើអន្តរាគមដែរ តែមានលក្ខណៈទន់ភ្លន់ច្រើន។ ដង្ហើមរបស់សេដ្ឋកិច្ចពិតប្រាកដ គឺស្ថិតនៅលើកណ្ដាប់ដៃតែក្រុមហ៊ុនគ្រួសារជប៉ុន៤ឬ៥នាក់ប៉ុណ្ណោះ ប៉ុន្តែមានការប្រមូលផ្ដុំគ្នារវាងរដ្ឋ ធនាគារនិងក្រុមហ៊ុនសៃបាត់ជុយ៉ាងជិតស្និទ្ធដែរ។

ក្រោយសង្គ្រាមលោកលើកទី២បន្តិចផ្សារហិរញ្ញវត្ថុបានត្រូវរប៉ាត់រប៉ាយអស់គ្មានសល់។នៅចំពោះមុខការអត្តខាត់ខាងដើមទុនបែបនេះ(Pénurie Capitaux) សហគ្រាសទាំងឡាយបានពឹងផ្អែកលើធនាគារវិញព្រោះធនាគារនេះជាអ្នកបើកឱ្យខ្ចីប្រាក់ប៉ុន្តែដើម្បីរត់តាមឱ្យទាន់ការលូតលាស់ខាងសេដ្ឋកិច្ចធនាគារទាំងឡាយបានពឹងទៅលើរដ្ឋជាធំដែរ។ ដូចនេះហើយបានជាគេឃើញមានដើម្បីទុនឧស្សាហកម្មចំនួន៨០% បានមកពីធនាគារទាំងអស់។ គឺក្នុងការរៀបចំបែបនេះហើយ បានជាគេបើកឱ្យសហគ្រាសសៃបាត់ជុកើតឡើងវិញ។

សហគ្រាសសៃបាត់ជុ មិនមែនជាត្រឹស(Trust) ឬកាតែល(Cartels)(១)ទេ។ តែជាការប្រមូលផ្ដុំនៃសហគ្រាសនានា ដោយមាននយោបាយតែមួយដូចគ្នា ហើយមានធនាគារផ្ទាល់ខ្លួនផង។ ក្នុងឆ្នាំ១៩៦៩ មានធនាគារបីនៅប្រទេសជប៉ុន សំខាន់ៗដែលបានជាប់លេខប្រសើរក្នុងបណ្ដាធនាគារពិភពលោកទាំងឡាយដូចជាធនាគារ Fuji លេខ១០ Sumimoto លេខ១១ និង Mitsubishi លេខ១៧ រីឯBourse នៅតូក្យូបានជាប់លេខមួយក្នុងពិភពលោកដែរ។ប្រទេសជប៉ុនធ្វើវិនិយោគនៅបរទេសច្រើនជាងបរទេសធ្វើវិនិយោគក្នុងប្រទេសខ្លួន។ចំពោះសហរដ្ឋអាមេរិកមានដើមទុនធ្វើវិនិយោគសម្រាប់ឧស្សាហកម្មនៅប្រទេសជប៉ុនតែ២%(១៩៦៩) ទេ ដូចនេះជប៉ុនបានខិតខំបន្ថយចំនួនវិនិយោគបរទេសជាច្រើន។

### ៣-២-មនុស្សជប៉ុន

-ក្រុមកម្មករជប៉ុនមានចំនួនច្រើនជាអ្នកព្យាយាមឧស្សាហ៍ធ្វើការបំផុតហើយពុំសូវទាមទារប្រាក់បៀវត្ស ច្រើនប៉ុន្មានទេ។ គេសង្កេតឃើញមិនសូវមានកម្មករទាំងនោះសុំច្បាប់ឈប់លំហែ ជាហេតុបណ្តាលឱ្យកើន ផលិតផលជាតិដល់ទៅ៨%ក្នុងមួយឆ្នាំ។ សហជីពកម្មករក៏បានបង្កើតឡើងក្នុងរង្វង់សហគ្រាស ដើម្បីការពារ ផលប្រយោជន៍កម្មករ ជាហេតុមិនសូវមានទំនាស់រវាងកម្មករនិងម្ចាស់រោងចក្រប៉ុន្មានទេ។

ជនជាតិជប៉ុនច្រើនមានគំនិតសន្សំ(esprit d'épargne) អ្នកធ្វើការ(Salarié) ជប៉ុនដាក់ប្រាក់សន្សំ ចំនួន២០%នៃផលទុនរបស់គេក្នុងធនាគារក្រោយពីបានបង់ពន្ធជូនរដ្ឋការមក។ប្រាក់សន្សំទាំងនេះនឹងចូលទៅ ក្នុងចលនាវិលវង់នៃសេដ្ឋកិច្ចដែរ។ចំនួនអ្នករដ្ឋការតិចណាស់គឺគេកម្រិតត្រឹមតែ១,៣លាននាក់ដោយគិតទាំង ទាហានផង។មនុស្សជប៉ុនដឹកនាំការខំប្រឹងប្រែងរបស់ខ្លួនទៅលើការលូតលាស់ខាងសេដ្ឋកិច្ចជានិច្ចហើយនិង ចង់បង្ហាញពិភពលោកថាប្រទេសជប៉ុនអាចទៅជាមហាអំណាចពិភពលោកបានដោយមិនបាច់មានគ្រាប់បែក បរមាណូ។

ការសិក្សារៀនសូត្រនៃប្រជាពលរដ្ឋនីមួយៗមានកម្រិតខ្ពស់ណាស់។អត្រាចំនួនមនុស្សចេះអក្សរមាន ដល់ទៅ៩៨%។ ក្នុងឆ្នាំ១៩៦៧ មានកូនក្មេងដល់អាយុ១៧ឆ្នាំចំនួន៧០% បានចូលរៀនក្នុងសាលា ហើយ និង១៦%បានសិក្សាក្នុងសាលាជាន់ខ្ពស់។ ដូច្នោះហើយបានជាអ្នកធ្វើការជាតិជប៉ុនមានវិជ្ជាសម្បត្តិខ្ពស់។ ចំណែកទំនាក់ទំនងរវាងសហគ្រាសនិងសកលវិទ្យាល័យក៏មានលក្ខណៈជិតស្និទ្ធណាស់ដែរ។ក្នុងពេលថ្មីៗនេះ រដ្ឋាភិបាលបានបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រមួយនៅលើភ្នំស៊ូគូបា(Tsukuba) ចម្ងាយ៥០គ.ម ពីទីក្រុងតូក្យូ ដោយអាចទទួលបានមនុស្សចំនួន១៦០.០០០នាក់ ទៅសិក្សារៀនសូត្រ។ សារព័ត៌មានត្រូវគេ ទទួលស្គាល់ថា មានការលូត់លាស់ច្រើនណាស់ ក្នុងមួយថ្ងៃៗអាចចេញផ្សាយបានដល់ទៅ ៣០លានច្បាប់ គ្រាន់តែកាសែតអាសាហ៊ី(Asahi) តែឯងចេញក្នុងមួយថ្ងៃ១០លានច្បាប់ទៅហើយ។ ចំពោះទូរទស្សន៍វិញ គ្រួសារជប៉ុនចំនួន៩៥%មានទូរទស្សន៍ប្រើម្នាក់មួយៗ។

### ៤-បច្ចេកវិទ្យាជប៉ុន

-ក្នុងឆ្នាំ១៩៦៦ ជប៉ុនមានសហគ្រាសចំនួន៣.៦២២ ដែលកម្មករលើស៣០០នាក់ និងមានចំនួន ៤២លានដែលប្រើកម្មករតិចជាង៣០០នាក់ក្នុងចំនួននេះមាន៣០៤ជាសហគ្រាសប៉េកអឺរ៉ុប(សហរដ្ឋអាមេរិក មានចំនួនសហគ្រាស១៨៩នៅជប៉ុន)។ឧស្សាហកម្មជប៉ុនច្រើនប្រមូលផ្តុំតាមទីក្រុង ដូចជានៅតាមតំបន់ឆ្នេរ សមុទ្រពីតូក្យូទៅអូសាកាជាដើម(៨៦%នៃតម្លៃផលិតផលឧស្សាហកម្មទាំងអស់)បច្ចេកទេសក្នុងការផលិត វត្ថុប្រើប្រាស់មានគុណភាពហើយច្រើនបែបច្រើនយ៉ាង ថ្វីត្បិតតែជប៉ុនមិនសូវសំបូររ៉ែដែក ធ្យូងថ្ម ជាធម្មជាតិ ក៏ដោយ។

បច្ចេកទេសខ្ពស់ជាងគឺការផលិតដែកថែប ប្រើអុកស៊ីហ្សែន(acier à oxygène) ដែលជាប់លេខ១ក្នុង ពិភពលោក។ ក្នុងឆ្នាំ១៩៦៩ ជប៉ុនស្ថាបនាឡស្លដែកមួយធំជាងគេក្នុងពិភពលោកចំណុះ២.៩២៥ម៣។ រោងចក្រទាំងឡាយត្រូវប្រមូលផ្តុំគ្នាយ៉ាងមាំ(Fort concentration) ដែលក្រុមហ៊ុនជាច្រើនចូលប្រឡូកក្នុង ការផលិតដែកថែបនេះNipponKokauនិងSumimotoMetalIndustries។ឧស្សាហកម្មប្រភេទនេះច្រើនតាំងនៅ ជិតឆ្នេរសមុទ្រព្រោះស្រួលនាំចូលនូវរ៉ែនិងធ្យូងថ្មមកពីបរទេស។ផលិតផលដែកថែបកើនឡើងពីចំនួន៣២លាន (១៩៦០) ទៅ៨២,១លានតោន(១៩៦៩) លេខ៣ ក្នុងពិភពលោក ព្រមទាំងបាននាំចេញទៅបរទេសចំនួន ១៦លានតោនផង។

ក្នុងការស្ថាបនាកប៉ាល់បច្ចេកទេសរបស់ជប៉ុនក៏ខ្ពស់ណាស់ដែរព្រោះអាស្រ័យទៅដោយសនិទានកម្ម (Nationalisation) និងវិធីផលិតគំរូតែមួយ(Standardisation) ជាហេតុបណ្តាឱ្យតម្លៃដើមថោកច្រើន ណាស់។ជប៉ុនកំពុងស្ថាបនានាវាប្រេងកាតមួយចំណុះ៤៥៥.០០០តោនដែលត្រូវចេញឱ្យប្រើក្នុងឆ្នាំ១៩៧២។ ឧស្សាហកម្មនាវាសំខាន់ៗបីគឺ Ishihawajim Harima, Mitsubishi Heary Industrie និង Mitsui ដោយបាន ផលិតចំនួននាវាទាំងអស់ចំណុះ៨,២៨លានតោន ប្រមាណ៤៨%នៃផលិតកម្មពិភពលោក។

បើនិយាយពីការស្ថាបនារថយន្តវិញ ប្រទេសជប៉ុនបានជាប់លេខ២ នៅក្នុងពិភពលោកគឺចំនួន ៤.៦៧៤.០០០គ្រឿងក្នុងឆ្នាំ១៩៦៩។ ឧស្សាហកម្មរថយន្តប្រមូលផ្តុំគ្នា២ឬ៣ប៉ុណ្ណោះគឺក្រុមហ៊ុនToyota (៣៧,៩%)នៃផលិតកម្មទាំងអស់ Nissan (២៥,៣%) និងI.M.F(១៤,៥%)។ ចំនួនអ្នកប្រើប្រាស់រថយន្តឡើងខ្ពស់ដល់៤៣,២% ហើយការនាំចេញក៏ឡើងដល់១៨,៣%នៃផលិតផលដែរ(១៩៦៩) ជាហេតុធ្វើឱ្យប្រទេសក្រៅបារម្ភយ៉ាងខ្លាំងចំពោះសម្ពុះនៃរថយន្តជប៉ុននៅផ្សារបរទេស។ បើចាប់ពីទោចក្រក្រយានយន្ត (Honda) ត្រីចក្រក្រយានយន្តវិញជប៉ុនមានចំនួនច្រើនលើសលប់(លេខ១)។

បន្ថែមពីនេះ គឺបច្ចេកទេសផលិតគ្រឿងអគ្គិសនី និងអេឡិកត្រូនិក ដូចជា ទូរទស្សន៍មានពណ៌ (២,៥៥លានគ្រឿងក្នុងឆ្នាំ១៩៦៩) និងប្រដាប់Ordinateur(លេខ៣)។ មានក្រុមហ៊ុនធំៗបួនដែលមាននាទីក្នុងការផលិតគ្រឿងប្រដាប់ទាំងអស់នេះ ដូចជា Nippon Electric(៤៥%) Fujitaui(១៥%) Hitachi(១៤%) O.K.I.Electric Industry (៩%) ទីបំផុតគឺការស្ថាបនាផ្លូវគមនាគមន៍និងទីក្រុងដែលមានការប្រែប្រួលយ៉ាងឆាប់រហ័សពីមួយឆ្នាំទៅមួយឆ្នាំ។ ទីក្រុងធំៗពិសេសទីក្រុងតូក្យូត្រូវសង់ឡើងទៅលើអាកាសជាផ្ទះច្រើនជាន់ (gratte.ciel) ដោយប្រទេសជប៉ុនរកឃើញបច្ចេកទេសថ្មីក្នុងការស្ថាបនាសំណង់ការពារនឹងការរញ្ជួយដី (anti-sismique) និងស្ពានថ្នល់ធំៗសម្រាប់រថយន្ត(autoroutes aériennes)។ មិនតែប៉ុណ្ណោះ ទីក្រុងមានសង់បន្តទៅក្រោមដីទៀត ដោយប្រើផ្លូវម៉េត្រូ(métro) ជាច្រើន។ មានរថភ្លើងឈ្មោះ Toakaido បើកពីតូក្យូទៅអូសាកាចម្ងាយ៥៥០គ.ម. តែក្នុងរយៈពេល៣ម៉ោង២០នាទី ដោយដឹកនាំអ្នកដំណើររាប់ពាន់នាក់ក្នុងមួយថ្ងៃ។ រោងចក្រខ្លះត្រូវសង់នៅលើទឹក ដោយប្រើសសរបង្គោលបេតុង។

នៅប្រទេសជប៉ុន សមាគមឧស្សាហកម្មមិនចូលឡាយលំក្នុងការលក់ផលិតផលទេ គឺមានក្រុមហ៊ុនពាណិជ្ជកម្មដែលមានឯកទេសផ្សេងៗសម្រាប់ទទួលនាំចេញ ទោះនៅក្នុងផ្នែរាបក្នុងប្រទេសក៏ដូចជាផ្នែរាបអន្តរជាតិដែរ ដូចជាក្រុមហ៊ុន Mitsubishi(លេខ១) Mitsui(លេខ២) Sumitonai(លេខ៦)។ បច្ចុប្បន្ននេះប្រទេសជប៉ុនជាប់លេខ៤ ក្នុងសកលលោក អាស្រ័យដោយសារកងនាវាចរណ៍យ៉ាងសំខាន់។

លក្ខខណ្ឌសំខាន់ៗដូចបានពោលមកខាងដើមនេះបញ្ជាឱ្យឃើញនូវវិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចមួយដ៏ឆាប់រហ័សគេប្រមាណឃើញថា"សតវត្សទី២១ជាសតវត្សនៃប្រទេសជប៉ុនហើយនៅពេលនោះប្រជាជនមានឋានៈជីវភាពខ្ពស់ជាងគេទាំងអស់ក្នុងលោក...។ ប៉ុន្តែការរីកចម្រើននេះមិនមែនប្រកបដោយលំនឹងរឹងប៉ឹងទេ ព្រោះតែជួបនឹងវិបត្តិជាញឹកញាប់ហើយធ្ងន់ធ្ងរផងរហូតដល់ទៅមានការអនុវត្តនយោបាយវាតទីដើម្បីដោះបញ្ហាទាំងឡាយនោះផង។

អនាគតជប៉ុនបិតនៅលើឧស្សាហកម្មនិងការលក់ផលិតផលដែលចេញពីឧស្សាហកម្មនេះ។ប៉ុន្តែបញ្ហាចិញ្ចឹមប្រជាជនដ៏ច្រើន។សព្វថ្ងៃនេះបញ្ហាប្រជាជនកំពុងតែដោះស្រាយទៅតាមផ្លូវឧស្សាហូបនីយកម្មការនេះអាចសម្រេចទៅបានត្រូវប្រទេសជប៉ុនមានលទ្ធភាពនឹងទិញវត្ថុធាតុដើមឱ្យបានកាន់តែច្រើនឡើងៗនិងលក់ផលិតផលទៅវិញឱ្យមានគុណភាពដូចគេឯងឬល្អជាងគេឯងហើយថោកជាងគេទៀត។ចំណោទនេះត្រូវប៉ះពាល់ដល់ប្រាក់បៀវត្សកម្មករដែលគេពុំអាចបញ្ចុះបាន។បើគិតទៅលើតុល្យការនៃការនាំចេញនិងការនាំចូលមានគុណភាពយ៉ាងច្រើនពីព្រោះប្រទេសជប៉ុនត្រូវស្វែងរកទំនិញដែលខ្លួនត្រូវការទាំងប៉ុន្មាននៅកន្លែងឆ្ងាយណាស់ជាហេតុនាំឱ្យជប៉ុនបង់ខាតប្រាក់ជាច្រើនក្នុងការដឹកនាំតែឥឡូវនេះមូលធនអាចរកបានជួយទប់ទល់ការបង់ខាតទាំងនេះ។ប្រទេសជប៉ុនសង្ឃឹមយ៉ាងមាំលើការប្រាស្រ័យទាក់ទងជាថ្មីទៀតខាងពាណិជ្ជកម្មជាមួយនិងចិនដីគោក។ អាស៊ីប៉ែកអាគ្នេយ៍ ក៏ជាទិសដៅនៃបំណងរបស់ជប៉ុនដែរ ពិសេសសង្គ្រាមនៅភូមិភាគនេះ បានហុចលាភសក្ការៈដ៏ប្រសើរសម្រាប់ទ្រទ្រង់ជីវិតសេដ្ឋកិច្ចជប៉ុន។

ដូចនេះ សន្ទុះនៃសេដ្ឋកិច្ចបែបសេរីនិយមនៅប្រទេសជប៉ុនជាផ្លូវដើរទៅរកវិបត្តិមួយ របៀបដូចមហាវិបត្តិឆ្នាំ១៩២៩ដែរ។

បើដូច្នេះមែនវិបត្តិនៅប្រទេសជប៉ុនអាចនឹងឆាបឆេះដោយហេតុថា គេទុកប្រទេសជប៉ុនជាឃ្លាំងរំសេវមួយដ៏ពិតៗ៕

## ២- អំណាចជាអ្វី ?

ពាក្យ "**អំណាច**" មានន័យសម្បូរបែបអាចជាន័យរូបី ន័យទូទៅដែលអាចឬងាយយល់ និងន័យនីតិសាស្ត្រ ឬន័យគតិយុត្ត ន័យប្រើក្នុងច្បាប់ដែលអាចពិបាកយល់ហើយទាមទារការសិក្សាស្រាវជ្រាវខាងវិស័យទស្សនវិជ្ជា និងសង្គមវិទ្យា។ល។

ក្នុងន័យរូបី ន័យទូទៅ អំណាចជាកម្លាំង (force) ឋាមពល (énergie) សមត្ថភាព (capacité) ឥទ្ធិពល (influence) លទ្ធភាព (possibilité) ញាណសត្តិ (faculté) កម្លាំងកាយឬចិត្តដែលអាចធ្វើអ្វីមួយ ឬប្រើឱ្យគេធ្វើ ឬ ទារអ្វីមួយ។

តាមន័យនីតិសាស្ត្រឬន័យគតិយុត្ត អំណាចជាសិទ្ធិដែលត្រូវបានប្រគល់ឱ្យ ដើម្បីធ្វើសកម្មភាពឬធ្វើអំពើអ្វីមួយ។ ជាឧទាហរណ៍ អំណាចដឹកនាំរបស់រដ្ឋាភិបាលគឺជាសិទ្ធិដែលប្រជាពលរដ្ឋប្រគល់ឱ្យតាមរយៈការបោះឆ្នោត ដើម្បីធ្វើកិច្ចការរបស់រដ្ឋ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។ ក្នុងន័យនេះ អំណាចសុទ្ធតែមានព្រំដែន កម្រិត បែងចែកទៅតាមទ្រឹស្តីនៃការបែងចែករបស់ម៉ុងតេស្គយ្យូ (Montesquieu) លើកលែងតែអំណាចផ្តាច់ការដែលមានប្រភពផ្សេងៗ។ អំណាចគិតជាទូទៅស្ថិតនៅក្នុងសញ្ញាណ (notion) បី ដែលទាក់ទងគ្នាជាដរាបមិនអាចខ្វះបានរណបគ្នាទៅវិញទៅមកបើមិនដូច្នោះអំណាចមិនមានស្ថិរភាពជាអចិន្ត្រៃយ៍ និងមិនមានអត្ថិភាព (existence) គ្រប់លក្ខណៈរបស់វាឡើយ។ សញ្ញាណទាំងបីគឺ ១.ប្រភពជាទុន ២.សមត្ថភាព ៣.ការប្រើប្រាស់។ នៅក្នុងន័យនយោបាយ ប្រសិនបើមានប្រភពជាទុន ហើយទោះបីមានសមត្ថភាពតែបើគ្មានចរិតជាយុទ្ធសាស្ត្រនៃអំណាចនោះមិនចេះប្រើប្រាស់វា អំណាចក៏គ្មានអត្ថិភាពគ្រប់លក្ខណៈរបស់វាដែរ។ អំណាចមិនមែនបង្រួមមកត្រឹមតែការប្រើកម្លាំង គាបសង្កត់ផ្លូវយោធា ផ្លូវច្បាប់នោះទេ ពីព្រោះកម្លាំងដែលចេញពីប្រភពខាងលើនេះគ្មានស្ថិរភាពជាអចិន្ត្រៃយ៍នោះឡើយ។ ជាទូទៅអំណាចជាបច្ច័យ (reliation) ទំនាក់ទំនងរវាងកម្លាំងទាំងឡាយដែលមាននៅក្នុងសង្គម។សូម្បីតែធម្មានុកូលភាព (légitimité) ដែលជាប្រភពមួយប្រភេទនៃអំណាចដែលបានមកដោយសារសមត្ថភាពដើម្បីធ្វើឱ្យគេយល់តាមធ្វើតាមក៏ពុំទាន់ចាត់ទុកបានថាជាអំណាចពេញលេញនៅឡើយដែរពីព្រោះវាពុំមានស្ថិរភាព។

ដើម្បីយល់ឱ្យកាន់តែច្បាស់អំពីអំណាចនៅក្នុងសភាពស្មុគស្មាញរបស់វានេះគេត្រូវគួបផ្សំការវិភាគអំពីប្រភពរបស់វាជាមួយនិងការវិភាគអំពីយុទ្ធសាស្ត្រដែលគេប្រើវា។

ឈរលើមូលដ្ឋាននៃការសិក្សាស្រាវជ្រាវខាងលើយើងអាចធ្វើការវិភាគអំពីជម្លោះនយោបាយនៅកម្ពុជាបានពាក់ព័ន្ធនឹង "ការដណ្តើមអំណាច" "ការរក្សាការពារអំណាច" "ការក្រាញអំណាច" ដែលជាព្រឹត្តិការណ៍នយោបាយជាតិសំខាន់៕

ដោយ លី គឹមសុខ

# ៣- ការស្រឡាញ់ជាតិ

ការស្រឡាញ់ជាតិព្រោះមនុស្សទម្រាំនឹងចាប់កំណើតជាមនុស្សជាករណីកម្រណាស់។ដូចនេះមនុស្សកើតមកមានជាតិជារបស់ខ្លួនដោយចងភ្ជាប់នឹងមាតុភូមិ ទឹកដី ប្រជាជាតិ ប្រវត្តិសាស្ត្រ។

ការស្រឡាញ់ជាតិជាកាតព្វកិច្ចនៃដំណើររបស់ដូនតាខ្មែរមានតាំងពីសម័យព្រេងនាយមកម្ល៉េះ ហេតុធ្វើឲ្យសង្គមខ្មែរក្លាយជាចក្រភពដ៏អស្ចារ្យ។ជាក់ស្តែង ដូចយើងឃើញនៅក្នុងសិលាចារឹកនាសតវត្សទី១១ក្នុងរាជ្យព្រះបាទឧទយាទិត្យទី២ ប្រកបដោយមោទនភាពថា " **បើផលដែលកើតចេញពីបុណ្យរបស់ខ្ញុំមានមែនជាតិក្រោយ សូមឱ្យខ្ញុំឆាប់មកកើតនៅកម្ពុជា** " ទៀត។

ក្នុងសង្គមខ្មែរ បើរាប់ពីការធ្លាក់ចុះនៃអារ្យធម៌អង្គរមក គឺមិនថាសម័យណា ឬសម័យណាទេ រហូតមកដល់សព្វថ្ងៃនេះ យើងឃើញពាក្យថា "**ការស្រឡាញ់ជាតិ**" បានផ្ទុះឡើងក្នុងសង្គមខ្មែរយ៉ាងផុលផុសបំផុត។ ពិសេសក្នុងពេលប្រទេសមានសន្តិភាពនិងការអភិវឌ្ឍនេះ យើងតែងឮពាក្យមួយឃ្លានេះ ផ្ទុះចេញពីមាត់មេបក្សនយោបាយ ឬសកម្មជននយោបាយខ្លះ នៅលើបណ្តាញសង្គមខ្លួន ស្ទើរក្លាយជាកម្មសិទ្ធិផ្តាច់មុខរបស់បុគ្គលម្នាក់ៗ ក្នុងចេតនាតាំងខ្លួនថា ជាអ្នកស្រឡាញ់ជាតិដ៏អស្ចារ្យ។

**តើអ្វីជាការស្រឡាញ់ជាតិ ?**

ការស្រឡាញ់ជាតិ គឺជាការជួយទំនុកបម្រុងជាតិ ក្នុងទស្សនៈស្មារតីជាតិនិយម ដល់មាតុភូមិ ប្រជាជនដើម្បីស្ថាបនាជាតិ ទាំងលើឆាកជាតិនិងអន្តរជាតិ។ មានន័យថា " **ការស្រឡាញ់ជាតិ** " ពុំមែនស្ថិតនៅត្រឹមតែមនោសញ្ចេតនា ឬត្រឹមតែបបូរមាត់ប៉ុណ្ណោះទេ គឺស្ថិតនៅលើសកម្មភាពនិងឧត្តមគតិយ៉ាងជាក់ស្តែងក្នុងបុព្វហេតុការពារផលប្រយោជន៍ជាតិ សេចក្តីថ្លៃថ្នូរជាតិ និងប្រជាពលរដ្ឋជាចម្បង។

ស្ថិតក្នុងបរិការនេះ " **ការស្រឡាញ់ជាតិ** " ពុំមែនធ្វើឱ្យជាតិឯកោ ដោយផ្តាច់ចេញពីសហគមន៍អន្តរជាតិដូចសម័យប៉ុលពតនោះទេ។ តែផ្ទុយទៅវិញ " **ការស្រឡាញ់ជាតិ** " ត្រូវផ្សារភ្ជាប់នឹងសហគមន៍អន្តរជាតិជាមិត្តផងដែរ ព្រោះជាតិមួយមិនអាចរស់នៅបានដោយកាត់ផ្តាច់នឹងទំនាក់ទំនងជាមួយនឹងជាតិនានាបានទេ ប៉ុន្តែទំនាក់ទំនងនេះគឺត្រូវឈរលើគោលការណ៍ស្មើភាព សមភាព និងផលប្រយោជន៍គ្នាទៅវិញទៅមក។

ហេតុនេះចំពោះការស្រឡាញ់ជាតិ ពុំមែនសំដៅលើការស្រឡាញ់បែបចង្អៀតចង្អល់ហួសហេតុទេ ប៉ុន្តែធ្វើយ៉ាងណាឱ្យអត្តិភាពជាតិខ្លួនឧដុង្គឧត្តមបំផុតដោយធ្វើយ៉ាងណាឱ្យសក្តិសមជាជាតិមួយក្នុងសហគមន៍ពិភពលោកដូចជាតិនានាដែរ។បានសេចក្តីថាយើងចង់ឱ្យជាតិយើងមានឧត្តមភាពគ្រប់វិស័យប៉ុន្តែយើងក៏គ្មានមហិច្ឆិតាយកឧត្តមភាពនេះទៅរំលោភលើជាតិដទៃដែរ។

ដូចនេះចំពោះ " **ការស្រឡាញ់ជាតិ** " ត្រូវឈរលើឧត្តមគតិជាតិនិយម និងអន្តរជាតិនិយមផងដែរព្រោះយើងត្រូវយល់ថា " **ជាតិ** " នានា ក៏គេស្រឡាញ់ជាតិគេដូចយើងស្រឡាញ់ជាតិយើងដែរ។ ជាក់ស្តែងចំពោះសេចក្តីស្រឡាញ់ជាតិ យើងឃើញក្នុងប្រវត្តិសាស្ត្រកន្លងនេះក្នុងពេលប្រទេសជិតខាង មានមហិច្ឆិតាចង់រំលោភបំពានលើបូរណភាពទឹកដីខ្មែរយើងនៅតំបន់ប្រាសាទព្រះវិហារ ឬតំបន់ផ្សេងៗទៀត គឺយើងហ៊ានពលីជីវិតដើម្បីថែរក្សាការពារនូវសមិទ្ធផលជាតិរបស់យើងដល់តំណក់ឈាមចុងក្រោយរហូតទទួលបានជោគជ័យដើម្បីឯករាជ្យ អធិបតេយ្យ វប្បធម៌។ល។ នេះហៅថា " **ឧត្តមគតិការស្រឡាញ់ជាតិ** " យ៉ាងពិតប្រាកដ។

សព្វថ្ងៃបើពិនិត្យចំពោះទង្វើសកម្មភាពរបស់អ្នក នយោបាយខ្លះ ឬមេបក្សខ្លះ កំពុងតាំងខ្លួនថាជាអ្នកស្រឡាញ់ជាតិ តើពិតជាស្រឡាញ់ជាតិមែនឬទេ ?

បើពិនិត្យមើលអំពីទង្វើជាក់ស្តែងរបស់បុគ្គលទាំងនេះ គឺពុំមែនជាអ្នកស្រឡាញ់ជាតិអ្វីនោះទេ។ ដោយហេតុថា ពួកគេគ្រាន់តែយកពាក្យ " **កាស្រឡាញ់ជាតិ** " នេះ មកធ្វើជាបទចម្រៀងដ៏ពិរោះ ដើម្បីច្រៀងបំពេឱ្យមហាជនស្តាប់គាំទ្រខ្លួនតែប៉ុណ្ណោះ។ ជាក់ស្តែងពួកគេបានយកជាតិទៅជាន់ឈ្លីឬឱ្យបរទេសជាន់ឈ្លីលើឆាកជាតិនិងអន្តរជាតិដោយបានដើរប្រកូសប្រកាសឱ្យអន្តរជាតិផ្តាច់ជំនួយឬកុំឱ្យក្រុមហ៊ុនបរទេសនានាទិញទំនិញពីស្រុកខ្មែរ និងកុំមករកស៊ីនៅស្រុកខ្មែរជាដើម។ ទង្វើទាំងនេះពុំមែនជាការស្រឡាញ់ជាតិដូចគេពោលនោះទេ គឺហៅថាជាការប្រមាថនិងសម្លាប់ " **ជាតិ** " ។

ដូច្នេះការស្រឡាញ់ជាតិជាដំណើររបស់ដូនតា ហើយបើគ្រាន់តែជាវោហាសាស្ត្រនោះទេ គឺប្រៀបដូចជាការឡុកឡាយដល់ព្រលឹងបុព្វការីជនខ្លួនយ៉ាងដូច្នោះដែរ៕

ដោយ រ័ត្ន សណ្តាប់

**គំនិតគួរចងចាំ**

« វិជ្ជានាំឱ្យមានវិន័យ វិន័យនាំឱ្យបានសេចក្តីថ្លៃថ្នូរ សេចក្តីថ្លៃថ្នូរនាំឱ្យបានទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិនាំឱ្យបានធម៌ ធម៌ដឹកនាំឱ្យបានសេចក្តីសុខ។ »

លោកន័យសាស្ត្រ - មាស ព្រេង ១៩៥៧

## សកម្មភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែតុលាឆ្នាំ២០២០ |
|---|---|---|
| ១ | ០៥-១០-២០<br>ម៉ោង១៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងឱកាសប្រារព្ធពិធីបុណ្យរួបរួមជាតិសាធារណរដ្ឋសហព័ន្ធនៃប្រទេសអាឡឺម៉ង់ នៅសណ្ឋាគារ Raffles Hotel Le Royal ។ |
| ២ | ០៧-១០-២០<br>ម៉ោង០៩:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធមជ្ឈមណ្ឌលកម្សាន្តព្រីនស៍ម៉ាណ័រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅក្នុងភូមិដីឥដ្ឋកោះផុស ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ |
| ៣ | ០៧-១០-២០<br>ម៉ោង១៥:០០នាទី | ដឹកនាំអង្គប្រជុំដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២១-២០២៣។<br>២- សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣។<br>៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៣.១- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកវាព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម<br>៣.២- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖<br>១. ពិធីសារទី៣ស្តីពីសិទ្ធិសហការលើជើងហោះហើរក្នុងស្រុក ក្នុងរង្វង់ទឹកដីនៃប្រទេសជាសមាជិកអាស៊ានណាមួយ<br>២. ពិធីសារទី៤ស្តីពីសិទ្ធិហោះហើរកូដ៍មីណល រវាងអាកាសយានដ្ឋាននៅក្នុងទឹកដីនៃប្រទេសជាសមាជិកអាស៊ាន<br>៣.៣- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៩ និងទី១០ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម<br>៣.៤- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៤ | ០៨-១០-២០<br>ម៉ោង០៩:៣០នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២១-២០២៣។<br>២- សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣។ |

| | | |
|---|---|---|
| | | ៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៣.១- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម<br>៣.២- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖<br>១. ពិធីសារទី៣ស្តីពីសិទ្ធិសហការលើជើងហោះហើរក្នុងស្រុក ក្នុងរង្វង់ទឹកដីនៃប្រទេសជាសមាជិកអាស៊ានណាមួយ<br>២. ពិធីសារទី៤ស្តីពីសិទ្ធិហោះហើរកូដ៍មីណល រវាងអាកាសយានដ្ឋាននៅក្នុងទឹកដីនៃប្រទេសជាសមាជិកអាស៊ាន<br>៣.៣- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៩ និងទី១០ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម<br>៣.៤- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ។<br>(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៥ | **០៩-១០-២០**<br>**ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២១-២០២៣។<br>២- សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហឹង្សាលើស្ត្រី ២០១៩-២០២៣។<br>៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៣.១- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម<br>៣.២- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖<br>១. ពិធីសារទី៣ស្តីពីសិទ្ធិសហការលើជើងហោះហើរក្នុងស្រុក ក្នុងរង្វង់ទឹកដីនៃប្រទេសជាសមាជិកអាស៊ានណាមួយ<br>២. ពិធីសារទី៤ស្តីពីសិទ្ធិហោះហើរកូដ៍មីណល រវាងអាកាសយានដ្ឋាននៅក្នុងទឹកដីនៃប្រទេសជាសមាជិកអាស៊ាន<br>៣.៣- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៩ និងទី១០ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម<br>៣.៤- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព) |

| | | |
|---|---|---|
| ៦ | **១៣-១០-២០ ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំចង្អៀត ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា។ (នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៧ | **១៣-១០-២០ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំ ជាមួយក្រុមការងាររដ្ឋាភិបាលចុះមូលដ្ឋានឃុំអង្គាញ់។ (នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៨ | **២០-១០-២០ ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំពិសេសគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ (នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៩ | **២១-១០-២០ ម៉ោង០៩:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។<br>២- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។<br>៣- បញ្ហាផ្សេងៗ<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។<br>(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ១០ | **២២-១០-២០ ម៉ោង០៩:៣០នាទី** | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។<br>២- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។<br>៣- បញ្ហាផ្សេងៗ។<br>(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ១១ | **២៣-១០-២០ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។<br>២- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។<br>៣- បញ្ហាផ្សេងៗ។<br>(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ១២ | **២៧-១០-២០ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំដើម្បីធ្វើបទបង្ហាញអំពី ECOSOCC ជូនដល់ ឯកឧត្តម **ជួន សុកាន់ណារិទ្ធ** សមាជិកថ្មី។ )នៅទីស្តីការគណៈរដ្ឋមន្ត្រី( |
| ១៣ | **២៨-១០-២០ ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា។ (នៅទីស្តីការគណៈរដ្ឋមន្ត្រី) |

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែវិច្ឆិកាឆ្នាំ២០២០ |
|---|---|---|
| ១ | ០៣-១១-២០<br>ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការសម្របសម្រួល និងសហការជាមួយភាគីចិនលើគម្រោងជួសជុលកែលម្អអគារមិត្តភាពជាមួយភាគីចិន។<br>(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ២ | ០៥-១១-២០<br>ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំចង្អៀតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំត្រីមាសទី៣។<br>(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៣ | ១២-១១-២០<br>ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំពិសេសគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។<br>(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៤ | ២៤-១១-២០<br>ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការសម្របសម្រួល និងសហការជាមួយភាគីចិនលើគម្រោងជួសជុលកែលម្អអគារមិត្តភាពជាមួយភាគីចិន។<br>(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៥ | ២៤-១១-២០<br>ម៉ោង១៥:៣០នាទី | ជួបប្រជុំការងារជាមួយឯកឧត្តម **អ៊ី សារី** សហប្រធានក្រុមការងារចុះមូលដ្ឋានឃុំព្រៃល្វា។<br>(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៦ | ២៥-១១-២០<br>ម៉ោង១៥:០០នាទី | ដឹកនាំកិច្ចប្រជុំការងារផ្ទៃក្នុងរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។<br>(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៧ | ២៧-១១-២០<br>ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា។<br>(នៅទីស្តីការគណៈរដ្ឋមន្ត្រី) |

## បច្ចេកសព្ទ

**វប្បធម៌** ទំនៀមទម្លាប់ ប្រពៃណី ផ្នត់គំនិត ជំនឿសាសនា បច្ចេកវិទ្យា ព្រមទាំងឥរិយាបថនៃសង្គមមនុស្ស ឬជាតិសាសន៍មួយ។ ការបណ្ដុះនូវចំណេះវិជ្ជា ប្រាជ្ញាស្មារតី និងរបៀបរស់នៅរបស់មនុស្សឱ្យបានលូតលាស់ចម្រើន ដើម្បីសម្របសម្រួលទៅនឹងបរិស្ថាន និងការអភិវឌ្ឍសង្គមដោយវិទ្យាសាស្ត្រឬដោយសិល្បៈផ្សេងៗជាដើម។ culture

**បេតិកភណ្ឌ** ស្នាដៃ ទ្រព្យសម្បត្តិ ឬកេរមរតកដែលបង្កើតឡើងដោយមនុស្សជំនាន់មុន ហើយមានតម្លៃបន្តពីជំនាន់មួយទៅជំនាន់មួយ។ heritage

**បេតិកភណ្ឌវប្បធម៌** រាល់ស្នាដៃរបស់មនុស្សនិងរាល់ផលិតផលរបស់ធម្មជាតិដែលមានចរិតវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា ដែលឆ្លុះបញ្ចាំងនូវដំណាក់កាលនៃការវិវត្តរបស់អរិយធម៌ឬរបស់ធម្មជាតិ។ cultural heritage

**បេតិកភណ្ឌវប្បធម៌ក្រោមទឹក** រាល់ដានស្នាមក្រោមទឹកនៃអត្ថិភាពរបស់មនុស្ស ដែលមានចរិតលក្ខណៈវប្បធម៌ ប្រវត្តិសាស្ត្រឬបុរាណវត្ថុវិទ្យា ដែលលិចក្នុងទឹកមួយផ្នែកឬទាំងស្រុង ទៅតាមកាលកំណត់ទៀងទាត់ឬជាអចិន្ត្រៃយ៍ តាំងពីរយៈពេលមួយរយឆ្នាំយ៉ាងតិច មានជាអាទិ៍ : ១-រមណីយដ្ឋាន រចនាសម្ព័ន្ធ អគារ វត្ថុ និងសំណល់ឆ្អឹងរបស់មនុស្ស ព្រមទាំងបរិបទបុរាណវត្ថុវិទ្យា និងធម្មជាតិនៃរបស់ទាំងនេះ។ ២-នាវា យន្តហោះយានយន្តដទៃទៀតឬរាល់ភាគនៃរបស់ទាំងនេះដោយមាននាវាភណ្ឌឬបន្ទុកដទៃផ្សេងទៀតនិងព្រមទាំងបរិបទបុរាណវត្ថុវិទ្យានិងធម្មជាតិ និង៣-រាល់វត្ថុនានាដែលមានលក្ខណៈសណ្ឋានជាបុរេប្រវត្តិ។ ក្នុងន័យនេះ បំពង់បង្ហូរប្រេង ឧស្ម័ន និងខ្សែកាបដែលដាក់ឬដំឡើងក្នុងជម្រៅសមុទ្រមិនចាត់ទុកជាផ្នែកនៃបេតិកភណ្ឌវប្បធម៌ក្រោមទឹកឡើយ។សំណង់ក្រៅពីបំពង់បង្ហូរប្រេងឧស្ម័នឬខ្សែកាបដែលដាក់ឬដំឡើងក្នុងជម្រៅសមុទ្រហើយកំពុងប្រើប្រាស់មិនចាត់ទុកជាផ្នែកនៃបេតិកភណ្ឌវប្បធម៌នេះទេ។ under water cultural heritage

**បេតិកភណ្ឌវប្បធម៌ជាតិ** សម្បត្តិវប្បធម៌ទាំងរូបី ទាំងអរូបីរបស់ជាតិមួយ។ national cultural heritage

**បេតិកភណ្ឌវប្បធម៌បៃតង** កេរដំណែលសម្បត្តិវប្បធម៌ដែលត្រូវបានបង្កើតឡើង ឬកើតចេញពីធម្មជាតិ ឬរកឃើញនៅក្នុងទឹកដីនៃមាតុភូមិ ដែលជាស្នាដៃមនុស្សនិងផលិតផលរបស់ធម្មជាតិ ដោយមានលក្ខណៈវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា និងលក្ខណៈធម្មជាតិបៃតង ដែលបង្ហាញពីការវិវត្តនៃសង្គមវប្បធម៌និងសង្គមសេដ្ឋកិច្ចរបស់ប្រទេសផ្សារភ្ជាប់ទៅនឹងការវិវត្តនៃអភិវឌ្ឍន៍បៃតងនិងអរិយធម៌ជឿនលឿនតាមបែបធម្មជាតិ។ green cultural heritage

**បេតិកភណ្ឌវប្បធម៌រូបី** ស្នាដៃបង្កើតដោយមនុស្ស ជាទ្រព្យសម្បត្តិដែលអាចមើលឃើញ ប៉ះពាល់បាន ងាយយល់ និងមានតម្លៃប្រវត្តិសាស្ត្រ សោភណភាព សិល្បៈ សាសនា វិទ្យាសាស្ត្រ បុរាណវត្ថុវិទ្យា ជាតិពន្ធុវិទ្យា ឬនរវិទ្យា រួមមានប្រាសាទ វិមាន វិហារ អគារ ផ្ទះសម្បែង វត្តអារាម រមណីយដ្ឋានវប្បធម៌ជាដើម។ tangible cultural heritage

**បេតិកភណ្ឌវប្បធម៌អរូបី** ការប្រតិបត្តិ ការសម្តែង ការនិយាយ ចំណេះដឹង ចំណេះធ្វើ ព្រមទាំងឧបករណ៍វត្ថុ វត្ថុដែលវាមានប្រភពសិប្បនិម្មិតនិងលម្ហវប្បធម៌បញ្ចូលគ្នាដែលសហគមន៍ក្រុមមនុស្សនិងក្នុងករណីខ្លះបុគ្គល ទទួលស្គាល់ថាជាផ្នែកមួយនៃបេតិកភណ្ឌវប្បធម៌របស់ពួកគេ។ បេតិកភណ្ឌវប្បធម៌ អរូបីនេះត្រូវបានបន្តវេន ពីជំនាន់មួយទៅជំនាន់មួយហើយដែលត្រូវបានបង្កើតថ្មីឡើងវិញជាអចិន្ត្រៃយ៍ដោយសហគមន៍និងក្រុមមនុស្ស ផ្អែកទៅតាមកន្លែងនិង បរិស្ថានដែលគេរស់នៅទៅនឹងអន្តរកម្មរបស់ពួកគេជាមួយនឹងធម្មជាតិ ព្រមទាំង ជាមួយនឹងប្រវត្តិសាស្ត្ររបស់ពួកគេ ហើយបានផ្ទេរនូវមនោសញ្ចេតនានៃអត្តសញ្ញាណនិងនិរន្តរភាពនោះ សម្រាប់ការរួមចំណែកក្នុងការជំរុញឱ្យមានការគោរពវប្បធម៌ប្លែកៗគ្នានិងភាពចេះបង្កើតថ្មីរបស់មនុស្ស។ក្នុង អនុសញ្ញាស្តីពីការការពារបេតិកភណ្ឌវប្បធម៌អរូបី អាចចាត់ទុកបានជាបេតិកភណ្ឌវប្បធម៌អរូបី គឺរបស់ដែល សមស្របជាមួយនឹងលិខិតូបករណ៍អន្តរជាតិកំពុងអត្ថិភាព ទាក់ទងជាមួយនឹងសិទ្ធិមនុស្សជាធរមាន ក៏ដូចជា ការតម្រូវឱ្យមានការគោរពគ្នាទៅវិញទៅមករវាងសហគមន៍រវាងក្រុមមនុស្សបុគ្គលនិងការអភិវឌ្ឍប្រកបដោយ ចីរភាព។ បេតិកភណ្ឌវប្បធម៌អរូបី តាមនិយមន័យនេះ ត្រូវបានស្តែងឡើងជាពិសេសនៅក្នុងវិស័យដូចតទៅ : ១-ប្រពៃណីនិងសំដីនិយាយ រួមមានភាសាជាយាននៃបេតិកភណ្ឌវប្បធម៌អរូបី។ ២-សិល្បៈទស្សនីយភាព។ ៣-ការប្រតិបត្តិសង្គម សាសនា និងប្រតិបត្តិការណ៍សម្រាប់ពិធីបុណ្យ។ ៤-ចំណេះដឹង និងការប្រតិបត្តិអំពី ធម្មជាតិនិងសាកលលោក និង ៥-ចំណេះធ្វើផ្សារភ្ជាប់ជាមួយនឹងសិប្បកម្មប្រពៃណី។ intangible cultural heritage

**បេតិកភណ្ឌវប្បធម៌អរូបីបៃតង** ការប្រត្តិបត្តិ ការសម្តែង ការនិយាយ ចំណេះដឹង ចំណេះធ្វើ ព្រមទាំងឧបករណ៍ វត្ថុដែលមានប្រភពសិប្បនិម្មិត លម្ហបៃតង និងពិពិធភាវូនីយកម្មវប្បធម៌ ទទួលស្គាល់និងទទួលយកក្នុងសង្គម ដោយត្រូវបានបន្តវេនពីជំនាន់មួយទៅជំនាន់មួយ ហើយត្រូវបានបង្កើតថ្មីឡើងវិញជាអចិន្ត្រៃយ៍ នៅតាម សហគមន៍និងក្រុមមនុស្សផ្អែកទៅតាមកន្លែងដែលបង្កើតនូវសុខដុមនីយកម្មរបស់មនុស្សជាមួយនឹងធម្មជាតិ ព្រមទាំងជាមួយនឹងប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ និងអក្សរសាស្ត្ររបស់ ពួកគេ ហើយបានផ្ទេរនូវមនោសញ្ចេតនានៃអត្តសញ្ញាណ និងនិរន្តរភាព សម្រាប់រួមចំណែកក្នុងការជំរុញឱ្យ មានការគោរពវប្បធម៌ប្លែកៗគ្នានិងភាពចេះបង្កើតថ្មីរបស់មនុស្ស។ green intangible cultural heritage

---

ដកស្រង់ពីសទ្ទានុក្រមបច្ចេកសព្ទ ឆ្នាំ២០២០
រៀបរៀងដោយបណ្ឌិតសភាចារ្យ ឆយ អូន

# ស្រាវជ្រាវ : យល់ដឹងអំពី " ប្រពៃណីបុណ្យអុំទូក អកអំបុក សំពះព្រះខែ "

ក) **ពិធីបុណ្យអុំទូក** ៖ គឺជាបុណ្យប្រពៃណីដ៏ធំមួយ ដែលប្រជារាស្ត្រខ្មែរតែងរៀបចំធ្វើជារៀងរាល់ឆ្នាំ ក្នុងថេរវេលា៣ថ្ងៃ គឺនៅថ្ងៃ១៤កើត ១៥កើត និងថ្ងៃ១រោចនៃខែកត្តិក។ ក្នុងពិធីបុណ្យអុំទូកនេះ គេតែងមានប្រារព្ធពិធីបណ្តែតប្រទីប ពិធីសំពះព្រះខែ និងអកអំបុកផងដែរ។

**ក១.ប្រវត្តិបុណ្យអុំទូក**៖ ប្រវត្តិនៃពិធីបុណ្យអុំទូកមានតាំងពីបុរាណកាលយូរលង់កន្លងមកហើយ។មានឯកសារជាច្រើនបានបកស្រាយប្លែកៗគ្នា ហើយក៏មានរូបភាពជាក់ស្តែងឆ្លាក់នៅលើសិលាជញ្ជាំងប្រាសាទបាយ័ន និងបន្ទាយឆ្មារផង ដែរ។ ប្រវត្តិសាស្ត្រខ្មែរបានចែងថា ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ប្រទេសកម្ពុជា ជាមហានគរ ហើយមានសេចក្តីសុខក្សេមក្សាន្តណាស់។ ប្រាសាទបាយ័នកសាងក្នុងរាជ្យព្រះអង្គនោះ យើងបានឃើញរូបចម្លាក់កង ទ័ពទូកយ៉ាងច្រើន។ឯនៅប្រាសាទបន្ទាយឆ្មារក៏បានកសាងឡើងក្នុងរាជ្យព្រះអង្គដែរនោះ មានឆ្លាក់ព្រះឆាយាលក្ខណ៍ព្រះអង្គប្រថាប់ឈរលើទីនាំងនាវាចំបាំង ហើយទ្រង់ធ្នូរនិងដំបងយ៉ាងស្វាហាប់...។ព្រះអង្គបានយាងចេញធ្វើសឹកសង្គ្រាមតាមជើងទឹកដើម្បីបង្ក្រាបពួកចាមហើយទទួលបានជ័យជំនះរំដោះក្រុងកម្ពុជារួចផុតពីខ្មាំងសត្រូវនៅក្នុងគ.ស.១១៧៧-៨១។ ប្រជារាស្ត្រខ្មែរនៅខេត្តឃ្លាំងក្នុងទឹកដីកម្ពុជាក្រោម ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសវៀតណាម ក្នុងសម័យបច្ចុប្បន្ននេះ នៅបានរក្សាប្រពៃណីដូនតាយ៉ាងប្តូរផ្តាច់។ គេតែងប្រារព្ធធ្វើបុណ្យអុំទូកនៅថ្ងៃពេញបូណ៌មីនៃខែកត្តិកនេះ ដោយមានភាពអឹកធឹកដែរ។ គេនៅរក្សាបានប្រពៃណីដ៏ជាប់លាប់នេះ គឺដោយសារឧត្តមគតិស្នេហាជាតិ និងទំនៀមទម្លាប់ប្រពៃណីក៏ដូចជាពូជអំបូរ ដែលមានឈាមជ័រជាអ្នកតស៊ូដ៏អង់អាច។ ជាក់ស្តែងនៅក្នុងឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៅព.ស.២០៧១ គ.ស.១៥២៨ ព្រះអង្គចន្ទទី១ ទ្រង់តាំងពញាតាគងារជាសិទ្ធិភូបាល ជាស្តេចត្រាញ់នៅកម្ពុជាក្រោម ស្រុកបាសាក់។ ស្តេចត្រាញ់នេះបានចាត់របៀបរៀបចំការពារស្រុក មានដូចតទៅនេះ ៖

ទាហានជើងទឹកចែកជា៣ក្រុម ៖



ព្រះឆាយាលក្ខណ៍នៃព្រះបាទជ័យវរ្ម័នទី៧ នៅប្រាសាទបន្ទាយឆ្មារ

-ក្រុមទី១: ហៅទ័ពស្រួច ហាត់ច្បាំងនឹងទូកអុំដែលមានទ្រង់ទ្រាយដូចទូកប្រណាំងយើងសព្វថ្ងៃ។

-ក្រុមទី២: ហៅទ័ពជំនួយ ហាត់ច្បាំងនឹងទូកចែវពីរជួរដែលមានទ្រង់ទ្រាយដូចទូកប្រណាំងយើងសព្វថ្ងៃ។

-ក្រុមទី៣ : ហៅទ័ពបាសាក់ គឺទូកធំមានដំបូលមានចែវមានក្តោងមានទ្រង់ទ្រាយដូចបាសាក់ ហៅទូកប៉ុកចាយ តែរាងស្តួចវែងមានដំបូលតែមួយកាត់ខាងមុខឥតជញ្ជាំង ជាទូកដាក់ស្បៀងអាហារសម្រាប់កងទ័ព។ របៀបបង្ហាត់ចម្បាំង បើតាមទំនៀមស្តេចត្រាញ់កម្ពុជាក្រោម ស្តេចលើកមន្ត្រីបួនទិស «ចតុស្តម្ភ» ដែលនៅក្រោមឱវាទលោកសិទ្ធិភូបាល ស្តេចត្រាញ់គ្រប់ជំពូក ដែលបញ្ញត្តិច្បាប់សម្រាប់

ស្រុក។ កំណត់យកថ្ងៃពេញបូណ៌មីខែកត្តិក រដូវអកអំបុកនោះ មន្ត្រីទាំងបួនទិសត្រូវកេណ្ឌទាហាន ជើងទឹក ជើងគោក មកធ្វើ«សមយុទ្ធ» ១ថ្ងៃ១យប់រៀងរាល់ឆ្នាំ។ ចំណែកទាហានជើងទឹកទៅប្រឡងឫទ្ធិនៅ ឯទន្លេពាម កន្ទោរក្នុងខេត្តឃ្លាំង ត្បិតទីនោះជាទីប្រជុំទឹកគ្រប់ខេត្ត និងទៅមកបានស្រួល។ ចំណោរកាលក្រោយមក ពិធីហ្វឹកហាត់កងទ័ពជើងទឹក បានក្លាយទៅជាប្រពៃណីបុណ្យអុំទូក ដើម្បីរំលឹកគុណដល់វីរយុទ្ធជនខ្មែរដែលបាន ធ្វើពលីកម្មការពារទឹកដីខ្មែរ ឱ្យបានគង់វង់រហូតមកដល់សព្វថ្ងៃនេះ។

**ក២. កម្មវិធីបុណ្យអុំទូក - បណ្តែតប្រទីបៈ** ប្រជារាស្ត្រខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនា តែក្នុងព្រលឹងខ្មែរ តែងមានបង្កប់នូវឥទ្ធិពលព្រហ្មញ្ញសាសនានិងជំនឿជីវចលនិយមដែរ។ ដូចនេះប្រពៃណីខ្លះមានប្រវត្តិទាក់ទង ទៅនឹងព្រះពុទ្ធជាព្រះបរមគ្រូហើយក៏មានទាក់ទងទៅនឹងជំនឿសាសនាពីរទៀតនោះដែរ។ ក្នុងពិធីបុណ្យអុំទូក នេះ គេមានរៀបពិធីលយប្រទីបដែរ នោះគឺសម្រាប់បូជាព្រះពុទ្ធបាទដែលប្រតិដ្ឋាននៅឆ្នេរស្ទឹងធម្មទា និង ព្រះចង្កូមកែវជាដើម នៅពិភពនាគ។ ក្នុងគម្ពីរទាថាវង្សបានចែងថា ព្រះចង្កូមកែវទាំងបួនរបស់ព្រះពុទ្ធ បាន ប្រតិដ្ឋាននៅបួនកន្លែងដែរគឺៈ នៅឋានត្រៃត្រឹង ពិភពនាគ ស្រុកគន្ធារៈ និង ទន្តបុរៈ នៃដែនកលិង្គរដ្ឋ។ ឯ ភាណវារៈបាលី ត្រង់ពុទ្ធនមស្ការគាថាបានចែងថាៈ ស្នាមព្រះបាទព្រះពុទ្ធមានប្រតិដ្ឋាននៅប្រាំកន្លែងគឺៈ នៅ ភ្នំសុវណ្ណម្មាលិក ភ្នំសុវណ្ណ ភ្នំសុមុនកូដ យោនកបុរី និងស្ទឹងធម្មទា។ ហេតុដូចនេះហើយបានជាបុព្វបុរសយើង ធ្វើបុណ្យលយប្រទីបឧទ្ទិសដ្ឋានតាមព្រះគង្គាទៅកាន់ទីកន្លែងទាំងពីរនេះ។ ម្យ៉ាងទៀត បុណ្យអុំទូកនិងលយ ប្រទីបនេះ ក៏អាចចាត់បញ្ចូលក្នុងជំនឿ និងទំនៀមទម្លាប់នៃព្រហ្មញ្ញសាសនា គឺដើម្បីជាការដឹងគុណដល់ព្រះ គង្គា និងព្រះធរណី ដែលជាអ្នកផ្តល់ឱ្យជីវភាពរស់នៅ និងសេចក្តីសុខក្សេមក្សាន្តផងដែរ។ ជាក់ស្តែងស្ថាន ភាពភូមិសាស្ត្រនៃប្រទេសកម្ពុជាមានបឹងទន្លេសាបដែលជាប្រភពទឹកដ៏ធំមួយនៅអាស៊ីភាគអាគ្នេយ៍បានទទួល ទឹកពីទីបេប្រទេសចិន ជាទីដ៏សែនឆ្ងាយតាមរយៈទន្លេមេគង្គ។ ម្យ៉ាងទៀតបឹងទន្លេសាបនេះ ក៏បានទទួលទឹក ពីប្រភពភ្នំគូលែន ដែលជាទីដ៏ពិសិដ្ឋតាមរយៈស្ទឹងសៀមរាបដែរ។ ទឹកជំនន់ដៃទន្លេមេគង្គ បានធ្វើឲ្យបឹងបួរ ទាំងឡាយលិចក្លាយទៅជាសមុទ្រដ៏ធំល្វឹងល្វើយ ដោយនាំយកដីល្បាប់មកជាមួយ បានធ្វើឱ្យដីមានជីជាតិ បង្កលក្ខណៈឱ្យដំណាំដុះលូតលាស់ល្អគួរជាទីពេញចិត្ត។ ដល់រដូវសម្រក ទឹកក្នុងបឹងទាំងឡាយនោះហូរ ត្រឡប់តាមទន្លេសាប ពីជើងទៅត្បូងវិញ ដែលចាប់ផ្តើមនៅខែវិច្ឆិកា គឺជាពេលដែលស្រូវក្នុងស្រែកំពុងតែទុំ ដែរ។ ប្រជារាស្ត្រខ្មែរជាកសិករ បានដាំដំណាំនិងធ្វើស្រែតាមដំណើរនៃទឹកសម្រកនេះ រៀបចំជាពិធីបុណ្យ « អុំទូក លយប្រទីប សំពះព្រះខែ និងអកអំបុក » ដើម្បីសំដែងនូវមនោសញ្ចេតនាដឹងគុណ ចំពោះវីរសកម្ម យុទ្ធជនខ្មែរ ក្នុងការការពារប្រទេសជាតិមាតុភូមិបានគង់វង់ និងមានកេរ្តិ៍ឈ្មោះល្បីរន្ទឺពេញសកលលោក។ ចំពោះអ្នកមានគុណ និងដើម្បីសុំខមាទោសនូវអំពើមិនគប្បី ដែលកើតមានជាយថាហេតុ ក្នុងការផ្តល់គ្រឿង ស្មោកគ្រោកដល់លោកទាំងពីរ។

ក្នុងឱកាសពិធីអុំទូក កម្មវិធីតែងចាប់ផ្តើមប្រព្រឹត្តទៅពីម៉ោង១២ រហូតដល់ ម៉ោង១៦ ដោយមានទូកអុំ និងទូកចែវមួយគូៗ ក្នុងសម្លៀកបំពាក់ចម្រុះពណ៌ គួរឱ្យចង់គយគន់។ ទូកនីមួយៗត្រូវនៅខ្សែទឹកខាងក្នុង និង ខ្សែទឹកខាងក្រៅ ហើយត្រូវឆ្លងកាត់បីកងពាន់ ទើបបានដល់ទីប្រណាំង ដោយមានអ្នកចាំវាយស្គរជ័យនៅទី នោះ។ ព្រលប់នៃថ្ងៃទី៣ដែលជាថ្ងៃបង្ហើយ ទូកទាំងអស់ត្រូវប្រមូលផ្តុំគ្នាធ្វើពិធីចាប់កូនខ្លែង ដើម្បីប្រារព្ធពិធី

កាត់ព្រំតបិទកម្មវិធីប្រណាំងទូករួចលាគ្នាវិលត្រឡប់ទៅកាន់តំបន់រស់នៅរបស់ខ្លួនវិញ។ឯពិធីបណ្តែតប្រទីប ចាប់ប្រព្រឹត្តទៅពីម៉ោង១៨ទៅ ដោយចេញដំណើរពីសាលសន្និសិទ្ធចតុមុខ ព្រមទាំងមានបាញ់កាំជ្រួចទន្ទាភ្លឺព្រោងព្រាតផង ឆ្ពោះទៅដល់វិមានរដ្ឋាភិបាល ហើយត្រលប់មកវិញចុះឡើងចំនួន៣ជុំ។ គេតែងកំដរដោយតន្ត្រីពិណពាទ្យ ដូចក្នុងពិធីអុំទូកដែរ តែសម្រាប់តែនៅលើនាវាដែលលយប្រទីបទេ។ ចំណែកនៅលើព្រះរាជដំណាក់ផែ គេប្រគុំកំដរដោយប្រភេទតន្ត្រីមហោរីវិញ។ បទមហោរីដែលគេបានជ្រើសរើសមកកំដរក្នុងពិធីចុះផែនេះច្រើនជាបទសម្តែងនូវមនោសញ្ចេតនាសប្បាយរីករាយ ឬក៏ពណ៌នាពីទេសភាពដ៏ត្រកាលគួរជាទីចាប់ចិត្ត។ ទំនុកជាពិសេសច្រើនរៀបរាប់ពីទិដ្ឋភាពក្រោមពន្លឺព្រះចន្ទពេញបូណ៌មី ឬការរាប់ឈ្មោះនៃហ្វូងតារាដ៏ច្រើនអនេក ឬក៏ការច្រៀងឆ្លើយឆ្លងគ្នា។ ប៉ុន្តែទំនុកចាប់ផ្តើមជាដំបូង គេត្រូវប្រើ ពាក្យ « សកវាទី » ជាដរាប។ ហេតុដូចនេះហើយ បានជាចាស់ៗច្រើនតែពោលថា «សកវាទីចុះផែ» ដ៏គួរពីរោះក្រៃលែង...។ សកវាទីនេះមានន័យថា ជាពាក្យសំដីពោលខាង ចំណែកខ្លួន គឺមកពី «សក» ជាពាក្យបាលីប្រែថា «របស់ខ្លួន ឬជាចំណែកខ្លួន» ឯ «វាទី» មកពីពាក្យ «វាទ» ជាពាក្យបាលីដែរប្រែថា «ពាក្យសំដី»។

**ខ) ពិធីសំពះព្រះខែ - អកអំបុក**

**ខ១. ពិធីសំពះព្រះខែ:** គេធ្វើបុណ្យសំពះព្រះខែ ដើម្បីរំឭកដល់កាលព្រះពោធិសត្វយោនយកកំណើតជាសត្វទន្សាយ។នៅថ្ងៃពេញបូណ៌មីនាវេលារាត្រីព្រះចន្ទរះពេញវង់មានពន្លឺល្អទ្រង់ក្រឡេកមើលព្រះចន្ទហើយមានសេចក្តីជ្រះថ្លាដោយនឹកគិតថា«បើនរណាត្រូវការសាច់របស់អាត្មាអញជាអាហារអាត្មាអញនឹងបានបំពេញជីវិតទានក្នុងពេលឥលូវនេះ»។គ្រាន់តែនឹកគិតភ្លាមក៏ក្តៅដល់ព្រះឥន្ទ្រស្តេចឃើញទន្សាយព្រះពោធិសត្វមានសេចក្តីប្រាថ្នាចង់បំពេញទាន។ ព្រះឥន្ទ្រក៏មកក្លែងខ្លួនធ្វើជាព្រាហ្មណ៍ចាស់ម្នាក់ មកកាន់សំណាក់ទន្សាយពោធិសត្វហើយពោលថា«ជីវិតខ្ញុំនឹងក្ស័យក្នុងថ្ងៃនេះមិនខានឡើយធ្វើម្តេចនឹងបានអាហារបរិភោគ»។ទន្សាយប្រាប់ថា «ខ្ញុំមានតែសាច់និងឈាមរបស់ខ្ញុំត្រូវការឱ្យជាទាន បើអ្នកត្រូវការចូររកអុសមកបង្កាត់ភ្លើងឱ្យឆេះទៅចុះ »។ ព្រាហ្មណ៍ចាស់តបថា « ខ្ញុំអរគុណអ្នកណាស់ » ហើយក៏រកអុសមកបង្កាត់ភ្លើង រួចហើយទន្សាយលោតខ្លួនយ៉ាងស្អាតលោតចូលទៅក្នុងភ្លើង ស្រាប់តែភ្លើងនោះរលត់អស់ សូម្បីតែរោមមួយសរសៃក៏ពុំបានឆេះផង។ ព្រះឥន្ទ្រស្ញើចសរសើរហេតុដ៏អស្ចារ្យនេះ ហើយក៏ហោះទៅយកម្នាងសិលាមួយដុំ គូសវាសភ្ជាប់រូបទន្សាយក្នុងវង់ព្រះចន្ទ។ ហេតុនេះហើយ បានជាអ្នកខ្លះមើលលោកខែហាក់មានរូបទន្សាយនៅក្នុងរង្វង់។ អ្នកកាន់ព្រះពុទ្ធសាសនាតែងនាំគ្នាគោរព និងធ្វើបុណ្យសំពះព្រះខែតរៀងតាំងពីបុរាណកាលមក។

**ខ២. ពិធីអកអំបុក:** គឺជាពិធីរំឭកដល់កាលព្រះពោធិសត្វយោនយកកំណើតជាសត្វទន្សាយដែរ។ នៅខែកត្តិកជារដូវស្រូវជិតទុំ មានពណ៌ក្រហមស្លាបសេក ប្រជារាស្ត្រតែងច្រូតយកខ្លះ ដើម្បីលីងដាល់អំបុកដែលជាអាហារម៉្យាងមានរសជាតិឈ្ងុយឆ្ងាញ់គួរជាទីជាប់ចិត្ត។ចំណីអំបុកនេះបើគេហូបត្រូវលើកអកបានមិនខ្ទះខ្ទាយកំពប់ខាតចោល។ប្រសិនបើចង់ឱ្យងាយស្រួលទទួលទានហើយបង្កើនរស់ជាតិផ្អែមគេត្រូវច្របាច់ជាមួយចេកឬយកចេកចុចនឹងអំបុកនោះរិតតែជាការប្រសើរ។ហេតុនេះហើយបានជាក្នុងពិធីសំពះព្រះខែគេតែងដាក់ចេកថ្វាយព្រះចន្ទជាមួយអំបុក។ ម៉្យាងទៀត ដោយជឿតាមរឿងខាងលើនេះដែរ បានជាគេតែងដាក់ផ្លែចេក ព្រោះចេកជាចំណីមួយយ៉ាងប្រសើររបស់សត្វទន្សាយ។គេប្រារព្ធពិធីនេះក្នុងរាត្រីនៃថ្ងៃ១៥កើតខែកត្តិកដោយដំណើរ

ការរៀបចំអុជទៀនធូបថ្វាយនៅពេលព្រះចន្ទរះលេចចេញច្បាស់រហូតដល់ម៉ោង១២អាធ្រាតនៅកណ្ដាលទីវាលស្រឡះ។ក្នុងឱកាសរង់ចាំរហូតដល់ពេលខែត្រង់នេះគេតែងមកជួបជុំគ្នាដើម្បីលេងល្បែងប្រជាប្រិយ ឬច្រៀងរាំដើម្បីកំដរបរិយាកាសឱ្យមានភាពរីករាយ។ ចាស់ៗតែងនិទានរឿងឱ្យកូនចៅស្ដាប់ ពិសេសរឿងព្រះពុទ្ធយោនយកកំណើតជាសត្វទន្សាយនេះដោយឱ្យក្មេងៗគយគន់មើលទន្សាយក្នុងរង្វង់ព្រះចន្ទដើម្បីបញ្ជាក់ភាពជាក់ស្ដែង។ ក្នុងការកំដរបរិយាកាសកំសាន្តនេះ ចំណីសម្រាប់ហូបចុកតែងមានអំបុកនិងចេក ជាចាំបាច់ដែរ។ គេនាំគ្នាក្ដាប់អំបុកអកខ្លួនឯង ឬបង្អកអ្នកដទៃ ដោយយកដៃគក់ខ្នងលេងថ្នមៗ ហើយសួរថា « ពេញហើយឬនៅ ? »។ អ្នកត្រូវគេបង្អកឆ្លើយថា « នៅ! » គេសួរដដែលៗចំនួន៣ដង ទើបអ្នកត្រូវគេបង្អកហារមាត់ស្រែកថា « ពេញហើយ ៗ ! »។ អ្នកឈរមើលនាំគ្នាស្រែកទទួលព្រមៗគ្នាថា « សាធុ! សាធុ! »។ ក្រៅពីចេក និងអំបុក គេតែងនាំយកភោគផលផ្សេងៗទៀត ដែលគេទើបប្រមូលបានមកចូលរួមដែរ មានអំពៅ ត្រាវ ដំឡូងដូង ...។ ប៉ុន្តែអ្នកនៅស្រុកស្រែចម្ការ គេច្រើននាំគ្នាមកប្រជុំនៅកណ្ដាលភូមិ ឬនៅកណ្ដាលទីធ្លាវត្តដែលស្រឡះផងមើលឃើញតែមេឃនិងព្រះចន្ទ ដើម្បីប្រារព្ធពិធីសំពះព្រះខែនេះ។ គេនាំគ្នាជញ្ជូនអំបុក ចេក និង ចំណីផ្លែឈើមកចាក់ជារួមគ្នាលើកន្ទេល ហើយដាំឫស្សីពីរដើមធ្វើបង្គោល និងយកឫស្សីមួយដើមទៀតចងពីលើ ដើម្បីជានិមិត្តរូបនៃក្លោងទ្វារនៅកណ្ដាលទីធ្លានោះ។ គេក៏បានរៀបចំដង្វាយដាក់ថ្វាយព្រះចន្ទដោយឡែក ហើយអុជទៀនធូបបន់ស្រន់តាមបំណងរៀងៗខ្លួន។ ដល់ពេលខែត្រង់ អាចារ្យចាប់អុជទៀនដែលបិទភ្ជាប់នឹងឫស្សីចំនួន៣ដើម។ទៀនកណ្ដាលតំណាងឱ្យភូមិរបស់គេឯទៀនពីរទៀតតំណាងឲ្យភូមិជិតខាង។អាចារ្យចាប់បង្វិលឫស្សីដែលបិទទៀននោះចំនួន៣ជុំហើយដាក់ទៀនសំយុងចុះមកក្រោមឱ្យស្រក់ក្រមួនទៅលើស្លឹកចេក។ទំនាយទឹកភ្លៀងបរិបូណ៌ ឬខ្សត់ខ្សោយ ទៅតាមភាពនៃទៀននោះស្រក់ច្រើនញាប់ឬរង្វើល។ ចំណែកភោគផលស្រូវក្នុងភូមិស្រុក ក៏ទាយតាមរូបភាពក្រមួន ដែលបានស្រក់ទៅលើស្លឹកចេកដែរ។ គេជជែកគ្នាពី ទំនាយភោគផលទៅឆ្នាំក្រោយ ហើយឧបកិច្ចថាភ្លៀងនិងភោគផលស្រូវ ត្រូវតែសំបូរហូរហៀរក្នុងភូមិគេមិន ខាន។បន្ទាប់មកគេនាំគ្នាយកចេកទុំ និងអំបុកមកបង្អកគ្នាតាមទំនៀមទម្លាប់ដូចរបៀបខាងលើដែរ។

នៅក្នុងព្រះបរមរាជវាំង ការប្រារព្ធពិធីសំពះព្រះខែនេះ មានរៀបចំយ៉ាងឧឡារិកណាស់។ ទន្ទឹមនឹងនោះក៏មានរៀបពិធីបួងសួងប្រកាសផ្សងទឹកភ្លៀង ( ពិធីសម្រក់ទៀន ) ដោយមានអុជទៀនតាមចំនួនខេត្តនិងក្រុងសម្រាប់តំណាងឱ្យខេត្តនិងក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលដែរ។ ចំណែក តន្ត្រីដែលមាននាទីកំដរក្នុងពិធីនេះគឺ វង់តន្ត្រីពិណពាទ្យ៕

ខេមរវិទ្យា - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## គង់តែ ...! (បទពាក្យ៤ - មួយវគ្គមាន៨ឃ្លា)

កុកហើរលើមេឃ គង់ងាប់លើដី
ខ្លារស់ក្នុងព្រៃ គង់គេចាប់បាន
ត្រីហែលក្នុងទឹក គង់ងាប់លើចាន
ចោរទាំងប៉ុន្មាន គង់តែជាប់គុក។
ស្រីសាច់សខ្ចី គង់តែនឹងចាស់
ស្រឡាញ់គ្នាណាស់ គង់តែជួបទុក្ខ
អ្នកអួតខ្លាំងពេក គង់តែបាក់មុខ
ដើរបោកអ្នកស្រុក គង់តែគេដឹង។
ជីវិតរាល់រូប គង់តែនឹងស្លាប់
ត្រូវតែប្រញាប់ ស្វែងរកពំនឹង
ធ្វើបុណ្យដាក់ទាន លាលះកំហឹង
ព្រោះយើងមិនដឹង រស់បានត្រឹមណា។

## វស្សាដើមឆ្នាំ (បទពាក្យ៧)

វស្សាដើមឆ្នាំខ្យល់គ្រសាក់ ផ្គរក្ដួងភ្លៀងធ្លាក់រន្ទះឆាំង
ផ្លេកបន្ទោរព្រាកពន្លឺចាំង ពពកបិទបាំងសែងរង្សី។
សន្ធឹកខ្យល់ព្យុះស្នុះកក្រើក រំពើកព្រឹក្សាផ្អើលបក្សី
ម្រឹគាលោតផ្លោលបោលចូលព្រៃ បសុបក្សីរត់រចល់។
គង្ហាររលកបោកគគ្រេង សាគរធំធេងរញ្ជួយខ្វល់
នាវាយោគយោលខ្ទោលតាមខ្យល់ រៀចរង់វិលវល់ក្នុងជលសា។
មច្ឆាតូចធំហែលហើបហាក់ ឡើងតាមទឹកដក់រកអាហារ
ពួកហ៊ីងកង្កែបស្រែកឡូឡា ហ្វូងក្ដាមឆ្លេឆ្លាចេញពីរូង។
ផ្គរលាន់រណ្ដំគ្រហឹមគ្ហិល ខ្យល់រល់គួចវិលផ្គរលាន់ក្ដួង
ភ្លៀងធ្លាក់ខ្ទោកៗស្មោះដុះច្រូង មើលហ្វូងម្រឹគីស៊ីស្លឹកខ្ចី។
រុក្ខជាតិលូតលាស់ស្រស់ប៉ប្រិម ធារទឹកល្អាចល្អឹមដក់លើដី
បុប្ផាក្រៀមក្រោះស្រស់រីកថ្មី ត្រួយលាស់ខៀវខ្ចីយោលតាមខ្យល់។
សំណាបបន្លែផ្លែដំណាំ នាខែដើមឆ្នាំដាំយកផល
ផ្លែឈើខ្ចីទុំភ្ញុំមកដល់ នេះហើយគឺផលដើមវស្សា។

## រឿងបុរសយកលាទៅលក់

មានតំណាលថាបុរសពីរនាក់ឪពុកនិងកូនដឹកលាយកទៅលក់ឯផ្សារ។កូនជិះលើខ្នងលា ឪពុកដឹកខ្សែដើរពីមុខលា នៅពេលឆ្លងកាត់ហ្វូងមនុស្សវ័យកណ្ដាល ក៏មានសំលេងស្រែកចំអកថា៖

-នៅក្មេងសោះ សុខចិត្តឱ្យឪពុកដើរ ខ្លួនឯងជិះលើខ្នងលាបែបអ៊ាងអឺយ!

បុរសជាកូនឮដូច្នោះ ក៏ចុះចេញពីខ្នងលា ទុកឱ្យឪពុកជិះវិញម្ដង ឯខ្លួនក៏ទៅដឹកខ្សែមុខលាវិញ។ លុះពេលធ្វើដំណើរកាត់ហ្វូងស្រីៗជំទង់ ក៏មានសម្រែកចំអកថា៖

-ខូចសាច់កូនអស់ហើយ លោកតា បណ្ដោយឱ្យគ្នាដើរដឹកលាបែបនេះ មិនសមសោះ!

ឪពុកនិងកូនក៏ចាប់ផ្ដួលលាយកខ្សែចងជើង រួចនាំគ្នាសែងលាកាត់ហ្វូងមហាជនចម្រុះវ័យស្រាប់តែមានសម្រែកខ្លាំងៗថា៖

-នេះបានចំជាឆ្កួតលីលាមែន កែមិនឡើងទេ!

តម្លៃសីលធម៌រឿង៖ កម្រផ្គាប់ចិត្តមនុស្សគ្រប់គ្រូវណាស់

## រឿងល្បើកថ្មើរជើងម្នាក់

កាលនោះ មានថ្មើរជើងម្នាក់ធ្វើដំណើរមកដល់ពាក់កណ្ដាលផ្លូវ ឃើញដើមឈើមួយដើមនៅក្បែរផ្លូវ មានមែកបែកសាខាត្រជាក់ស្រួលក៏គិតថា៖ « អញសម្រាកហូបបាយនៅទីនេះត្រជាក់ស្រួលណាស់! » គិតហើយ គាត់ដាក់ប្រដាប់ប្រដានិងបាយកញ្ចប់នៅក្រោមដើមឈើនោះ រួចគាត់ទៅរកដងទឹកមកទុកផឹក។ពេលដើរចេញទៅមានសត្វស្វាមួយដែលអាស្រ័យនៅលើដើមឈើនោះក្រឡេកឃើញកញ្ចប់បាយវានឹកថា៖ « អញកំពុងតែឃ្លានផង ឥឡូវលាភមកដល់ល្មម ចាំអីទៀតអញ! សត្វស្វាក៏ចុះពីលើចុងឈើចាប់ហែកកញ្ចប់បាយស៊ីលុះត្រាតែឆ្អែត។វាខ្លាចម្ចាស់គេមកទាន់រករឿងធ្វើបាបវាក៏គិតថា៖ « អញយកបាយដែលនៅសល់ ទៅលាបមាត់ពពែសិន » គិតហើយស្វាក៏យកបាយ ដែលនៅសល់បន្តិចបន្តួច ទៅលាបលើមាត់ពពែដែលកំពុងឈរស៊ីស្មៅក្បែរនោះ រួចវាក៏ឡើងលើដើមឈើពួនចាំមើលហេតុការណ៍។ ថ្មើរជើងត្រឡប់ពីដងទឹកវិញឃើញកញ្ចប់បាយរហែកខ្ទេចខ្ទី គ្រាប់បាយរាយពាសវាលពាសកាលនឹកក្ដៅចិត្តក៏រអ៊ូថា៖«តើអ្នកណាមកស៊ីបាយអញ!កំពុងតែហេវហត់ថ្មើរជើងក្រឡេកមើលឆ្វេងស្ដាំ ឃើញគ្រាប់បាយជាប់នៅមាត់ពពែ ក៏ស្រែកឧទានខ្លាំងៗថា៖

- អញ្ចឹងទេតើ! ស៊ីស្មៅហើយស៊ីបាយទៀត។ គាត់ចាប់បានដំបងមួយស្ទុះទៅសំពងពពែយ៉ាងដំណំ តាមកំហឹងរបស់ខ្លួន ដោយសម្គាល់ថា ពពែលួចបាយខ្លួនស៊ី។

តម្លៃសីលធម៌រឿង៖ មនុស្សខូចយកតែរួចខ្លួន

# ការវិវត្តនៃប្រព័ន្ធទឹកសាប
# និងប្រវត្តិនៃវិស័យជលផលទឹកសាបកម្ពុជា (ត)




រូបទី៨. ផែនទីបង្ហាញពីផ្លូវក្បួនរទេះដែលអ្នកស្រុកលើចុះមកកែឆ្នៃត្រីនៅបាក់ព្រា បឹងទន្លេសាប

ទាក់ទងទៅនឹងប្រពៃណីនៃការលើកគ្នាមកចាប់ត្រីធ្វើប្រហុករបស់អ្នកស្រុកលើនៅភាគខាងជើងនេះក៏អាចជាទល្លីករណ៍មួយដែលអាជ្ញាធរថៃ**សម័យលោកម្ចាស់**ដាក់ការត្រួតត្រាលើខេត្តភាគខាងជើងបឹងទន្លេសាបជាពិសេសខេត្តបាត់ដំបងដើម្បីតែប្រភពសេដ្ឋកិច្ចត្រីបឹងទន្លេសាប និងស្រូវក៏អាចថាបាន។

ចំណុចសំខាន់មួយទៀតទាក់ទងនឹងឈ្មោះ"**បឹងទន្លេសាប**"ដែលតាមការស្រាវជ្រាវវិភាគតាម បែបវិទ្យាសាស្ត្រភាសាដែលធ្វើតាមរយៈការធ្វើសំភាសន៍ និងសាកសួរពីប្រភពចាស់ទុំដែលមានខ្សែស្រឡាយជាអ្នករៀនសូត្រចេះដឹងនៅក្នុងវង្សត្រកូលអភិជននាសម័យលោកម្ចាស់ និងចាស់ទុំដែលដឹងរឿងរ៉ាវក្នុងសង្គមច្រើនបានផ្ដល់សញ្ញាណឲ្យដឹងបានថាអ្នកបាត់ដំបងជំនាន់នោះមានទម្លាប់ហៅតៗគ្នា តាមគ្រាមភាសារបស់ពួកគេថា "**ថាលេសាប**" ដែលមានន័យថាសមុទ្រសាប នៅពេលដែលពួកគេទាំង នោះរួមទាំងអ្នកស្រុកពីនគររាជ, បូរីរ៉ាម, ស៊ីសាកេត និងស៊ូរិន្ទ ដែលចុះមកចាប់ត្រីធ្វើប្រហុកនៅបឹង ជង្រុកត្រីទឹកសាបដ៏ធំដូចជាសមុទ្រនៅក្នុងដីគោកបែបនេះ។ ពាក្យថា "**ថាលេសាប**" បានក្លាយទៅជា ទម្លាប់ហៅជាទូទៅ ហើយដោយសារតែពាក្យ "**ថាលេ**" មានសូរសៀងប្រហែលគ្នានឹងពាក្យ"ទន្លេ" នោះ អាចជនជាតិខ្មែរដ៏ច្រើននៅភាគកណ្ដាលយល់ស្របហៅថា"**ទន្លេសាប**" ដែលអាចប្រហែលជានៅក្នុង ដំណាក់កាលណាមួយនោះពាក្យនេះត្រូវបានគេទទួលស្គាល់យកមកប្រើប្រាស់ជាផ្លូវការដោយគ្រាន់តែបន្ថែមពាក្យបឹងពីមុខទន្លេសាបដើម្បីបញ្ជាក់ថា ទន្លេសាបគឺជាឈ្មោះបឹង។ ម្យ៉ាងទៀត បើតាមការដឹង តៗគ្នាមកថា ខ្មែរនៅសម័យបុរាណតែងហៅ បឹងទន្លេសាប, ទន្លេសាប, ទន្លេមេគង្គ និងទន្លេបាសាក់ថា "**ទន្លេធំ** " តែមួយដូចគ្នាទាំងអស់ ព្រោះបឹងទន្លេទាំងអស់តភ្ជាប់គ្នាទៅវិញទៅមកក្នុងប្រព័ន្ធតែមួយ។

## ៤. ប្រវត្តិឧស្សាហូបនីយកម្មនេសាទទឹកសាបនាសម័យអាណានិគមបារាំង

នៅពាក់កណ្ដាលសតវត្សទី១៩មានជនជាតិបារាំងម្នាក់បានធ្វើដំណើរចុះពីប្រទេសភូមាកាត់តាមប្រទេសសៀមចូលមកខេត្តសៀមរាបបានប្រទះឃើញប្រាសាទអង្គរវត្តដ៏អស្ចារ្យដែលត្រូវបានគេបោះបង់ចោលក្នុងព្រៃស្មសាន្តរាប់រយឆ្នាំ និងបឹងទន្លេសាបដែលសម្បូរទៅដោយត្រីទឹកសាបធម្មជាតិ ដ៏សម្បើមគ្មានពីរក្នុងលោក។ សៀវភៅឯកសាររបស់គាត់ បានបង្ហាញឲ្យពិភពលោកដឹងពីអ្វីដែលគាត់ បានឃើញជាពិសេសអច្ឆរិយភាពនៃស្ថាបត្យកម្មខ្មែរ និងនៃធនធានធម្មជាតិជាមរតកដ៏ពិសិដ្ឋ ដែល កកើតឡើងនៅក្នុងទឹកដីខ្មែរ (Mohout, M. H., 1864)[8] ។ព័ត៌មានទាំងពីរនេះបានទទួលការចាប់ អារម្មណ៍ពីគ្រប់មជ្ឈដ្ឋាននៅក្នុងប្រទេសបារាំង និងបានជួយដល់រដ្ឋាភិបាលបារាំងក្នុងការរៀបចំផែនការសេដ្ឋកិច្ចទ្រទ្រង់ដល់ការពង្រីកអាណានិគមរបស់ខ្លួននៅតំបន់ឥណ្ឌូចិនផង។ស្របគ្នាជាមួយនឹងការអភិវឌ្ឍឧស្សាហកម្មនេសាទសមុទ្រនៅអឺរុបផងនោះអ្នកសេដ្ឋកិច្ចបារាំង

[8] Mouhot,. M. H., 1864. Travels in the Central Part of Indo-China (Siam) Cambodia, and Laos, during the years 1858 , 1859 and 1860. Vol. 1 and Vo;. 2 (Reprint, White Lotus, Bangkok).

បានមើលឃើញថា ប្រព័ន្ធ ផលផលទឹកសាបនៅបឹងទន្លេសាបគឺជាមូលដ្ឋានសេដ្ឋកិច្ចតែមួយគត់ ដែលអាចធ្វើឧស្សាហូបនីយកម្ម នេសាទសម្រាប់បម្រើការនាំចេញ ដើម្បីបង្កើតមូលដ្ឋានសេដ្ឋកិច្ចជាដំបូងនៅប្រទេសនេះ ហើយដែលដោយលក្ខខណ្ឌនេះ,បារាំងបានជំរុញព្រះមហាក្សត្រខ្មែរព្រះបាទនរោត្តមដែលទើបឡើងគ្រងរាជ្យនៅឆ្នាំ១៨៦០ (ពេលនោះព្រះអង្គមានទាហានចំនួនតែ៣៥០នាក់ប៉ុណ្ណោះនៅការពារព្រះបរមរាជវាំង) ឲ្យយល់ព្រមដាក់ប្រទេសកម្ពុជាឲ្យនៅក្រោមអាណាព្យាបាលបារាំង និងដាក់ចេញនូវគោលនយោបាយ នេសាទឧស្សាហកម្មនៅឆ្នាំ១៨៦៣ ដើម្បីរកចំណូលសម្រាប់ថវិកាទ្រទ្រង់ការងាររាជការ និងរដ្ឋបាល អាណានិគម (Vincint,1871-2)[9]។គោលនយោបាយនេះបានកំណត់ថា“**សេរីភាពនៃការនេសាទ គឺជាគោលការណ៍ហើយសិទ្ធិនៃការកាន់កាប់ដំបូងត្រូវតែមានសុពលភាពជារហូត**”ដោយភ្ជាប់ជាមួយការអំពាវនាវដល់ជនជាតិខ្មែរទាំងអស់ឲ្យចូលរួមសកម្មភាពនេះ។ការអំពាវនាវនេះពុំបានទាក់ទាញជនជាតិខ្មែរណាម្នាក់ឲ្យចូលរួមឡើយដោយអាចជាមូលហេតុមិនមានបទពិសោធន៍ក្នុងការធ្វើនេសាទឧស្សាហកម្មមិនមានដើមទុនគ្រប់គ្រាន់មិនមានជំនាញបច្ចេកទេស មិនធ្លាប់រកស៊ីបណ្តាក់ទុនក្នុងរបរនេសាទ ឬដោយសារទស្សនៈ ″**ទីណាមានទឹកទីនោះមានត្រី**″ ឬមកពីប្រជាជនមានចំនួនតិចតួច ប្រហែលជាង១លាននាក់ប៉ុណ្ណោះនៅពេលនោះ (Blanc M., 1958)[10] ដែលធ្វើឲ្យរាជការខ្មែរនិងរដ្ឋបាលអាណានិគមត្រូវបង្ខំចិត្តងាកទៅរកវិនិយោគិនបរទេសវិញ។នាយទុន៥នាក់ដំបូងជាជនជាតិចិនមកពីហុងកុង បានចូលមកចុះកិច្ចសន្យាជាមួយអាជ្ញាធរខ្មែរ និងរដ្ឋបាលអាណានិគម ដើម្បីរកស៊ីផ្តាច់មុខនៅក្នុងឧស្សាហកម្មនេសាទនៅបឹងទន្លេសាបជាសម្បទានិកនេសាទ (Fermierdepeche) នៅក្នុងខេត្តចំនួនបីគឺពីរនៅពោធិសាត់មួយនៅកំពង់ធំនិងពីរនៅកំពង់ឆ្នាំង ដោយនាំចូលសម្ភារៈបច្ចេកទេសនេសាទទាំងអស់ដូចជាអួន (ធ្វើពីសសៃធ្មៃ) និងទូកក្តោងសមុទ្រធំៗដែលហៅថា ″**ទូកប៉ុកចាយ**″ យកមកប្រើសម្រាប់ធ្វើជាកន្លែងស្នាក់នៅកន្លែងកែច្នៃត្រី-ហាលត្រីឃ្លាំងនិងដឹកជញ្ជូន (លើកលែងតែបង្គោលឈើឬស្សីរល្លិជ័រទឹកជ័រចុង ដែលអាចរកបាននៅក្នុងស្រុក) និងពលករ ជំនាញពីស្រុកចិន (Vincint,1870-1)។ នាយទុនផ្តាច់មុខទាំងនោះបានចាត់ចែងកន្លែងនេសាទតូចៗជួលបន្តទៅឲ្យដង្វៅចិនតូចៗធ្វើនេសាទជាមួយការផ្តល់ឥណទានជាទុន និងសម្ភារៈបច្ចេកទេស ដោយទូទាត់សងវិញជាត្រីកែច្នៃនៅពេលប្រមូលផលសម្រាប់នាំចេញ។ កម្លាំងពលកម្មនេសាទ និងកែច្នៃត្រី ស្ទើរតែទាំងស្រុងជាជនជាតិវៀតណាមដែលធ្វើការតាមការបែងចែកពលកម្ម (division of labor) ដែលសម្បទានិក និងដង្វៅនេសាទចិននាំយកមកបំរើការងារនេសាទ ព្រោះតែជនជាតិខ្មែរម្ចាស់ស្រុកស្ទើរតែ ទាំងអស់នៅពេលនោះជាកសិករឯករាជ្យមិនមានទម្លាប់ ស៊ីឈ្នួលគេ (Mohout, M. H. 1884)។

ការតាំងទីលំនៅនៅលើទឹក ដោយការសាងសង់ផ្ទះបណ្តែតទឹកត្រូវបានចាប់ផ្តើមនៅពេលនោះ ដែលក្រោយមកបានក្លាយទៅជាភូមិបណ្តែតទឹករហូតមកដល់សព្វថ្ងៃ។ សម្បទានិកនេសាទផ្តាច់មុខ ទាំងអស់ត្រូវធានាបង់ពន្ធនេសាទតាមការកំណត់ជារៀងរាល់ឆ្នាំ ឯការនាំចេញត្រីត្រូវបង់ពន្ធទៅតាម បរិមាណនាំចេញទៅឲ្យរដ្ឋបាលអាណានិគម (Vincent, 1870-1)។

រហូតមកដល់ឆ្នាំ១៨៧២ ទើបមានបទបញ្ជានេសាទមួយដែលកំហិតមិនឲ្យធ្វើផ្នស់ ឬរបាំងព្រួល ឬស្សីកាត់បិទភ្ជិតទទឹងស្ទឹង ឬព្រែក ឬអូរទាំងអស់ ដោយត្រូវបើកច្រកមុខទឹកប្រមាណ៥0% សម្រាប់ នាវាចរណ៍ឆ្លងកាត់ តែក្រោយមកបានកែប្រែមកនៅត្រឹមតែ១/៣នៃទទឹងមុខផ្លូវទឹកវិញព្រោះមានការតវ៉ា ពីដង្វៅនេសាទនិងមេសង្វៀននេសាទ។មកដល់ឆ្នាំ១៨៧៥ទើបមានបទបញ្ជាទី២ដាក់កំហិតក្រឡាអួនឬប្រឡោះត្រៀមព្រួលឬស្សី ពីមួយទៅមួយ មិនឲ្យតូចជាង ២,៥សង់ទីម៉ែត្រ (Vincint,1870-1)។

[9] Vincint F., Jun., 1871-2. The Land of the White Elephant sights and scenes in Burma, Siam, Cambodia and Chin-China (1971-72). With and introduction and notes by John Villers (White Lotus Co. Ltd., Bangkok, Thailand, 1988).

[10] BLANC, M., 1958. Mission Hydrologique et Oceanographique au Cambodge (Cahiers du Pacifique No. 1, December, 1958. Published due to financial support of the Singer-Polignac Foundation.

**កំណត់ចំណាំ:** កំពស់ទឹកនៅកណ្តាលបឹងទន្លេសាបនាចុងខែកញ្ញាមានជាមធ្យមពី១០,៥ទៅ១១ម៉ែត្រ ហើយឡើងទៅដល់១២ម៉ែត្រនៅឆ្នាំទឹកធំ ដែលធ្វើឲ្យផ្ទៃបឹងទន្លេសាបរីកធំទៅដល់ផ្លូវជាតិលេខ៥នៅ ភាគខាងត្បូងឈៀងខាងលិច និងទៅដល់ផ្លូវជាតិលេខ៦នៅភាគខាងកើតឈៀងខាងជើង ដែលមាន ទំហំ ១៥,០០០គម២ ដែលធំជាងទំហំបឹងនៅរដូវប្រាំងចំនួន៥ដង (Vincint,1870-1)។ នៅពេលនោះ អ្នកវិទ្យាសាស្ត្រក៏បានរកឃើញថាត្រីទឹកសាបមានចំនួន៦២៥ប្រភេទផងដែរ (Tirant, 19885)[11] ។

### ៤.១. បច្ចេកទេសនេសាទឧស្សាហកម្មដែលប្រើប្រាស់ជាតំបូង

នៅពេលទទួលបានសម្បទាននេសាទនៅបឹងទន្លេសាបក្នុងខេត្តពោធិសាត់,កំពង់ធំនិងកំពង់ឆ្នាំងនៅអំឡុងឆ្នាំ១៨៦៣ហើយនោះ សម្បទានិកផ្តាច់មុខ ឬមេសង្វៀនទាំង៥ បានកេណ្ឌប្រមូលជនជាតិចិនដែលមានបទពិសោធន៍ធ្វើនេសាទ និងសម្ភារៈឧបករណ៍នេសាទ ដើម្បីមករៀបចំធ្វើអាជីវកម្មនេសាទនៅបឹងទន្លេសាប។ នៅក្នុងគ្រាដំបូងនោះ ដែននេសាទនៃខេត្តទាំង៣ ត្រូវបានបែងចែកទៅជាដែននេសាទសម្បទានចំនួន ៥ ដែលមាន២នៅខេត្តពោធិសាត់, ២នៅក្នុងខេត្តកំពង់ឆ្នាំង និង១ នៅក្នុងខេត្តកំពង់ធំ (សូមមើលរូបគំនូរទី៩) (Vincint,1870-1)។




រូបគំនូរទី៩. ផែនទីដែននេសាទសម្បទាន១៨៦៣-៨៤




រូបគំនូរទី១០. លប ណាំវ (ប្រភព: F. D 'AUBENTON)

ដោយសារស្ថានភាពទឹករាក់នៅបឹងទន្លេសាបនៅរដូវប្រាំង មានលក្ខណៈដូចគ្នានឹងបឹងទឹកប្រៃ ជាប់មាត់សមុទ្រនោះ ការនេសាទត្រូវបានគេប្រើរបាំងព្រួលរត់ស្របតាមចរន្តទឹកហូរចេញពីព្រៃលិចទឹក មកក្នុងតួបឹងដើម្បីគៀងត្រីឲ្យចូលស៊ង ដែលគេរៀបចំនៅមាត់បឹងខាងក្រៅព្រៃលិចទឹក។ នៅដើមរដូវ ប្រាំងពេលធ្លាក់ខ្យល់ត្រជាក់ពីទិសខាងជើងដំបូងនៅអំឡុងខែធ្នូបានធ្វើឲ្យលក្ខខ័ណ្ឌគីមីក្នុងទឹកនៅក្នុងតំបន់ព្រៃលិចទឹកមានការប្រែប្រួលយ៉ាងខ្លាំង ដោយការបញ្ជៀប(saturation)នៃខ្យល់អុកស៊ីហ្សែនទៅ ក្នុងទឹកឡើងដល់២០០% ដែលធ្វើឲ្យកំហាប់អុកស៊ីហ្សែនក្នុងទឹកឡើងខ្ពស់ដល់១៦មក្រ/លីត្របង្កើតរបាយដល់ស្រទាប់បាតដែលធ្វើឲ្យសារធាតុចំណីក្នុងទឹក អាចចាប់យកអុកស៊ីហ្សែន ដើម្បីបន្លែងខ្លួនឲ្យ ទៅជាបាក់តេរីហើយបញ្ចេញសារធាតុអាម៉ូនីញ៉ាក់ពុលទៅក្នុងទឹកជាពិសេសក្នុងតំបន់ព្រៃលិចទឹក ធ្វើឲ្យ ត្រីនៅទីនោះ នាំគ្នាគេចចេញតាមចរន្តទឹកហូរទៅរកកន្លែងដែលអាចរស់នៅបាន។ត្រីដែលថយចេញពីព្រៃលិចទឹកបានហែលសៀរតាមរបាំងព្រួលចូលទៅក្នុងស៊ងមួយដែលមានប្រឹះនៅមាត់ច្រក ធ្វើឲ្យ ត្រីចូលហើយចេញវិញមិនបាន។ ត្រីត្រូវរស់នៅក្នុងស៊ងនេះរហូតដល់ពេលដែលអ្នកនេសាទចាប់យក ទៅលក់ (សូមមើលរូបគំនូរទី១០ និង១១) (Filly & M. d'AUBEN TON, 1962-63)។

[11] Tirant, 1885. Itchological Work of Fresh water Fish in Cambodia.




រូបគំនូរទី១១. ការរាយរបាំងព្រួលណាំរចេញពីព្រៃលិចទឹកនៅតាមជាយបឹងទន្លេសាប
(ប្រភព: M. d'AUBENTON)

នៅតាមផ្លូវទឹកនានាដូចជាស្ទឹង ព្រែក ឬអូរ ដែលហូរចាក់មកក្នុងបឹងទន្លេសាប អ្នកនេសាទបានធ្វើរបាំងព្រួល (របាំងផ្ទួស) បិទមុខទឹកនៅដើមរដូវប្រាំង ដើម្បីចាប់ត្រីដែលធ្វើបន្លាស់ទីពីទំនាបខាងលើ មកក្នុងបឹងទន្លេសាប (សូមមើលរូបគំនូរទី១២)។ កំណាត់ដៃទន្លេតាមដងទន្លេសាបនៅខេត្តកំពង់ឆ្នាំងមួយចំនួនត្រូវបានគេធ្វើរបាំងផ្ទួសបិទដើម្បីចាប់ត្រីដែលធ្វើបន្លាស់ទីពីបឹងទន្លេសាបនិងទីទំនាបជុំវិញ។របាំងផ្ទួសចុងក្រោយនេះមានប្រវែងវែងជាងនិងរឹងមាំជាងពពួករបាំងផ្ទួសទីមួយព្រោះត្រូវសាងសង់ឆ្លង កាត់ដៃទន្លេដែលជ្រៅនិងមានចរន្តទឹកខ្លាំងផង(សូមមើលគំនូរ១៣)(M. d'AUBENTON, 1962-63)។




រូបគំនូរទី១២. របាំងផ្ទួសកាត់មុខស្ទឹងឬព្រែក និងមុខងារ




រូបគំនូរទី១៣. របាំងផ្ទួសកាត់ដៃទន្លេ នៅខេត្តកំពង់ឆ្នាំង




រូបគំនូរទី១៤. ការគៀរអួនចាប់ត្រីក្នុងណរត់ឈូងនៅបឹងទន្លេសាប




រូបគំនូរ១៥. ប្រតិបត្តិការអួនគំនៀរក្នុងស្ទឹងឬព្រែក




រូបគំនូរទី១៦. ការគៀរអួនក្នុងដៃទន្លេក្នុងខេត្តកំពង់ឆ្នាំង

នៅចុងរដូវប្រាំងក្នុងអំឡុងចុងខែមេសាដល់ចុងខែឧសភានៅតាមជាយមាត់បឹងទន្លេសាបអ្នកនេសាទបានវាយផែនព្រួលព័ទ្ធដែននេសាទសម្បទានដើម្បីធ្វើប្រតិបត្តិការអូសអួនគៀរចាប់ត្រីនៅមុនរដូវទឹកជម្លើងចូលមកដល់(សូមមើលរូបគំនូរទី១៤)។ នៅតាមដងស្ទឹង ព្រែក និងដៃទន្លេ ដែលគេបាន បិទដោយរបាំងឆ្នុកដើម្បីចាប់ត្រីកាលនៅដើមរដូវប្រាំងនោះវិញ ក៏ត្រូវបានគេធ្វើនេសាទអួនគំនៀរចាប់ ត្រីមុនរដូវទឹកជម្លើងចូលមកដល់ដែរ(សូមមើលគំនូរទី១៥និង១៦) (M. d’AUBENTON, 1962-63)។

ការនេសាទត្រីរាជនៅក្នុងបឹងទន្លេសាបនៅអំឡុងខែសីហា-កញ្ញានិងនៅតាមដងទន្លេសាបក្នុងកំណាត់ទន្លេប្រឡាយមាសនៅអំឡុងខែមីនា-មេសា ដែលអ្នកនេសាទជនជាតិចិនបានកសាងអួនហ៊ុំ ប្រវែង២-៣ពាន់ម៉ែត្រនិងជម្រៅ៣០ម៉ែត្រដែលជើងអួនត្រូវភ្ជាប់ដោយច្រវាក់ដើម្បីការពារកុំឲ្យត្រីត្បុលភក់គេចចេញបាន និងផ្នែកខាងលើភ្ជាប់ដោយខ្សែព្រួរ ដើម្បីហ៊ុំរឹបសាច់អួនចាប់ត្រី (សូមមើលរូបទី១៧)។

របៀបនេសាទមួយបែបទៀត ដែលនាំមកអនុវត្តដោយអ្នកនេសាទជនជាតិចិននៅដំណាក់កាលកែទម្រង់នេសាទនាឆ្នាំ១៨៨៤-៨៩គឺការនេសាទហ៊ុំសម្រាស់នៅចុងរដូវប្រាំងនៅក្នុងបឹងទន្លេសាបដោយការកាប់មែកឈើព្រៃលិចទឹកមកទម្លាក់ក្នុងតួបឹងនៅរដូវវស្សាបង្កើតបានជាជម្រកឲ្យត្រីនៅរដូវប្រាំងដើម្បីហ៊ុំអួនចាប់ត្រីដែលមកសំងំលាក់ខ្លួននៅទីនោះ (M. d’AUBENTON, 1962-63)។




រូបគំនូរ១៧. ប្រតិបត្តិការហ៊ុំអួនចាប់ត្រីរាជក្នុងបឹងទន្លេសាប (ប្រភព: M. d’ Aubenton, 1962-63)

## ៤.២. របៀបកែច្នៃត្រី

សម្បទានិកនេសាទផ្តាច់មុខទាំង៥ដោយឈរនៅលើមូលដ្ឋាននៃតម្រូវការនៃទីផ្សារអន្តរជាតិ និងដោយផ្អែកលើប្រភពធនធានត្រីរបស់បឹងទន្លេសាបផងនោះ បានជំរុញកែច្នៃជាត្រីប្រឡាក់និងត្រីងៀតដើម្បីនាំចេញ។ ត្រីដែលនេសាទបានត្រូវកាត់ក្បាល និងវះយកគ្រឿងក្នុងចេញ ហើយជ្រៀតជាចម្រៀក ប្រឡាក់អំបិលក្នុងកំហាប់ខ្ពស់ ហើយហាលថ្ងៃឲ្យស្ងួតល្អនៅលើរានហាលត្រីនៅកណ្តាលបឹងទន្លេសាប រួចសារប្រមូលវេចខ្ចប់ដើម្បីរក្សាទុកក្នុងជាល និងកញ្ចេផលិតក្នុងស្រុកធ្វើពីបន្ទះឬស្សីសម្រាប់នាំចេញ។លើកលែងតែត្រីប្រម៉ាដែលយកតែគ្រឿងក្នុងចេញហើយដាក់ត្រាំក្នុងទឹកអំបិលទាំងមូលតែម្តង ព្រោះជា ទំនិញដែលមានតម្លៃខ្ពស់ជាងគេសម្រាប់ផ្គត់ផ្គង់ទីផ្សារជនជាតិចិន ព្រោះត្រីនេះជាប្រភេទត្រីស៊ីសាច់ជា អាហារមិនសូវមានខ្លាញ់ និងមានរសជាតិឆ្ងាញ់ហើយអាចរក្សាទុកបានយូរមិនងាយខូចគុណភាពដូចត្រី ប្រានិងត្រីស្រកាផ្សេងៗទៀតឡើយ។ ទំនិញដែលមានតម្លៃបន្ទាប់ពីត្រីប្រម៉ាគឺ ត្រីរ៉ស់ងៀត និងត្រីឆ្តោរ ងៀត និងត្រីកេសប្រឡាក់ដែលជាពពួកត្រីស៊ី

សាច់ជាអាហារ មានសាច់ច្រើន មានរសជាតិឆ្ងាញ់ និង មិនស្វរ មានខ្លាញ់ ហើយអាចរក្សាទុកបានយូរគួរសមផងដែរ (Darboux et al, 1906)[12] ។

### ៤.៣. កំណើត ឬការចាប់ផ្តើមវារីវប្បកម្មនៅបឹងទន្លេសាប កម្ពុជា

ការសន្សំសំចៃរបស់ដង្ហៅនេសាទ និងអ្នកនេសាទជនជាតិចិន គឺជាការចាប់ផ្តើមសកម្មភាព វារីវប្បកម្មនៅក្នុងបឹងទន្លេសាប ដោយនៅពេលដែលពួកគេនេសាទត្រីបានម្តងៗ បានប្រទះឃើញត្រី ដែលមិនទាន់ធំដល់ខ្នាតតម្រូវមានចំនួនច្រើន ត្រូវលែងទៅក្នុងធម្មជាតិវិញនោះ ក៏បែកគំនិតចាប់យក មកបង្ខាំងទុកក្នុងស៊ីង ឬបែរនៅរដូវប្រាំង ដើម្បីថែបំប៉នចំណីមួយរយៈឲ្យបានធំធាត់ដល់ទំហំដែល ទីផ្សារតម្រូវអាចលក់បានបង្កើនចំណូលរបស់ពួកគេ។ ការថែបំប៉នត្រីក្នុងស៊ីង ឬបែរនេះបានប្រព្រឹត្តទៅ ប្រកបដោយជោគជ័យដែលធ្វើឲ្យបរនេះរីករាលដាលនៅទូទាំងបឹងទន្លេសាប ក្នុងរយៈកាលដ៏ខ្លី ដែល ធ្វើឲ្យអ្នកអនុវត្តទទួលបានបទពិសោធណ៍កាន់តែច្រើនឡើងៗ រហូតដល់ក្លាយទៅជាបច្ចេកទេសក្នុងការ ជ្រើសរើសប្រភេទ ឬពូជត្រីដែលស្រួលចិញ្ចឹម ធំធាត់លឿន ហើយអាចរកឱកាសលក់ឲ្យបានថ្លៃផង។ ការថែបំប៉នត្រីនេះ ត្រូវបានអ្នកនេសាទនៅកន្លែងផ្សេងៗទៀតអនុវត្តតាម រហូតដល់ក្លាយទៅជាការ ចិញ្ចឹមត្រីតាំងពីកូនត្រីក្នុងស៊ីង ឬបែររហូតដល់ធំពេញខ្នាតដែលទីផ្សារតម្រូវ នៅទូទាំងប្រទេសនាពេល ក្រោយៗមកទៀត (Darboux et al, 1906)។

### ៤.៤. ការកែទម្រង់ឧស្សាហកម្មនេសាទដំបូង

នៅឆ្នាំ១៨៨៤ដោយរងសម្ពាធពីការបះបោររបស់កសិករនៅឆ្នាំ១៨៦៦ ១៨៦៧ ១៨៧២ ១៨៧៦-៧៧ និងឆ្នាំ១៨៨៥-៨៦ បានធ្វើឲ្យមានការកែប្រែជាបន្ទាន់តាមកំណែទម្រង់ដំណើរការនយោបាយ រដ្ឋបាលនិងសេដ្ឋកិច្ច ក្រោយពេលដែលរាជការខ្មែរនិងរដ្ឋបាលអាណានិគមបារាំងបានភ្ញាក់ ដឹងពីផលប៉ះពាល់ពីការកេងប្រវ័ញ្ចដ៏ធំក្នុងឧស្សាហកម្មនេសាទនិងបានទទួលស្គាល់ភាពទន់ខ្សោយនៃប្រព័ន្ធរដ្ឋបាលរបស់ខ្លួននៅពេលនោះ (PETILLOT, Loys. 1911)[13] (Jan Ovesen, et all, 1996)[14] ។ ដែននេសាទត្រូវបានដកហូតពីសម្បទានិកផ្តាច់មុខទាំងអស់ហើយបើកទូលាយឲ្យអ្នកនេសាទទូទៅអាចចូលទៅធ្វើនេសាទបានពេញមួយឆ្នាំ ដោយតម្រូវឲ្យបង់ពន្ធតិចតួច ចាប់ពីឆ្នាំ១៨៨៤ ដល់ឆ្នាំ១៨៨៩ (Marguet, 1905; Loys Petillot, 1911)។ ទោះជាយ៉ាងនេះក៏ដោយ ការនេសាទទាំងអស់នៅតែស្ថិតក្រោមការគ្រប់គ្រងរបស់នាយទុនផ្តាច់មុខដដែល ព្រោះពួកគេបានក្តាប់ទីផ្សារត្រីនិងប្រភពឥណទាននេសាទយ៉ាងណែនដែលអ្នកនេសាទស្ទើរតែទាំងអស់ត្រូវតែរណប។

នៅអំឡុងឆ្នាំ១៨៨៩-៩០ ក្នុងទិសដៅរៀបចំចាត់ចែង និងបែងចែកផលប្រយោជន៍ពីធនធាន ជលផលឡើងវិញ និងដើម្បីបំពេញសំណូមពរប្រជាជនដែលនៅជិតខាងដែននេសាទ ឲ្យមានកន្លែងធ្វើនេសាទនោះ រដ្ឋបាលអាណានិគមបានចំណាយពេលសិក្សាពីទំនាក់ទំនងអេកូឡូស៊ី-ភូមិសាស្រ្ត និងសង្គម-សេដ្ឋកិច្ចនៃប្រជាកសិករដែលជាប់ពាក់ព័ន្ធអស់រយៈពេលជាង១០ឆ្នាំដើម្បីកំណត់ដែននេសាទសម្បទានសម្រាប់ដាក់ឲ្យដេញថ្លៃដោយតម្លាភាព និងដែននេសាទទុកសម្រាប់ការនេសាទជាលក្ខណៈគ្រួសាររបស់ប្រជាជនដែលមិនជាប់ពន្ធ (G. Darboux, et all, 1906)[15] ។

នៅឆ្នាំ១៩០៧ ខេត្តមួយចំនួននៅភាគខាងជើង និងពាយព្យ (ភាគខាងជើងនៃខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តបាត់ដំបង និងភាគខាងជើងនៃខេត្តពោធិសាត់) ត្រូវបានអាជ្ញាធរថៃ បង្វែរ

---

12 Darboux et al, 1906. Nos Richesse Coloniales 1900-1905: L’Industrie des Peches aux Colonies.
13 PETILLOT Loys, 1911. Une Richesse du Cambodge: La Peche et les Poissons. Publication: Paris Augustin CHALLAMEL. Editeur.
14 OVESEN, J.; I-B., TRANKELL, AND J. OJENDAL, 1996. When every household is an island: social organization and power structure in rural Cambodia.
15 DARBOUX, G.; COTTE, J.; STEPHAN, P. & VAN GAVER, F., 1906. Nos Richesse Coloniales 1900-1905: L’Industrie des Peches aux Colonies (Tome II). Publication: Marseille, Barlatier, Imprimeur-Editeur.

រដោយសន្តិភាពមកឲ្យរាជការព្រះបាទស៊ីសុវត្ថិ(គ្រងរាជ្យនៅឆ្នាំ១៩០៤)វិញតាមការចុះហត្ថលេខារវាងអាជ្ញាធរថៃ និងរដ្ឋបាលអាណានិគមនៅលើសន្ធិសញ្ញាឆ្នាំ១៩០៤ និងឆ្នាំ១៩០៧ (សូមមើលរូបទី១៨) ក្រោយពីបានកាន់កាប់អស់រយៈ២៧០ឆ្នាំចាប់ពីឆ្នាំ១៦៣៧ដល់១៩០៧ (Martin, 1994)[16] ។



រូបទី១៨. ផែនទីប្រទេសកម្ពុជាបង្ហាញតំបន់កាន់កាប់ដោយអាជ្ញាធរថៃអស់រយៈពេល២៧០ឆ្នាំគិតត្រឹមឆ្នាំ១៩០៧

នៅឆ្នាំ១៩០៨ រាជការខ្មែរបានគ្រប់គ្រងបឹងទន្លេសាបទាំងស្រុង ហើយក៏រៀបចំដែននេសាទ ទាំងអស់ឲ្យទៅជា: (១) ដែននេសាទរៀបជាពួកដែលត្រូវចាត់តាំងជាឡូត៍បឹងព្រៃក ឡូត៍សំរាស់ (បង្កើតតាមទម្លាប់អ្នកនេសាទក្នុងស្រុក) និងឡូត៍ដាយត្រីតាមដងទន្លេសាប ក្នុងខេត្តកណ្តាល និងរាជធានីភ្នំពេញ (ប្រភេទថង់សំណាញ់ធំរូបរាងដូចអួនអូសនៅសមុទ្រដែលគេដាក់កាងបញ្ច្រាស់ចរន្តទឹក បើកមាត់ពីបាតដីដល់ផ្ទៃលើទឹក ដើម្បីត្រងចាប់ត្រីដែលធ្វើដំណើរចុះតាមចរន្តទឹក ដែលនាំមកអនុវត្តដោយអ្នកនេសាទចិន)[17] ដើម្បីដាក់ឲ្យដេញថ្លៃជាសាធារណៈសម្រាប់រយៈពេលបីឆ្នាំម្តង (សូមមើលរូបគំនូរទី១៩និង២០)។ (២) ដែននេសាទដែលត្រូវការពារទុកសម្រាប់នេសាទសិប្បកម្ម ឬចល័តដូចជាការនេសាទត្រីរាជនិងត្រីគល់រាំងដោយអួនសម្រុងចំនួន២ដងក្នុងមួយឆ្នាំ(អំឡុងខែសីហា-កញ្ញានៅក្នុងបឹងទន្លេសាបនិងអំឡុងខែមីនា-មេសានៅក្នុងដងទន្លេក្នុងខេត្តកំពុងឆ្នាំង)[18]។ការនេសាទខាងលើនេះត្រូវមានលិខិតអនុញ្ញាតិ និងត្រូវមានសៀវភៅបន្ទុកដែលចង្អុលបង្ហាញបទបញ្ជាដែលអ្នកកាន់កាប់ត្រូវតែគោរពតាមដាច់ខាតជាមួយការកត់ត្រាផលត្រីដែលចាប់បានមួយលើកៗផង។ត្រីធំៗដែលចាប់បានដោយអួនសម្រុង



រូបគំនូរទី១៩. ផែនទីទីតាំងនេសាទដាយតាមដងទន្លេសាប



រូបគំនូរទី២០. ប្រតិបត្តិការនេសាទដាយ(បើកនិងបិទមាត់)

17 បច្ចេកវិទ្យានេះត្រូវបានអ្នកនេសាទចិនចំលងតាមបច្ចេកវិទ្យាអួនអូសសមុទ្ររបស់អឺរ៉ុបដែលយកមកប្រើនៅប្រទេសចិននៅចុងសតវត្សទី១៩។
18 ត្រីរាជពងកូននៅទន្លេមេគង្គលើតំបន់ត្រីកោនមាសជាប់ព្រំប្រទល់ប្រទេសចិនក្នុងខែមិថុនា-កក្កដា។ កូនញាស់ហើយអណ្តែតតាមទឹកចុះមកក្រោមដែលមួយចំនួនតូចសំងំនៅតំបន់ ខាងលើល្បាក់ខោន ហើយមួយចំនួនធំធ្លាក់ដល់ បឹងទន្លេសាបដើម្បីស៊ីចំណីធំធាត់នៅទីនោះ ឯត្រីគល់រាំងពងកូននៅតំបន់ទឹកជ្រូរខេត្តស្ទឹងត្រែងនិងក្រចេះក្នុងខែមិថុនា-កក្កដា ដែលកូនញាស់អណ្តែតតាមទឹកចូលទៅក្នុង បឹងទន្លេសាបស៊ីចំណីធំធាត់នៅទីនោះដែរ។ ត្រីធំៗដែល ចុលទៅស៊ីចំណីនៅក្នុងបឹងទន្លេសាប នៅពេលទឹកនឹងឬកូនរដូវប្រាំងក្នុងរដូវវស្សាក្នុងខែសីហា-កញ្ញាត្រូវតែថយចេញពីក្នុងព្រៃលិចទឹកមកនៅលំហរកណ្តាលបឹងរួចបន្តដំណើរចេញទៅទន្លេមេគង្គលើវិញ។

ជាពិសេសត្រីរាជត្រូវបាននាំទៅលក់ (ស្រស់ ឬប្រឡាក់អំបិល) នៅប្រទេសថៃ តាមច្រកប៉ោយប៉ែតខេត្តបាត់ដំបង[19]។ ឡូត៍នេសាទបឹងព្រែក និងឡូត៍ សម្រាស់ និងឡូត៍នេសាទដាយត្រី ត្រូវបានកំណត់ព្រំសីមារួចជាបន្តបន្ទាប់ដូចតទៅ៖ រាជធានីភ្នំពេញ (១៩០៣) ខេត្តព្រៃវែង (១៩០៩) ខេត្តកណ្តាល កំពង់ចាម ពោធិសាត់ កំពង់ឆ្នាំង និងកំពង់ធំ (១៩១១) ខេត្តតាកែវ(១៩២៣) និងខេត្តបាត់ដំបងនិងសៀមរាប (១៩២៦) ដោយទុកផ្ទៃក្រឡាចំនួន៧% នៃផ្ទៃឡូត៍នេសាទបឹងព្រែកនិមួយៗ សម្រាប់អ្នកភូមិនៅជិតខាងធ្វើនេសាទឥតជាប់ពន្ធជាលក្ខណៈគ្រួសារ (Loys Petillot, 1911)។

ការនាំចេញត្រីកែច្នៃ ទៅប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី សឹង្ហបូរី ហុងកុង និងប្រទេស អាហ្វ្រិកមួយចំនួនដែលនៅក្រោមអាណានិគមបារាំងដូចគ្នាដែលប្រព្រឹត្តទៅតាមការដឹកជញ្ជូនតាមផ្លូវទឹកយកទៅវេចខ្ចប់ចុងក្រោយនៅផ្សារច្រើឡឹង,ក្រុងព្រៃនគរ(បច្ចុប្បន្នជាទីក្រុងហូជីមិញ)ត្រូវបានចាត់ទុកថាជាប្រភពចំណូលដ៏សំខាន់របស់វិស័យនេសាទ តែចំណូលពីប្រភពទាំងពីរនេះ តាំងពីចាប់ ផ្តើមឧស្សាហកម្មនេសាទរហូតមកនៅតែទាបជាងការរំពឹងទុកជានិច្ច។ ផលិតផលត្រីនាំចេញ រួមមាន ត្រីងៀត ប្រហុក ខ្លាញ់ ត្រី (៤-៥ពាន់តោនចម្រាញ់ពីត្រីល្អិតដែលបានពីការនេសាទដាយ), អណ្តើក-កន្ធាយ និងក្រពើ (គ្មានការកត់ត្រា) តែងតែមានបរិមាណទាបជាងការពិត ដោយសារការរត់ពន្ធដ៏ខ្លាំង ក្លាមិនអាចទប់ស្កាត់បាន (Darboux et al, 1906)។ អណ្តើក-កន្ធាយរស់និងក្រពើរស់រាប់រយតោនក្នុងមួយឆ្នាំៗត្រូវបាននាំយកទៅស្តុកនៅខេត្តមីថរ(វៀតណាម) សម្រាប់នាំចេញជាបន្តទៅប្រទេសចិនធ្វើជាម្ហូបអាហារជាន់ខ្ពស់និងការកែច្នៃស្បែក។ការគ្រប់គ្រងត្រួតពិនិត្យឧស្សាហកម្មនេសាទ និងការ ប្រមូលពន្ធនេសាទ និងផលផលនាំចេញនៅពេលនោះជាភារកិច្ចរបស់តម្រួត។

ក្រោយពីឆ្នាំ១៩០៨មក ការប្រមូលពន្ធពីការនេសាទឧស្សាហកម្មនិងសិប្បកម្មត្រូវបានចាត់ចែង យ៉ាងច្បាស់លាស់សម្រាប់ថវិកាថ្នាក់ជាតិ, ថ្នាក់ខេត្ត និងថ្នាក់ឃុំដែលមន្ត្រីរដ្ឋបាល នៅតាមបណ្តាថ្នាក់ ទាំងនោះត្រូវចូលរួមប្រមូលពន្ធ ដើម្បីពង្រឹងការងាររដ្ឋបាលពីថ្នាក់ជាតិដល់ថ្នាក់ឃុំឲ្យទៅជាបង្អែកនៃ ការគ្រប់គ្រងរដ្ឋ។ យ៉ាងណាក៏ដោយនាយទុនទាំង៧ នៅតាមខេត្តជុំវិញបឹងទន្លេសាប (២នៅកំពុងឆ្នាំង ២នៅពោធិសាត់ ១នៅបាត់ដំបង ១នៅសៀមរាប និង១នៅកំពុងធំ) នៅតែគ្រប់គ្រងប្រព័ន្ធឥណទាន និងការនាំចេញយ៉ាងមានប្រសិទ្ធភាពបានជារហូត ជាមួយការបិទបាំង បរិមាណផលត្រីដែលចាប់បាន ដើម្បីបន្ថំបរិមាណត្រីកែច្នៃនាំចេញក្នុងបំណង គេចវេសពីការបង់ពន្ធ (Richommes report, 1917)[20] ។

ផលត្រីចាប់បានហាក់ដូចជាមិនដែលបានកត់ត្រាសោះ នៅក្នុងរយៈពេល៣ទសវត្សដំបូងដោយ គ្រាន់តែដឹងថាពន្ធនេសាទដែលប្រមូលបានមានចំនួន១លាន៨សែនហ្វ្រង់ប៉ុណ្ណោះ នៅឆ្នាំ១៨៧៥-៨៥ ឯបរិមាណត្រីកែច្នៃនាំចេញមានមិនដែលលើសពី២ម៉ឺនតោនក្នុងមួយឆ្នាំឡើយ ហើយបរិមាណនេះមាន តម្លៃស្មើនឹង៧លានហ្វ្រង់ នៅជំនាន់នោះ (GRUVEL, A., 1925)[21]។

ដោយសារតែការកេងប្រវ័ញ្ច និងការឃុបឃិតគ្នានៃពួកដង្ហៅនេសាទ, ឈ្មួញនាំចេញត្រី និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ បានធ្វើឲ្យចំណូលរដ្ឋបានតិចមិនអាច អភិវឌ្ឍវិស័យជលផលបានឡើយ (មានតែឡូទឹកត្រី៦កន្លែងប៉ុណ្ណោះនៅទូទាំងប្រទេស) ឯស្តុកត្រីធម្មជាតិជាពិសេសត្រីធំៗ ត្រូវបានធ្លាក់ ចុះយ៉ាងខ្លាំងនៅឆ្នាំ១៩២៦-៣០ (P. Chevey et F. Le Poulin, 1939)។

19 បច្ចុប្បន្នសាច់ត្រីរាជមានតម្លៃណាស់នៅប្រទេសថៃ(២០$/គក្រ) ព្រោះគេមានជំនឿថាបរិភោគសាច់ត្រីនេះធ្វើឲ្យមានអាយុវែង។ រហូតមកដល់សព្វថ្ងៃទីផ្សាត្រីរាជនៅប្រទេសថៃនៅតែសំខាន់ដដែល។

20 Bulletin Economique No. 45-September, 1904. La Peche au Grand Lac ( Cambodge ).
Releve des exportations chapitre “Peche” pendant le cours des trois annees consecutives 1902, 1903 et 1904.

21 GRUVEL, A., 1925. L’INDO-CHINE: Ses Richesses Marines et Fluviales (Exploitation Actuelle Avenir).
Publication: Paris Societe d’Editions (Geographiques, Maritimes et Coloniales), Ancienne Maison CHALLAMEL, Fondee en 1839.

ទំនាស់យុត្តាធិការនៃដែននេសាទរវាងការនេសាទជាប់ពន្ធ និងការនេសាទគ្រួសាររបស់អ្នកភូមិជិតខាង បានជម្រុញឲ្យរាជការព្រះបាទស៊ីសុវត្ថិមុនីវង្ស (គ្រងរាជ្យនៅឆ្នាំ១៩២៧) ដាក់ចេញនូវបទបញ្ញានេសាទជាបន្តបន្ទាប់ដើម្បីគ្រប់គ្រងធនធាននេះឲ្យបានប្រសើរឡើងវិញដូចជាបានកំណត់ព្រំសីមាឡូត៍នេសាទទាំងអស់ទៅក្នុងផែនទីភូមិសាស្ត្រច្បាស់លាស់នាអំឡុងឆ្នាំ១៩២៦-២៩និងបានលប់ចោលទាំងស្រុងនូវការនេសាទត្រីរាជដោយអួនសម្រុងនៅបឹងទន្លេសាប និងការសំរេចលប់ឡូត៍ នេសាទលេខ៤ខេត្តសៀមរាប, ឡូត៍នេសាទលេខ២ និងលេខ៦ខេត្តកណ្តាល នៅអំឡុងឆ្នាំ១៩៣១ (Darboux et al, 1906; P. Chevey et F. Le Poulin, 1939)[22] ។

ទាំងនេះ អាចជាកំណើនសម្ពាធពីផលប៉ះពាល់នៃចំនួនប្រជាជន ដែលចេះតែកើនឡើងពីចំនួន ២.៤០៣០.០០នាក់ នៅឆ្នាំ១៩២១ ទៅចំនួន ២.៨០៦.០០០នាក់ នៅឆ្នាំ១៩៣១ រួចឡើងដល់ចំនួន ៣.០៤៦.០០០នាក់ នៅឆ្នាំ១៩៣៦ ហើយឡើងទៅដល់ចំនួន ៣.១៩៥.០០០នាក់ នៅឆ្នាំ១៩៣៩ (Blanc, M., 1958)។ នៅពេលប្រហាក់ប្រហែលគ្នានេះដែរ គឺនៅអំឡុងឆ្នាំ១៩២៣-៣៨ ចំណូលពីការនេសាទឧស្សាហកម្មហាក់ដូចត្រូវបានអាជ្ញាធរយកចិត្តទុកដាក់កត់ត្រាបានល្អបង្គួរដែលអាចឲ្យគេដឹងបានថាចំណូលនៅឆ្នាំ១៩២៣ មានចំនួន ៧១០.០០០ផ្លាស់ ហើយកើនឡើងជាបន្តបន្ទាប់ រហូតដល់១លាន៣សែនផ្លាស់នៅឆ្នាំ១៩២៩ រួចចាប់ធ្លាក់ចុះបន្តិចម្តងៗមកវិញ រហូតមកនៅត្រឹមចំនួន ២៧០.០០០ផ្លាស់[23] នៅឆ្នាំ១៩៣៨ (P. Chevey et F. Le Poulin, 1939)។

### ៤.៥. ការគ្រប់គ្រងវិស័យនេសាទទឹកសាបតាមមូលដ្ឋានវិទ្យាសាស្ត្រលើកដំបូង

ការខកខានមិនបានទទួលផលប្រយោជន៍ធំដុំពីប្រភពធនធាននេសាទទឹកសាបដ៏សម្បើមនេះបានធ្វើឲ្យរដ្ឋបាលអាណានិគមបារាំងចាប់អារម្មណ៍ដល់ការស្រាវជ្រាវវិទ្យាសាស្ត្រដោយបានបញ្ជូននាវាស្រាវជ្រាវធំមួយឈ្មោះ "La Renaissance" ឲ្យមកធ្វើការស្រាវជ្រាវនៅបឹងទន្លេសាប នៅអំឡុងឆ្នាំ ១៩៣៥-៦។ ការស្រាវជ្រាវបានរកឃើញនូវមូលហេតុដែលធ្វើឲ្យស្តុកត្រីធម្មជាតិធ្លាក់ចុះជាបន្តបន្ទាប់ជាពិសេសប្រភេទត្រីដែលឡើងទៅពងកូន នៅតំបន់ទឹកជួរផ្នែកខាងលើទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង និងក្រចេះ។ជាទម្លាប់ធម្មជាតិ ត្រីមេពូជធំៗភាគច្រើន ត្រូវចាកចេញពីកន្លែងស៊ីចំណីនៅបឹងទន្លេសាប នៅដើមរដូវប្រាំង (តុលា-កុម្ភៈ) ដោយត្រូវឆ្លងកាត់ដៃទន្លេសាបមុននឹងបន្តដំណើរទៅផ្នែកខាងលើទន្លេមេគង្គដើម្បីបន្តពូជនៅរដូវទឹកតម្លើងក្រោយដែលនៅពេលឆ្លងកាត់នេះភាគច្រើននៃត្រីមេពូជទាំងនោះត្រូវចាប់បានដោយឧបករណ៍នេសាទដាយជាច្រើនមាត់ដែលដាក់កាងបន្តគ្នាជាជួរជាងពាក់កណ្តាលទទឹងទន្លេចាប់តាំងពីពាមលង្វែកមកដល់ជិតទន្លេចតុមុខដែលរួមទាំងអស់មានចំនួន២១ជួរ។ ឡូត៍ដាយ ត្រូវបានលប់ចោលទាំងស្រុងនៅឆ្នាំ១៩៣៩ តែដោយសារមានការតវ៉ាពីពលរដ្ឋនៅខេត្តកំពង់ស្ពឺ និង នៅភាគខាងលិចខេត្តកណ្តាលដែលសុំឲ្យមានការផ្គត់ផ្គង់ត្រីធ្វើប្រហុកនោះ ការនេសាទដាយត្រូវបានអនុញ្ញាតឲ្យធ្វើឡើងវិញនៅប្រហែល៣ឆ្នាំក្រោយមកតែអនុញ្ញាតិឲ្យចាប់តែត្រីល្អិតសម្រាប់អ្នកស្រុកធ្វើប្រហុកនៅខែមករា និងកុម្ភៈប៉ុណ្ណោះ (P. Chevey et F. Le Poulin, 19៤0 )[24]។

*(នៅមានត)*

ដោយ ទូច ស៊ាងតាណា

[22] CHEVEY, P. and LE POULIN, F., 1939. Rapport Preliminaire sur la Peche dans les eaux douces Cambodgiennes (Etudes scientifique, technique et economique). Extrait du Bulletin Economique de l'Indochine (Fascicules 1 et 2).

[23] រូបិយវត្ថុខ្មែរនៅមុនឆ្នាំ១៨៨៥គឺ(សាតាង) អាចជាប្រាក់ថៃ បន្ទាប់មកពីឆ្នាំ១៨៨៥-១៩៥៥គឺ (ហ្វ្រង់) ហើយពីឆ្នាំ១៨៩៥ មកដល់ពេលបានឯករាជ្យគឺ (ផ្លាស់) ដែលថ្លៃជាងលុយហ្វ្រង់៥ដង។

[24] CHEVEY, P. and LE POULIN, F., 1940. La Peche dans les Douces du Cambodge (5th Memory). Publication: L'Institut Oceanographique de l'Indochine (Published under orientation of Armend KREMPF and Pierre CHEVEY).



រូបភាពក្នុងកិច្ចប្រជុំវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា





ប្រាសាទភ្នំក្រោម